ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY


## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ ធនាគារ ស្ថាបនា ភីអិលស៊ី

# RISK MANAGEMENT IN CREDIT PROVISION BY SATHAPANA BANK Plc

## ជំនាញ៖ ហិរញ្ញវត្ថុ និងធនាគារ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ ធនាគារ ស្ថាបនា ភីអិលស៊ី

RISK MANAGEMENT IN CREDIT PROVISION BY SATHAPANA BANK Plc


**គ្រូណែនាំ៖ គ្រុង សាវរី**


**ជំនាញ៖ ហិរញ្ញវត្ថុ និងធនាគារ**

**រាជធានីភ្នំពេញ-ឆ្នាំ២០២៥**

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទ៖ ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់**
**ធនាគារ ស្ថាបនា ភីអិលស៊ី**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

គ្រុង សាវរី

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីយើងខ្ញុំបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញហិរញ្ញវត្ថុ និងធនាគារ នៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល ៤ ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាហិរញ្ញវត្ថុ និងធនាគារ ជាពិសេសក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញហិរញ្ញវត្ថុ និងធនាគារ ជាជំនាញមួយដែលមានសារៈសំខាន់សម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការធនាគារដែរ។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារគណនេយ្យ ហិរញ្ញវត្ថុ និងធនាគារ នៅក្នុងកម្មវិធីសិក្សាតាំងពីឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្តការងារធនាគារពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថាកិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទស្តីពី **«ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារ ស្ថាបនា ភីអិលស៊ី»** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការផ្តល់ឥណទានរបស់ធនាគារ។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធ



**សុខ ច័ន្ទដារា**
ID: B22/1362



**ឈាង ម៉ីលីង**
ID: B22/2137



**មឿង សុខហេង**
ID: B22/2214



**ស្រស់ ចំណាន**
ID: B22/2183



**សុធា សុភក្តិ**
ID: B22/2184

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិត នៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញហិរញ្ញវត្ថុ និងធនាគារ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារ និងមិត្តភក្តិដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតីជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះ ក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតដល់អ្នកមានគុណ ដែលបាន ចំណាយទាំងកម្លាំងកាយ និងកម្លាំងចិត្តចិញ្ចឹមបីបាច់ដល់យើងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅដល់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានជួយបង្ហាត់បង្រៀនដល់ក្រុមយើងខ្ញុំ នាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដា ដែលបានផ្តល់នូវការបង្ហាត់បង្រៀន បណ្តុះបណ្តាល ព្រមទាំង ផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះអ្នកគ្រូ **ត្រុង សាវទី** ជាគ្រូណែនាំ ដែលបានជួយជ្រោមជ្រែងបង្ហាត់ បង្ហាញបន្ថែមសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។ សូមគោរព ថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិក នៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែង ក្នុងការណែនាំ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានភាព ជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែ ពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## **អំណះអំណាង**

ក្រុមយើងខ្ញុំជា និស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញហិរញ្ញវត្ថុ និងធនាគារ នៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២៖ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ «**ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារ ស្ថាបនា ភីអិលស៊ី**» នេះគឺពិតជាស្នាដៃរបស់ក្រុមយើងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវដែលលើកឡើងនេះ ពិតជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនមកឡើយ។

ថ្ងៃពុធ ៨កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**

សុខ ច័ន្ទដារា

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ហេតុដោយមានការណែនាំ អនុញ្ញាត និងលើកទឹកចិត្តពីគណៈគ្រប់គ្រង នៃសាកលវិទ្យាល័យវ៉ាន់ដា។ សាកលវិទ្យាល័យ បានផ្តល់ឱកាសឱ្យក្រុមយើងខ្ញុំ បានសរសេររបាយការណ៍ស្រាវជ្រាវ ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញហិរញ្ញវត្ថុ និងធនាគារ ក្រោមប្រធានបទ «ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារ ស្ថាបនា ភីអិលស៊ី» ។ គោលបំណងសំខាន់ៗនៅក្នុងការស្រាវជ្រាវនេះ គឺដើម្បីស្វែងយល់ពីនីតិវិធីការគ្រប់គ្រងហានិភ័យឱ្យមានប្រសិទ្ធភាពរបស់ធនាគារ ស្ថាបនា ភីអិលស៊ី មានដំណើរការ និងយុទ្ធសាស្ត្រដូចម្តេចខ្លះ?

ជាលទ្ធផល នៃការស្រាវជ្រាវទៅលើប្រធានបទខាងលើ ក្រុមយើងខ្ញុំបានប្រមូល និងទទួលបាននូវទិន្នន័យមួយចំនួនដែលទាក់ទងនឹងធនាគារ ស្ថាបនា ភីអិលស៊ី មានដូចជា៖ ប្រវត្តិនៃស្ថាប័ន ការកម្លាយខ្លួនជាធនាគារពាណិជ្ជ ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃរបស់ស្ថាប័ន ប្រភេទឥណទាន បច្ចេកវិទ្យាឌីជីថលប្រព័ន្ធគ្រប់គ្រងហានិភ័យឥណទាន តួនាទី និងភារកិច្ចរបស់ធនាគារ រចនាសម្ព័ន្ធគ្រប់គ្រង ក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងប្រតិបត្តិ និងចំណេះដឹងផ្សេងៗទៀតដែលទាក់ទងជាមួយនឹងប្រធានបទផ្ទាល់។ ជាក់ស្តែង បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះមក ក្រុមយើងខ្ញុំបានយល់ឃើញថា ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទាន គឺជាដំណើរការដ៏សំខាន់សម្រាប់ធនាគារ ក្នុងការធានាសុវត្ថិភាពនៃទុន និងស្ថិរភាពហិរញ្ញវត្ថុរបស់ខ្លួន។ ដើម្បីឱ្យការផ្តល់ឥណទានមានប្រសិទ្ធភាព និងកាត់បន្ថយហានិភ័យដែលអាចកើតឡើងធនាគារ ស្ថាបនា ភីអិលស៊ី បានអនុវត្តនីតិវិធីច្បាស់លាស់ដូចជា ការវាយតម្លៃសមត្ថភាពអតិថិជន ការបែងចែកថ្នាក់ហានិភ័យ ការវាស់វែងឥណទាន និងគោលនយោបាយសំវិធានធន។ ធនាគារបានប្រើប្រាស់ឧបករណ៍ឌីជីថល ការរៀបចំរបាយការណ៍ និងការបណ្តុះបណ្តាលបុគ្គលិក ដើម្បីឆ្លើយតបនឹងហានិភ័យដោយប្រសើរ។ ការត្រួតពិនិត្យរួមជាមួយនឹងស្ថាប័នឯករាជ្យ និងការកែសម្រួលគោលនយោបាយជាប្រចាំ ក៏ជួយធានាថាការផ្តល់ឥណទានធ្វើទៅតាមបទបញ្ញត្តិ និងមានតម្លាភាពខ្ពស់។

សរុបសេចក្តីមក ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទាន ពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់គ្រប់ស្ថាប័នធនាគារទាំងអស់ ព្រោះវាជួយបង្កើនសុវត្ថិភាពក្នុងការប្រតិបត្តិការហិរញ្ញវត្ថុ រក្សានិរន្តភាពនៃប្រាក់ចំណេញ កាត់បន្ថយហានិភ័យនៃការខាតបង់ទុន និងបង្កើននូវទំនុកចិត្តពីភាគីពាក់ព័ន្ធ។ លើសពីនេះ វាក៏ជាគ្រឹះសម្រាប់ការគ្រប់គ្រងគណនេយ្យភាព ការធ្វើផែនការរយៈពេលវែង និងការអភិវឌ្ឍន៍ទិសដៅរបស់ធនាគារ។ តាមរយៈការគ្រប់គ្រងហានិភ័យយ៉ាងជាក់លាក់ និងមានប្រសិទ្ធភាពនេះ ធនាគារអាចសម្រេចបាននូវគោលដៅអាជីវកម្ម បំពេញបេសកកម្មរបស់ខ្លួន និងធានាបាននូវស្ថិរភាពក្នុងវិស័យហិរញ្ញវត្ថុបានយ៉ាងល្អប្រសើរ។

# មាតិកា

ទំព័រ

អារម្ភកថា ........ i

រចនាសម្ព័ន្ធ ........ ii

សេចក្តីថ្លែងអំណរគុណ ........ iii

អំណះអំណាង ........ vi

សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v

មាតិកា ........ vi

ជំពូកទី១

សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាស្រាវជ្រាវ ........ ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២

១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

១.៤.១ ទំហំដែនកំណត់នៃការស្រាវជ្រាវ ........ ២

១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........ ២

១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២

១.៥.១ វិធីសាស្ត្រប្រមូលទិន្នន័យចម្បង ........ ២

១.៥.២ វិធីសាស្ត្រប្រមូលទិន្នន័យបន្ទាប់បន្សំ ........ ២

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ២

១.៦.១ ចំពោះក្រុមស្រាវជ្រាវ ........ ២

១.៦.២ ចំពោះស្ថាប័ន ........ ៣

១.៦.៣ ចំពោះសង្គម ........ ៣

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

ជំពូកទី២

ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារ

២.១ លក្ខណៈទូទៅនៃការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារ ........ ៤

២.១.១ និយមន័យធនាគារ ........ ៤

២.១.២ ប្រវត្តិរបស់ធនាគារ ........ ៤

២.១.៣ តួនាទីនៃធនាគារ ........ ៥

២.២ យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងហានិភ័យឥណទានរបស់ធនាគារ ........ ៦

២.២.១ និយមន័យឥណទាន ........ ៦

២.២.២ ប្រវត្តិរបស់ឥណទាន ........ ៦

២.២.៣ ប្រភេទនៃឥណទាន ........ ៧
២.៣ ការគ្រប់គ្រងហានិភ័យឥណទានឱ្យមានប្រសិទ្ធភាពរបស់ធនាគារ ........ ៩
២.៣.១ និយមន័យហានិភ័យ ........ ៩
២.៣.២ ប្រវត្តិរបស់ហានិភ័យ ........ ៩
២.៣.៣ ប្រភេទនៃហានិភ័យ ........ ១០

## ជំពូកទី៣

## ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារ ស្ថាបនា ភីអិលស៊ី

៣.១ ស្ថានភាពទូទៅនៃធនាគារ ស្ថាបនា ........ ១១
៣.១.១ ប្រវត្តិរបស់ធនាគារ ស្ថាបនា ........ ១១
៣.១.២ ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃរបស់ធនាគារ ស្ថាបនា ........ ១៣
ក.ចក្ខុវិស័យ ........ ១៣
ខ.បេសកកម្ម ........ ១៣
គ.គុណតម្លៃ ........ ១៣
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ចរបស់ធនាគារ ស្ថាបនា ........ ១៤
ក. រចនាសម្ព័ន្ធគ្រប់គ្រង ........ ១៤
ខ. តួនាទីក្រុមប្រឹក្សាភិបាល ........ ១៤
គ. ភារកិច្ចគណៈគ្រប់គ្រងប្រតិបត្តិ ........ ១៧
៣.២ យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងហានិភ័យឥណទានរបស់ធនាគារ ស្ថាបនា ........ ២២
៣.២.១ ការស្វែងយល់សញ្ញាណហានិភ័យឥណទាន ........ ២៤
៣.២.២ ការតាមដាន និងការចាត់ថ្នាក់ហានិភ័យឥណទាន ........ ២៤
ក. ការតាមដានហានិភ័យឥណទាន ........ ២៤
ខ. ការចាត់ថ្នាក់ហានិភ័យឥណទាន ........ ២៥
៣.២.៣ ការវិភាគ និងការវាស់វែងហានិភ័យឥណទាន ........ ២៥
៣.២.៤ ការត្រួតពិនិត្យ និងការគ្រប់គ្រងហានិភ័យឥណទាន ........ ២៦
៣.២.៥ គោលនយោបាយសំវិធានធន ........ ២៨
៣.២.៦ លក្ខខណ្ឌនៃការបង់ប្រាក់ច្បាស់លាស់ ........ ២៩
៣.២.៧ ស្វ័យប្រវត្តិកម្មប្រកបដោយលទ្ធផលលឿនរហ័ស និងច្បាស់លាស់ ........ ៣០
៣.២.៨ បច្ចេកវិទ្យាឌីជីថលឈានមុខរបស់ធនាគារ ស្ថាបនា ........ ៣១
៣.៣ ការគ្រប់គ្រងហានិភ័យឥណទានឱ្យមានប្រសិទ្ធភាពរបស់ធនាគារ ស្ថាបនា ........ ៣១
៣.៣.១ អត្ថប្រយោជន៍នៃការគ្រប់គ្រងហានិភ័យឥណទានចំពោះធនាគារ ស្ថាបនា ........ ៣៣

## ជំពូកទី៤

## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ........ ៣៦

៤.២ ការវិភាគលើចំណុចខ្សោយ ..................................................................................................... ៣៧

**ជំពូកទី៥**

**សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

៥.១ សេចក្តីសន្និដ្ឋាន ........................................................................................................... ៣៨
៥.២ ការផ្តល់អនុសាសន៍ ..................................................................................................... ៣៨-៣៩
**ឯកសារយោង**
**ឧបសម្ព័ន**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

នៅពេលបច្ចុប្បន្ននេះមានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុជាច្រើន កំពុងធ្វើការបម្រើសេវាកម្មជូនដល់អតិថិជន ហើយអតិថិជនវិញមុននឹងធ្វើការសម្រេចចិត្តប្រើប្រាស់នូវសេវាកម្មរបស់ស្ថាប័នណាមួយ គឺពួកគេតែងតែស្វែងរកធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុណាដែលបម្រើសេវាកម្មល្អ និងអត្ថប្រយោជន៍ផ្សេងៗទៀតដែលពួកគេនឹងទទួលបានពីស្ថាប័ននោះ។ ហេតុដូចនេះហើយ ទើបស្ថាប័នហិរញ្ញវត្ថុបានបង្កើតឱ្យមានការចូលចែកយកព័ត៌មានបំណុលរបស់អតិថិជននៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានឥណទានកម្ពុជា ដើម្បីជៀសវាងនូវហានិភ័យដែលអាចកើតមានឡើង ការក្លែងបន្លំ និងព័ត៌មានមិនពិតណាមួយ ដើម្បីជាជំនួយក្នុងការសម្រេចចិត្តផ្តល់ឥណទានដល់អតិថិជន។

ធនាគារ ស្ថាបនា ភីអិលសុី បានលើកកម្ពស់ស្ថិរភាពហិរញ្ញវត្ថុឱ្យកាន់តែប្រសើរឡើង ដោយបានផ្តល់នូវទិន្នន័យបានទាន់ពេលវេលា និងជាក់លាក់ទៅកាន់អតិថិជន និងស្ថាប័នហិរញ្ញវត្ថុដែលជាសមាជិកក្នុងការជួយដល់ការគ្រប់គ្រងទិដ្ឋភាពហិរញ្ញវត្ថុនៃអាជីវកម្មរបស់ពួកគេ ដោយអនុញ្ញាតឱ្យអាជីវកម្មទាំងមូលអាចជៀសវាង និងការពារការក្លែងបន្លំអត្តសញ្ញាណ និងធ្វើការសម្រេចចិត្តបានលឿន។ ធនាគារ ស្ថាបនា ភីអិលសុី ក៏បានផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋគ្រប់រូប ក្នុងការត្រួតពិនិត្យមើលរបាយការណ៍ឥណទានផ្ទាល់ខ្លួនដើម្បីធ្វើការធានាឱ្យបានថាពួកគាត់អាចស្វែងរក និងទទួលបាននូវប្រាក់កម្ចី និងការការពារខ្លួនពីការលួចបន្លំអត្តសញ្ញាណផងដែរ។

ដោយមើលឃើញពីសារៈសំខាន់ជាច្រើនក្នុងការគ្រប់គ្រងហានិភ័យឥណទាន និងដើម្បីធ្វើការសិក្សាស្រាវជ្រាវឱ្យកាន់តែច្បាស់លើសេវាកម្មនេះ ទើបក្រុមយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទ ដែលទាក់ទងទៅនឹង **«ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារ ស្ថាបនា ភីអិលសុី»** មកធ្វើការសិក្សាស្រាវជ្រាវ ដើម្បីចងក្រងជារបាយការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនាពេលនេះ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទខាងលើនេះ គឺពិតជាមានសារៈសំខាន់សម្រាប់ការប្រើប្រាស់ទូទៅក្នុងវិស័យសេវាកម្មរបស់ធនាគារ និងជាពិសេសជួយឱ្យប្រជាពលរដ្ឋបានយល់ដឹងកាន់តែច្បាស់ពីការប្រើប្រាស់ឥណទានឱ្យកាន់តែមានភាពងាយស្រួល។ បច្ចុប្បន្នវិស័យធនាគារនៅកម្ពុជាមានការរីកចម្រើន និងមានការអភិវឌ្ឍន៍ច្រើនជាលំដាប់ ហើយក៏ជាផ្នែកមួយដែលបានចូលរួមជាចំណែកមួយជាមួយរាជរដ្ឋាភិបាលទៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិផងដែរ។ ដើម្បីបានយល់ដឹងបន្ថែម និងឱ្យកាន់តែច្បាស់ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី **«ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារ ស្ថាបនា ភីអិលសុី»** ត្រូវបានកំណត់ជាសំណួរមួយចំនួនដូចខាងក្រោម៖

១. តើធនាគារមានយុទ្ធសាស្ត្រដូចម្តេចក្នុងការគ្រប់គ្រងហានិភ័យឥណទាន?

២. តើការគ្រប់គ្រងហានិភ័យឥណទានឱ្យមានប្រសិទ្ធភាព ផ្តល់អត្ថប្រយោជន៍អ្វីខ្លះដល់ធនាគារ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

- ស្វែងយល់ពីយុទ្ធសាស្ត្រដើម្បីកាត់បន្ថយហានិភ័យឥណទានរបស់ធនាគារ។
- ស្វែងយល់ពីអត្ថប្រយោជន៍នៃការគ្រប់គ្រងហានិភ័យឥណទានរបស់ធនាគារ។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់នៃការស្រាវជ្រាវ

ដោយសារពេលវេលាមានកំណត់ ហើយទិន្នន័យនៃការគ្រប់គ្រងហានិភ័យឥណទានរបស់ធនាគារ ស្ថាបនា មានច្រើនហេតុដូចនេះ ក្រុមយើងខ្ញុំសូមលើកយកតែទិន្នន័យដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យឥណទានរបស់ធនាគារ ស្ថាបនា ដែលមានអាសយដ្ឋាន ស្ថិតនៅមហាវិថីព្រះនរោត្តម កែងផ្លូវលេខ១៧២ និងផ្លូវលេខ១៧៤ ភូមិភូមិ១៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវមួយនេះ គឺយើងបានធ្វើការសិក្សាស្រាវជ្រាវទៅលើការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារ ស្ថាបនា នៅក្នុងឆ្នាំ២០២៤ ដែលមានអាសយដ្ឋាននៅផ្លូវព្រះនរោត្តម។ ចំពោះសេវាកម្មនេះ យើងនឹងធ្វើការសិក្សាទៅលើរបាយការណ៍ឥណទានផ្ទាល់ខ្លួន របៀបស្នើសុំរបាយការណ៍ឥណទាន អត្ថប្រយោជន៍របាយការណ៍ឥណទានអតិថិជន សេវាវិភាគឥណទាន សេវាតាមដានឥណទាន សេវាត្រួតពិនិត្យឥណទាន និងដំណោះស្រាយទិន្នន័យតាមតម្រូវការនាពេលបច្ចុប្បន្ន។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រស្រាវជ្រាវដែលក្រុមយើងខ្ញុំបានយកមកប្រើប្រាស់ក្នុងការសិក្សានេះ គឺជាវិធីសាស្ត្របែបគុណវិស័យ ដោយទិន្នន័យដែលប្រមូលបានមកគឺតាមរយៈការស្រាវជ្រាវពីគេហទំព័រ និងបណ្ណាល័យសាកលវិទ្យាល័យវ៉ាន់ដា ។ វិធីសាស្ត្រប្រមូលទិន្នន័យនេះត្រូវបានបែងចែកចេញជា២ប្រភេទ ដើម្បីកំណត់ឱ្យបានកាន់ច្បាស់អំពីគោលបំណងនៃការស្រាវជ្រាវ។

បកស្រាយតាមសំណួរទី១៖ ការសិក្សាស្រាវជ្រាវនេះ ត្រូវបានរៀបចំឡើងដោយប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យដូចជា ការវិភាគទៅលើកម្រងឯកសារដែលពាក់ព័ន្ធនឹងប្រធានបទ ការស្រាវជ្រាវតាមរយៈគេហទំព័រ (www.sathapana.com) ជាពិសេសរបាយការណ៍ និងទិន្នន័យសំខាន់ៗរបស់ធនាគារ ស្ថាបនា និងការសិក្សាព័ត៌មានបន្ថែមពីបណ្ណាល័យសាកលវិទ្យាល័យវ៉ាន់ដា ការដកស្រង់ចេញពីមេរៀន និងកម្រងឯកសារផ្សេងៗដែលទាក់ទងនឹងប្រធានបទ និងការសាកសួរបន្ថែមពីសាស្ត្រាចារ្យណែនាំ។

បកស្រាយតាមសំណួរទី២៖ ការសិក្សាស្រាវជ្រាវនេះ គឺដូចគ្នាទៅនឹងការបកស្រាយតាមសំណួរទី១ ត្រូវបានរៀបចំឡើងដោយប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យដូចជា ការវិភាគទៅលើកម្រងឯកសារដែលពាក់ព័ន្ធនឹងប្រធានបទ ការស្រាវជ្រាវតាមរយៈគេហទំព័រ (www.sathapana.com) ជាពិសេសរបាយការណ៍ និងទិន្នន័យសំខាន់ៗរបស់ធនាគារ ស្ថាបនា ការសិក្សាព័ត៌មានបន្ថែមពីបណ្ណាល័យសាកលវិទ្យាល័យវ៉ាន់ដា ការដកស្រង់ចេញពីមេរៀន និងកម្រងឯកសារផ្សេងៗដែលទាក់ទងនឹងប្រធានបទ និងការសាកសួរបន្ថែមពីសាស្ត្រាចារ្យណែនាំ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះបានផ្តល់សារៈសំខាន់ និងអត្ថប្រយោជន៍ជាច្រើនដូចខាងក្រោម៖

**១.៦.១ ចំពោះក្រុមស្រាវជ្រាវ**

- ជួយបង្កើននូវចំណេះដឹង ជំនាញសមត្ថភាពផ្សេងៗដោយបានផ្សាភ្ជាប់ជាមួយទ្រឹស្តី និងការអនុវត្តជាក់ស្តែង។
- យល់ដឹងកាន់តែច្បាស់បន្ថែមអំពីការគ្រប់គ្រងហានិភ័យឥណទានឱ្យមានប្រសិទ្ធភាពរបស់ធនាគារ ស្ថាបនា។
- យល់ដឹងអំពីយុទ្ធសាស្ត្រ គោលនយោបាយ និងនីតិវិធីក្នុងការគ្រប់គ្រងហានិភ័យឥណទានរបស់ធនាគារ ស្ថាបនា ដែលចំណេះដឹងទាំងនេះសុទ្ធតែជាមូលដ្ឋានគ្រឹះសម្រាប់ការប្រើប្រាស់ទូទៅ និងការស្វែងរកការងារ។
- ចេះធ្វើការងារជាក្រុម ពិភាក្សា និងសម្របសម្រួលដោះស្រាយបញ្ហាការងារក្នុងក្រុម។
- ពង្រឹងសមត្ថភាពលើទំនួលខុសត្រូវលើកិច្ចការស្រាវជ្រាវ។

**១.៦.២ ចំពោះស្ថាប័ន**

- បង្កើនទំនុកចិត្ត និងភាពជឿជាក់ពីអតិថិជនមកលើស្ថាប័ន។
- ផ្សព្វផ្សាយពីវិសាលភាព សេវាកម្ម និងកេរ្តិ៍ឈ្មោះរបស់ធនាគារ។
- សិក្សាស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយដើម្បីយកទៅកែលម្អ និងអភិវឌ្ឍន៍។

**១.៦.៣ ចំពោះសង្គម**

- បានជួយផ្សព្វផ្សាយពីចំណេះដឹងទៅដល់និស្សិតជំនាន់ក្រោយ។
- ចងក្រងជាឯកសារសម្រាប់ឱ្យសិស្សប្អូនយកទៅធ្វើការសិក្សាស្រាវជ្រាវបន្ត។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវត្រូវចែកចេញជា៥ជំពូកដូចខាងក្រោម៖

**ជំពូកទី១ ៖ សេចក្តីផ្តើម** បង្ហាញពីលំនាំនៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវ និងសារៈសំខាន់នៃការស្រាវជ្រាវ។

**ជំពូកទី២ ៖ រំលឹកទ្រឹស្តី** លើកឡើងពីនិយមន័យ ទ្រឹស្តីពាក់ព័ន្ធ ទស្សនទាន ប្រវត្តិនៃការគ្រប់គ្រងហានិភ័យឥណទានរបស់ធនាគារ សំដីរបស់អ្នកប្រាជ្ញ និងបទពិសោធន៍ផ្សេងៗទៀត។

**ជំពូកទី៣ ៖ លទ្ធផលនៃការស្រាវជ្រាវ** លើកឡើងពីស្ថានភាពទូទៅរបស់ធនាគារ ស្ថាបនា ដូចជាប្រវត្តិរបស់ធនាគារ ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច យុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ ការវិភាគ និងវាស់វែងហានិភ័យ ការត្រួតពិនិត្យ និងគ្រប់គ្រងហានិភ័យ បច្ចេកវិទ្យាឌីជីថល និងការគ្រប់គ្រងហានិភ័យឥណទានឱ្យមានប្រសិទ្ធភាពរបស់ធនាគារ ស្ថាបនា។

**ជំពូកទី៤ ៖ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ** វិភាគទៅលើចំណុចទាំងអស់ ដែលបានអនុវត្តជាក់ស្តែង (គឺគ្រប់ចំណុចទាំងអស់ដែលមាននៅក្នុងជំពូកទី៣) គឺក្នុងគោលបំណងវិភាគឱ្យឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយរបស់ធនាគារ ស្ថាបនា ដើម្បីយកទៅធ្វើការកែលម្អបន្ថែម។

**ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍** ធ្វើការសិន្និដ្ឋានទៅលើគ្រប់ចំណុចខ្លាំង និងចំណុចខ្សោយ ដើម្បីផ្តល់ជាយោបល់ និងអនុសាសន៍ទៅលើចំណុចដែលត្រូវកែលម្អឱ្យប្រសើរឡើង។

# ជំពូកទី២

# ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារ

## ២.១ លក្ខណៈទូទៅនៃការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារ

### ២.១.១ និយមន័យធនាគារ

ធនាគារត្រូវបានគេកំណត់និយមន័យដូចខាងក្រោមៈ

- ធនាគារ គឺជាស្ថាប័នហិរញ្ញវត្ថុមួយ ដែលទទួលប្រាក់បញ្ញើ ដើម្បីដកតាមតម្រូវការ ( ដូចជា សរសេរមូលប្បទានបត្រ ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច) ហើយនឹងផ្តល់ឥណទានទៅឱ្យសាធារណជន និងអាជីវកម្ម (ផ្តល់ឥណទានដល់អាជីវកម្មឯកជន ដើម្បីពង្រីកសន្និធិរបស់ទំនិញនៅក្នុងហាងរបស់ពួកគេ ឬដើម្បីទិញសម្ភារបរិក្ខារថ្មី)[1]។
- ធនាគារ គឺជាស្ថាប័ន ឬគ្រឹះស្ថានទទួលប្រាក់បញ្ញើ ឬបណ្តាក់ទុនមួយជាបណ្តាញប្រមូលប្រាក់សន្សំដោយឥតប្រើប្រាស់ ឬនៅទំនេរក្នុងសេដ្ឋកិច្ចយកទៅចែកចាយទៅតាមគ្រប់វិស័យសេដ្ឋកិច្ចតាមការផ្តល់ឥណទាន ដើម្បីជួយលើកស្ទួយសកម្មភាព និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម[2]។
- ធនាគារ គឺជាស្ថាប័នហិរញ្ញវត្ថុ ដែលធ្វើប្រតិបត្តិការផ្តល់ឱ្យនូវសេវាកម្មហិរញ្ញវត្ថុច្រើនប្រភេទដូចជា ទទួលប្រាក់បញ្ញើគ្មានមុខសញ្ញាប្រើប្រាស់ និងប្រាក់សន្សំពីសាធារណជន ផ្តល់ឥណទានឱ្យឯកត្តជន និងក្រុមហ៊ុនអាជីវកម្មជំនួញដោយយកការប្រាក់ព្រមទាំងផ្តល់សេវាទៅលើការងារទូទាត់ និងធ្វើការវិនិយោគក្រោមរូបភាពជាសញ្ញាប័ណ្ណ និងមូលបត្រមានតម្លៃ ដើម្បីស្វែងរកប្រាក់ចំណេញសម្រាប់ម្ចាស់ក្រុមហ៊ុន[3]។
- ធនាគារ គឺជាគ្រឹះស្ថានសេវាហិរញ្ញវត្ថុមួយដែលបានផលិត និងលក់មូលធនជាសាធារណៈប្រកបទៅដោយវិជ្ជាជីវៈ និងបានដើរតួយ៉ាងសំខាន់នៅក្នុងផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្ម។

### ២.១.២ ប្រវត្តិរបស់ធនាគារ

ប្រវត្តិនៃធនាគារ បានចាប់ផ្តើមជាមួយនឹងធនាគារគំរូដំបូង ពេលគឺពាណិជ្ជករនៃពិភពលោកដែលបានផ្តល់ប្រាក់កម្ចីគ្រាប់ធញ្ញជាតិដល់កសិករ និងពាណិជ្ជករដែលបានដឹកជញ្ជូនទំនិញរវាងទីក្រុង។ នេះគឺប្រហែលឆ្នាំ ២០០០ មុន គ.ស. នៅអាស៊ីរី ឥណ្ឌា និងស៊ូមែរ។ ក្រោយមកនៅសម័យអាណាចក្ររ៉ូម និងក្រិកបុរាណ អ្នកផ្តល់ប្រាក់កម្ចីដែលមានមូលដ្ឋាននៅប្រាសាទនានាបានផ្តល់ប្រាក់កម្ចី ខណៈពេលដែលទទួលយកប្រាក់បញ្ញើ និងអនុវត្តការផ្លាស់ប្តូរប្រាក់។ បុរាណវិទ្យាពីសម័យកាលនោះនៅក្នុងប្រទេសចិន និងឥណ្ឌាបុរាណក៏បានបង្ហាញភស្តុតាងនៃការខ្ចីប្រាក់ដែរ។

អ្នកប្រាជ្ញជាច្រើនបានតាមដានឫសគល់ប្រវត្តិសាស្ត្រនៃប្រព័ន្ធធនាគារទំនើប ដល់មជ្ឈិមសម័យ និងសម័យកាល Renaissance ប្រទេសអ៊ីតាលី ជាពិសេសនៅទីក្រុងដូចជា Florence , Venice និង Genoa។ គ្រួសារ

[1] WordPress. Khem Sarith. (2016, October 04). *Banking Definitions*. Retrieved from https://khemsarith.wordpress.com (Accessed March, 03 2025).

[2] Facebook page. HRU. (2017, January 31). *និយមន័យធនាគារ*. Retrieved from https://www.facebook.com/share/p/1ACXBDpRTy/ (Accessed March, 03 2025).

[3] ACADEMIA. Ory Kalip. (2023, April 29). *និយមន័យធនាគារ*. Retrieved from https://www.academia.edu/31513027/ (Accessed March, 03 2025).

Bardi និង Peruzzi បានគ្រប់គ្រងវិស័យធនាគារនៅ Florence សតវត្សទី១៤ ដោយបានបង្កើតសាខានៅក្នុងតំបន់ជាច្រើនទៀតនៃទ្វីបអឺរ៉ុប។ ធនាគារដ៏ល្បីល្បាញបំផុតរបស់អ៊ីតាលីគឺ ធនាគារ Medici ដែលបង្កើតឡើងដោយ Giovanni Medici ក្នុងឆ្នាំ១៣៩៧។ ធនាគារចាស់ជាងគេបំផុតនៅលើលោក ដែលនៅតែបម្រើសេវាកម្ម គឺ Banca Monte dei Paschi di Siena ដែលមានទីស្នាក់ការកណ្តាលនៅ Siena ប្រទេសអ៊ីតាលី ដែលបានបើកដំណើរការតាំងពីឆ្នាំ១៤៧២។ រហូតដល់ចុងឆ្នាំ២០០២ ធនាគារចាស់ជាងគេបំផុតដែលនៅតែបើកដំណើរការគឺ Banco di Napoli ដែលមានទីស្នាក់ការនៅទីក្រុង Naples ប្រទេសអ៊ីតាលី ដែលបានដំណើរការតាំងពីឆ្នាំ១៤៦៣។

ការអភិវឌ្ឍន៍នៃធនាគារបានរីករាលដាលពីភាគខាងជើងប្រទេសអ៊ីតាលី ទៅ Holy Roman Empire ហើយនៅសតវត្សទី១៥ និងទី១៦ ទៅកាន់អឺរ៉ុបខាងជើង។ នេះត្រូវបានបន្តដោយការច្នៃប្រឌិតសំខាន់ៗមួយចំនួនដែលបានកើតឡើងនៅទីក្រុង Amsterdam ក្នុងអំឡុងសាធារណរដ្ឋហូឡង់ក្នុងសតវត្សទី១៧ និងទីក្រុងឡុងដ៍ចាប់តាំងពីសតវត្សទី១៨។ ក្នុងកំឡុងសតវត្សទី២០ ការអភិវឌ្ឍន៍នៃផ្នែកទូរគមនាគមន៍ និងកុំព្យូទ័របានបណ្តាលឱ្យមានការផ្លាស់ប្តូរយ៉ាងសំខាន់ចំពោះប្រតិបត្តិការរបស់ធនាគារ ហើយអនុញ្ញាតឱ្យធនាគារកើនឡើងយ៉ាងខ្លាំងនូវទំហំ និងការរីករាលដាលភូមិសាស្រ្ត។ វិបត្តិហិរញ្ញវត្ថុឆ្នាំ២០០៧-២០០៨ ដែលបាននាំឱ្យធនាគារមានការបរាជ័យជាច្រើន រួមទាំងធនាគារធំៗមួយចំនួននៅលើពិភពលោក និងបានបង្កឱ្យមានការជជែកវែកញែកជាច្រើនអំពីបទប្បញ្ញត្តិធនាគារ[4]។

### ២.១.៣ តួនាទីនៃធនាគារ

ធនាគារ គឺជាគ្រឹះស្ថានសេវាហិរញ្ញវត្ថុ ដែលផលិត និងលក់មូលធនជាសាធារណៈប្រកបទៅដោយវិជ្ជាជីវៈ និងបានដើរតួយ៉ាងសំខាន់នៅក្នុងផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្ម។

- ➢ ធនាគារមានតួនាទីសំខាន់ៗដូចខាងក្រោម៖
  - តួនាទីអន្តរការី៖ បង្វែរការសន្សំជាសាច់ប្រាក់ពីសាធារណជន ឱ្យទៅជាឥណទានសម្រាប់សហគ្រាសពាណិជ្ជកម្ម និងសហគ្រាសផ្សេងទៀត ដើម្បីវិនិយោគនៅក្នុងការសាងសង់ សម្ភារបរិក្ខារ ឧបករណ៍ប្រើប្រាស់ និងសន្និធិ។ល។
  - តួនាទីទូទាត់៖ គឺជាការអនុវត្តនូវការទូទាត់ផ្សេងៗសម្រាប់ទំនិញ និងសេវាកម្មក្នុងនាមជាអតិថិជនរបស់ពួកគេ ដូចជាការចេញ និងការទូទាត់មូលប្បទានបត្រ ការផ្ទេរសាច់ប្រាក់ ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិច និងការដកប្រាក់តាមប្រព័ន្ធម៉ាស៊ីនទំនើបATM។
  - តួនាទីជាអ្នកធានា៖ ឈរនៅពីខាងក្រោយអតិថិជនរបស់គេ ដើម្បីធ្វើការទូទាត់ ឬសងនូវបំណុលរបស់អតិថិជន នៅពេលដែលអតិថិជនទាំងនោះ មិនអាចសងត្រឡប់ឱ្យទៅម្ចាស់បំណុលរបស់គេក្នុងកាលៈទេសៈចៃដន្យ ដោយធនាគារគ្រាន់តែចេញនូវលិខិតឥណទាន ដើម្បីបង្ហាញនូវទឹកប្រាក់នៅក្នុងគណនីអតិថិជនរបស់គេ។
  - តួនាទីគ្រប់គ្រងហានិភ័យ៖ ជួយទៅដល់អតិថិជនទាំងអស់ ក្នុងការរៀបចំនូវការគ្រប់គ្រងប្រតិបត្តិការហិរញ្ញវត្ថុ សម្រាប់ការកើតមានហានិភ័យនៃការបាត់បង់ទ្រព្យសម្បត្តិ និងជីវិតមនុស្ស។

[4] WIKIPEDIA. (2005, September 13). *History of banking*. Retrieved from https://en.m.wikipedia.org/wiki/History_of_banking (Accessed March, 05 2025).

- តួនាទីជាទីប្រឹក្សាលើការសន្សំ៖ ជួយដល់អតិថិជនលើការផ្តល់ការប្រឹក្សាយោបល់សម្រាប់គោលដៅរយៈពេលវែង ក្នុងការធ្វើឱ្យមានជីវិតល្អប្រសើរ ដូចជាគម្រោងសាងសង់ ឬគម្រោងអាជីវកម្មផ្សេងៗ ដើម្បីជៀសវាងទុកប្រាក់សន្សំមិនចរាចរនៅលើទីផ្សារ។
- តួនាទីជាអ្នកថែរក្សាវត្ថុមានតម្លៃ៖ ទុកដាក់នូវវត្ថុមានតម្លៃរបស់អតិថិជន និងវាយតម្លៃប្រកបទៅដោយសុក្រិតភាពនូវតម្លៃរបស់ទ្រព្យសកម្ម ឬទ្រព្យសម្បត្តិដែលធ្វើប្រតិបត្តិការនៅលើទីផ្សារ។
- តួនាទីជាភ្នាក់ងារ៖ ក្នុងនាមជាអ្នកតំណាងឱ្យអតិថិជន ដើម្បីការចាត់ចែង និងការពារនូវទ្រព្យសកម្មរបស់ពួកគេ ឬចេញ និងរំលស់ ឬទទួលទូទាត់លក់ចេញ និងទិញចូលនូវប័ណ្ណភាគហ៊ុន។ ជាធម្មតាសកម្មភាពទាំងនេះត្រូវបានផ្តល់ឱ្យដោយនាយកដ្ឋានសច្ចភាពរបស់ធនាគារ។
- តួនាទីអ្នកអនុវត្តគោលនយោបាយ៖ ធ្វើប្រតិបត្តិការស្របតាមនូវគោលនយោបាយរបស់រដ្ឋាភិបាលក្នុងគោលបំណងឱ្យមានកំណើនសេដ្ឋកិច្ច និងឈានទៅដល់គោលដៅដែលសង្គមចង់បាន។

## ២.២ យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងហានិភ័យឥណទានរបស់ធនាគារ

### ២.២.១ និយមន័យឥណទាន

ឥណទានត្រូវបានគេកំណត់និយមន័យជាច្រើនមានដូចនៅខាងក្រោម៖

- ឥណទាន (Credit) គឺជាការឱ្យខ្ចីប្រាក់ដែលមានចងជាកិច្ចសន្យាត្រឹមត្រូវ ហើយអ្នកខ្ចីប្រាក់ត្រូវមានកាតព្វកិច្ចប្រើប្រាស់ប្រាក់កម្ចីឱ្យបានស្របច្បាប់ និងសងត្រឡប់មកវិញនូវប្រាក់ដើម ការប្រាក់ និងបន្ទុកហិរញ្ញវត្ថុផ្សេងៗទៀតដែលមានចែងក្នុងកិច្ចសន្យាឱ្យបានទៀងទាត់។
- ឥណទាន (Credit) គឺជាការផ្តល់នូវចលនទ្រព្យ ឬអចលទ្រព្យ ឱ្យទៅកាន់អ្នកមានតម្រូវការលើទ្រព្យទាំងនោះ ដោយតម្រូវឱ្យសងវិញតាមលក្ខខណ្ឌមួយច្បាស់លាស់។
- ឥណទាន (Credit) គឺជាការឱ្យអតិថិជនខ្ចីប្រាក់ ដើម្បីបំពេញសេចក្តីត្រូវការផ្សេងៗ ហើយអតិថិជនត្រូវមានកាតព្វកិច្ចសងត្រឡប់មកវិញទាំងប្រាក់ដើម ការប្រាក់ និងបន្ទុកហិរញ្ញវត្ថុផ្សេងៗទៀត។
- ឥណទាន (Credit) គឺជាការសន្យាសងនៅពេលអនាគត ក្នុងគោលបំណងដើម្បីទិញជំពាក់ ឬសុំខ្ចីនៅពេលបច្ចុប្បន្ន។
- ឥណទាន (Credit) គឺជាមធ្យោបាយដោះដូរជាមួយនឹងការទទួលយកដោយមានដែនកំណត់[5]។

### ២.២.២ ប្រវត្តិរបស់ឥណទាន

ឥណទានមានប្រវត្តិកាលយូរមកហើយដែលភ្ជាប់ជាមួយនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម។ ប្រព័ន្ធឥណទានត្រូវបានគេគ្រប់គ្រង និងប្រើប្រាស់តាំងពីសម័យបុរាណដូចជា នៅស៊ុមេរៀ (Sumeria), បាប៊ីឡូន និងអេហ្ស៊ីប។ Michael Hudson (2004) បញ្ជាក់ថា ប្រព័ន្ធសេដ្ឋកិច្ចដំបូងៗនៅមេសូប៉ូតាមៀបានដើរដោយប្រព័ន្ធបំណុល និងឥណទាន ជាជម្រើសសំខាន់ជាងការទាមទារប្តូរផលិតផលផ្ទាល់ (barter system)។

កិច្ចព្រមព្រៀងឥណទានដំបូងៗ ត្រូវបានកត់ត្រានៅលើថេបដីក្នុងច្បាប់ Hammurabi នៅប្រទេសបាប៊ីឡូន ប្រហែលឆ្នាំ១៧៥៤ មុនគ្រិស្តកាល។ ច្បាប់នេះបានកំណត់អត្រាការប្រាក់ ការទូទាត់បំណុល និងសិទ្ធិរបស់អ្នកខ្ចី និងអ្នកឱ្យខ្ចី (Nemet-Nejat, 1998)។

---

[5] CRID. (2011, August 01-12). *Credit Management*. Retrieved from http://ocsrp.blogspot.com/2016/05/blog-post_78.html?m=1 (Accessed March, 05 2025).

នៅក្នុងសតវត្សទី១៩ និងទី២០ ប្រព័ន្ធឥណទានទាន់សម័យបានកើតឡើងជាមួយនឹងកំណើននៃធនាគារផ្ទាល់ខ្លួន ក្រុមហ៊ុនហិរញ្ញវត្ថុ និងកាតឥណទាន។ វាជួយឱ្យប្រជាជនមានឱកាសចូលរួមដំណើរការទុនសម្រាប់វិនិយោគ ការប្រើប្រាស់ និងអភិវឌ្ឍន៍ជីវភាព[6]។

**២.៣.៣ ប្រភេទនៃឥណទាន**

មុខងារផ្តល់ឥណទាន (Credit Function) គឺជាមុខងារដ៏សំខាន់របស់ធនាគារ ដែលអាចឱ្យធនាគាររកប្រាក់ចំណេញបានយ៉ាងខ្ពស់តាមរយៈចំណូលការប្រាក់ពីសកម្មភាពនៃការផ្តល់ឥណទាន និងមានកម្ចីគ្រប់ប្រភេទរបស់ខ្លួនទៅឱ្យអតិថិជន។ ជាទូទៅឥណទានមានច្រើនប្រភេទដូចជា៖

**១. កម្ចីសម្រាប់អ្នកប្រើប្រាស់ (Consumer Loan)** ត្រូវបានគេប្រើប្រាស់អស់ជាច្រើនទសវត្សមកហើយ។ អ្នកប្រើប្រាស់ចង់បាន ឬត្រូវការទិញទំនិញគ្រប់ប្រភេទ ជាមួយការសន្យាសងដោយផ្តល់ចំណូលរបស់ពួកគេនាពេលអនាគត។ កម្ចីនេះបង្កលក្ខណៈងាយស្រួលជាច្រើន ដល់ការទិញគ្រឿងប្រដាប់ប្រដាប្រណិតជាច្រើនបែបសេវាកម្ម និងមុខទំនិញផ្សេងទៀតដែលត្រូវការ។

- ➢ កម្ចីនេះចែកចេញជា ៣ប្រភេទគឺ៖
- កម្ចីរាយ (Retail Loan) គឺជាប្រភេទកម្ចីមួយ ដែលអ្នកប្រើប្រាស់ជាច្រើនប្រើប្រាស់ដើម្បីទិញនូវទំនិញសម្រេច និងសេវាកម្មដោយផ្ទាល់ពីអ្នកលក់ ដោយប្រើកម្ចីវិល កិច្ចសន្យាសងរំលស់ ឬកម្ចីសេវា។ អ្នកលក់ទំនិញអាចទទួលយកបាន គឺការរង់ចាំសំណងពីអ្នកទិញសងនៅពេលអនាគត។
- កម្ចីសាច់ប្រាក់ (Cash Loan) គឺជាប្រភេទកម្ចីមួយ ដែលអ្នកខ្ចីទទួលបានមូលនិធិពីអ្នកផ្តល់កម្ចីដោះដូរជាមួយការចុះកិច្ចព្រមព្រៀងសងមូលនិធិនៅពេលណាមួយតាមកាលកំណត់។ ជាទូទៅមានការប្រាក់ ឬបន្ទុកហិរញ្ញវត្ថុ។ មូលនិធិដែលបានខ្ចីអាចយកប្រើសម្រាប់សម្គាល់បំណងផ្សេងៗ ដូចជាវិស្សមកាល អាពាហ៍ពិពាហ៍ កិច្ចការបន្ទាន់ និងការទិញទំនិញចាំបាច់ដទៃទៀត។
- កម្ចីអចលនវត្ថុ (Real Estate Loan) គឺជាប្រភេទកម្ចីសម្រាប់អ្នកប្រើប្រាស់ ដែលពាក់ព័ន្ធជាមួយអ្នកខ្ចីមូលនិធិខ្ចីកម្ចីដោយមានអចលនទ្រព្យជានា ឬដាក់បញ្ចាំ។ អ្នកខ្ចីពាក់ព័ន្ធរបស់បញ្ចាំ (និក្ខេប) (Mortgage Loan) ជាបំណុលជានាដោយអចលនវត្ថុ ដើម្បីទិញផ្ទះសម្រាប់គ្រួសារ។ កម្ចីនេះពេញនិយមដោយសារច្បាប់ស្តីពីពន្ធមិនឱ្យបង់ពន្ធលើការប្រាក់ ។

**២. កម្ចីអាជីវកម្ម (Business Loan)** គឺជាកម្ចីមួយប្រភេទសម្រាប់ផ្តល់ជូនអតិថិជន ដែលមានលក្ខណៈសម្បត្តិសមស្របតាមលក្ខណៈវិនិច្ឆ័យ ដើម្បីមានលទ្ធភាពពង្រីកមធ្យោបាយ បង្កើនប្រាក់ចំណូលនៅក្នុងសកម្មភាពនានា ប្រតិបត្តិការ ធុរកិច្ចគ្រប់ប្រភេទរួមមាន សិប្បកម្ម ផលិតកម្ម ពាណិជ្ជកម្ម សេវាកម្ម និងទេសចរណ៍។ល។

- ➢ កម្ចីនេះចែកចេញជា ២ប្រភេទគឺ៖
- កម្ចីសម្រាប់លក់៖ គឺជាកម្ចីសម្រាប់ទិញទំនិញ វត្ថុធាតុដើម និងសារពើភណ្ឌសម្រាប់ធ្វើការលក់បន្ត។ ជាទូទៅអតិថិជនទទួលបានទំនិញមុន ហើយយល់ព្រមទូទាត់តាមលក្ខខណ្ឌលក់ និងអនុញ្ញាតឱ្យអតិថិជនទូទាត់តាមពេលកំណត់។

[6] Nemet-Nejat, K. R. (1998). *Daily life in ancient Mesopotamia*. Westport, CT: Greenwood Publishing Group.

- កម្ចីមូលនិធិហិរញ្ញវត្ថុសម្រាប់ប្រតិបត្តិការៈ គឺជាកម្ចីមួយដែលមានតម្រូវការចាំបាច់ ក្នុងការចាប់ផ្តើមពង្រីកអាជីវកម្ម។

**៣. កម្ចីកសិកម្ម (Agricultural loan)** គឺជាកម្ចីមួយប្រភេទ ដែលបានបង្កើតឡើងសម្រាប់ផ្តល់ជូនឱ្យសាធារណជន ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌវិនិច្ឆ័យ ក្នុងគោលបំណងយកទៅអភិវឌ្ឍន៍ក្នុងវិស័យកសិកម្មជាលក្ខណៈគ្រួសារ ដែលមានដីកសិកម្មស្រាប់ជាសិទ្ធិផ្ទាល់ខ្លួន ដើម្បីទិញដីកសិកម្មពង្រីក គ្រឿងចក្រ កសិកម្មគ្រប់ប្រភេទ ពូជដីកសិកម្ម ថ្នាំកសិកម្ម ឬទូទាត់ថ្លៃពលកម្មផលិតកសិកម្ម ឬថ្លៃពលកម្មប្រមូលកសិផល។

**៤. កម្ចីសាធារណៈ (Government loan)** គឺជាកម្ចីមួយប្រភេទ ដែលធនាគារផ្តល់ជូនរាជរដ្ឋាភិបាល តាមរយៈការទិញបណ្ណបំណុលដែលរដ្ឋាភិបាលបានបោះផ្សាយ។

➢ ការចាត់ថ្នាក់របស់ឥណទានបែងចែកជា ២ថ្នាក់គឺៈ

- ឥណទានឯកជន គឺជាឥណទានមួយប្រភេទ ដែលធនាគារធ្វើការផ្តល់ជូនទៅឱ្យបុគ្គល ឬស្ថាប័នទាំងឡាយណាដែលស្ថិតនៅក្នុងវិស័យឯកជន សម្រាប់យកទៅប្រើប្រាស់ ឬវិនិយោគផ្សេងៗ។

ឥណទានឯកជនបែកចេញជា ២ប្រភេទគឺៈ

☞ ឥណទានអ្នកប្រើប្រាស់ចែកចេញជា ៣គឺៈ

- ឥណទានរាយ
- ឥណទានសាច់ប្រាក់
- ឥណទានអចលនទ្រព្យ

☞ ឥណទានអាជីវកម្មចែកចេញជា ២គឺៈ

- ឥណទានសម្រាប់ទិញ-លក់ទំនិញ
- ឥណទានមូលធនហិរញ្ញវត្ថុ

- ឥណទានសាធារណៈ គឺជាឥណទានមួយប្រភេទ ដែលធនាគារផ្តល់ជូនរដ្ឋាភិបាលសម្រាប់យកទៅអភិវឌ្ឍន៍ប្រទេសជាតិ តាមរយៈការទិញប័ណ្ណបំណុលរបស់រដ្ឋាភិបាល។

ដើម្បីធ្វើការសម្រេចចិត្តក្នុងការផ្តល់ឥណទានឱ្យបានត្រឹមត្រូវ គឺត្រូវមានព័ត៌មានឱ្យបានគ្រប់គ្រាន់ច្បាស់លាស់ មុខរបររបស់អតិថិជន និងកត្តាជាច្រើនផ្សេងទៀតដែលអាចមានឥទ្ធិពលដល់ការវិភាគ និងការវាយតម្លៃលើសុចរិតភាព សមត្ថភាព និងសុវត្ថិភាពក្នុងការផ្តល់ឥណទាន។

**ការវាយតម្លៃឥណទាន5(Cs)**

- ចរិកលក្ខណៈ (Character) គឺសំដៅទៅលើប្រវត្តិនៃការបង់សងរបស់អតិថិជន ដែលមានកេរ្តិ៍ឈ្មោះទៀងត្រង់ អំណត់អន់ធន់ និងការសម្រេចចិត្តលើកាតព្វកិច្ចសងបំណុលត្រឡប់។ លក្ខណៈនេះមានសារៈសំខាន់សម្រាប់អ្នកផ្តល់ឥណទាន ដើម្បីតាមដានលើការរស់នៅ ប្រវត្តិសងប្រាក់ ប្រវត្តិខ្ចីប្រាក់។
- សមត្ថភាព (Capacity) គឺបង្ហាញពីលទ្ធភាពដែលអ្នកស្នើសុំឥណទាន អាចសងត្រឡប់មកវិញឱ្យបានទាន់ពេលវេលា និងគ្រប់ចំនួនតាមការព្រមព្រៀងដែលបានស្នើសុំ។
- មូលធន (Capital) គឺបង្ហាញអំពីទ្រព្យសម្បត្តិ ឬធនធានហិរញ្ញវត្ថុ ដែលអ្នកស្នើសុំឥណទានក្នុងការសងត្រឡប់មកវិញ នៅពេលដែលបាត់បង់ការងារ ឬចំណូល។

- ទ្រព្យបញ្ចាំ ឬទ្រព្យធានា (Collateral) គឺសំដៅទៅលើទ្រព្យសម្បត្តិដែលអ្នកស្នើសុំឥណទានមានយកមកបញ្ចាំ ដើម្បីធានាប្រាក់កម្ចី។
- លក្ខខណ្ឌ (Condition) គឺសំដៅទៅលើកិច្ចព្រមព្រៀងរវាងអ្នកផ្តល់ឥណទាន និងអ្នកស្នើសុំឥណទានក្នុងគោលបំណងនៃការកម្ចីចំនួនទឹកប្រាក់ និងអត្រាការប្រាក់ជាដើម។

**ការវាយតម្លៃឥណទាន4(Rs)**

- ផ្តល់ឥណទានត្រូវចំអតិថិជន (Right People) គឺជាសកម្មភាពដែលស្ថានប័នផ្តល់ជូនដល់អតិថិជនគោលដៅ ឬអតិថិជនដែលស្ថាប័នចង់ធ្វើការវិនិយោគទៅលើពួកគាត់។
- ផ្តល់ឥណទានត្រូវតាមប្រភេទមុខរបរ (Right Business) គឺការផ្តល់ឥណទានឱ្យចំមុខរបរដែលស្របតាមទីផ្សារ ហើយទទួលប្រាក់ចំណូលខ្ពស់ព្រមទាំងមានហានិភ័យទាប និងមុខរបរស្របតាមច្បាប់។
- ផ្តល់ឥណទានត្រូវតាមសម្ថភាព និងតម្រូវការ (Right Amount) គឺជាសកម្មភាពដែលស្ថាប័នធ្វើការវាយតម្លៃលើសម្ថភាពរបស់អតិថិជនខ្លួនដោយផ្ទាល់។
- ផ្តល់ឥណទានត្រូវតាមរយៈពេល និងពេលវេលា (Right Time) គឺអ្នកផ្តល់ត្រូវឱ្យទាន់ពេលវេលា និងតម្រូវការរបស់អតិថិជន ហើយមានការត្រួតពិនិត្យឱ្យបានច្បាស់លាស់[7]។

## ២.៣ ការគ្រប់គ្រងហានិភ័យឥណទានឱ្យមានប្រសិទ្ធភាពរបស់ធនាគារ

### ២.៣.១ និយមន័យហានិភ័យ

- ហានិភ័យ គឺជាកម្រិតនៃគ្រោះថ្នាក់។
- ហានិភ័យ គឺជាឱកាសនៃការបាត់បង់។
- ហានិភ័យ គឺជាឱកាស ឬលទ្ធភាពរបស់លទ្ធផលពិតនៅពេលអនាគត ខុសពីអ្វីដែលគេបានរំពឹងទុកនៅពេលបច្ចុប្បន្ន។
- ហានិភ័យ គឺជាឱកាសនៃប្រាក់ចំណេញសុទ្ធរបស់ការវិនិយោគមួយ អាចខុសពីអ្វីដែលគេបានរំពឹងទុកនៅពេលបច្ចុប្បន្ន[8]។
- ហានិភ័យ គឺជាហេតុការណ៍ ឬព្រឹត្តិការណ៍ទាំងឡាយណា ដែលកើតមានឡើងដោយមិនបានគិតទុកជាមុន។
- ហានិភ័យ គឺជាព្រឹត្តិការណ៍មិនជាក់លាក់មួយ ដែលកើតមានឡើងនៅគ្រប់ពេលវេលា គ្រប់ទីកន្លែង និងគ្រប់កាលៈទេសៈទាំងអស់ ហើយការកើតមានឡើងតែងតែបង្កឱ្យមានការខូចខាត ឬបាត់បង់ទៅលើផ្នែកហិរញ្ញវត្ថុ និងផ្នែកមិនមែនហិរញ្ញវត្ថុ[9]។

### ២.៣.២ ប្រវត្តិរបស់ហានិភ័យ

នៅដើមសតវត្សទី ២០ ការវាយតម្លៃហានិភ័យបានចាប់ផ្តើមមានរូបរាងនៅក្នុងក្របខ័ណ្ឌនៃទ្រឹស្តីសេដ្ឋកិច្ច។ Frank H. Knight ក្នុងការងារសិក្ខាសាលារបស់គាត់ "Risk, Uncertainty, and Profit" ឆ្នាំ១៩២១ បានបែងចែករវាងហានិភ័យ ភាពមិនប្រាកដប្រជាក្នុងបរិមាណ និងភាពមិនប្រាកដប្រជាពិតប្រាកដ ដែលមិន

[7] វិទ្យាស្ថានវ៉ាន់ដា. (2023). *ការគ្រប់គ្រងឥណទាន*. បោះពុម្ពលើកទី២ ទំព័រទី២៤-២៦. ៥៨ទំព័រ. ភ្នំពេញ។

[8] Facebook. Khem Sarith. (2015, August 09). *Definition of Risk*. Retrieved from https://www.facebook.com/share/p/14uioNhirJ/ (Accessed March, 08 2025).

[9] វិទ្យាស្ថានវ៉ាន់ដា. (2016). *ការគ្រប់គ្រងហានិភ័យ*. បោះពុម្ពលើកទី២ ទំព័រទី១. ៧៧ទំព័រ. ភ្នំពេញ។

អាចវាស់វែងបាន (Korablev et al., 2020)។ ដំណាក់កាលបន្ទាប់ក្នុងការអភិវឌ្ឍន៍ហានិភ័យ គឺការលេចចេញនៅក្នុងឆ្នាំ១៩៦៥ នៃទ្រឹស្តីសំណុំ fuzzy និងឧបករណ៍គណិតវិទ្យានៃ fuzzy inference ដែលស្នើឡើងដោយ Lotfi A. Zadeh (2015) ។ អ្នកស្រាវជ្រាវមកពីអាស៊ីបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ និងការបង្កើតតក្កវិជ្ជាមិនច្បាស់។ ភាពខុសគ្នានេះ បានបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍន៍ជាបន្តបន្ទាប់ក្នុងការគ្រប់គ្រងហានិភ័យ និងជាពិសេសអំពីរបៀបដែលហានិភ័យត្រូវបានយល់ឃើញ និងបរិមាណនៅក្នុងបរិបទសេដ្ឋកិច្ច។ ទន្ទឹមនឹងនោះ ការរួមចំណែករបស់ Henri Fayol ចំពោះទ្រឹស្តីការគ្រប់គ្រងបានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃមុខងារសុវត្ថិភាពក្នុងការគ្រប់គ្រងអង្គភាព ដោយបញ្ចូលការពិចារណាហានិភ័យបន្ថែមទៀតទៅក្នុងការអនុវត្តអាជីវកម្ម (Korablev et al., 2020)[10]។

### ២.៣.៣ ប្រភេទនៃហានិភ័យ

ប្រភេទនៃហានិភ័យដែលធនាគារតែងតែជួបប្រទះមានដូចជា៖

- ហានិភ័យឥណទាន (Credit Risk)
- ហានិភ័យទីផ្សារ (Market Risk)
- ហានិភ័យប្រតិបត្តិការ (Operational Risk)
- ហានិភ័យអត្រាការប្រាក់ (Interest Rate Risk)
- ហានិភ័យសាច់ប្រាក់ងាយស្រួល (Liquidity Risk)
- ហានិភ័យកេរ្តិ៍ឈ្មោះ (Reputation Risk)
- ហានិភ័យបច្ចេកវិទ្យា (Technology Risk)
- ហានិភ័យអត្រាប្តូរប្រាក់ (Currency Forex Risk)
- ហានិភ័យច្បាប់ (Legal Risk)
- ហានិភ័យយុទ្ធសាស្រ្ត (Strategic Risk)...[11]។

[10] EP. (2019, December 19-20). *Risk Theory*. Retrieved from https://www.europeanproceedings.com/article/10.15405/epsbs.2020.04.75 (Accessed March, 08 2025).

[11] វិទ្យាស្ថាន វ៉ាន់ដា. (2019). *របិយវត្ថុ និងធនាគារ ភាគ១*. បោះពុម្ពលើកទី៥. ទំព័រទី៥៧. ៥៨ទំព័រ។


Risk in Banking
Financial Risk
Non-Financial Risk
Credit Risk
Market Risk
Counter Part of Borrower Risk
Intrinsic or industry Risk
Portfolio or Concentration Risk
Interest Rate Risk
Liquidity Rate Risk
Currency Forex Risk
Hedging Risk
Operational Risk
Strategic Risk
Funding Risk
Political Risk
Legal Risk

# ជំពូកទី៣

# ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារ ស្ថាបនា ភីអិលស៊ី

## ៣.១ ស្ថានភាពទូទៅនៃធនាគារ ស្ថាបនា

### ៣.១.១ ប្រវត្តិរបស់ធនាគារ ស្ថាបនា



ធនាគារ ស្ថាបនា ភីអិលស៊ី គឺជាសាជីវកម្ម ម៉ារ៉ូហាន់ របស់ជប៉ុនដែលបានបង្កើតឡើងតាំងពី ខែឧសភា ឆ្នាំ១៩៧៥ ដោយ លោក បណ្ឌិត Han Chang-Woo ប្រធានក្រុមប្រឹក្សាភិបាល ហើយបច្ចុប្បន្នគឺជាក្រុមហ៊ុនពហុកំសាន្តឈានមុខគេក្នុងប្រទេសជប៉ុន។ នៅពាក់កណ្ដាលឆ្នាំ២០០០ លោក បណ្ឌិត Han Chang-Woo បានធ្វើដំណើរទស្សនកិច្ចតាមប្រទេសមួយចំនួនក្នុងតំបន់អាស៊ីអាគ្នេយ៍ ដើម្បីសិក្សាស្វែងយល់ពីសក្តានុពល និងឱកាសអាជីវកម្មថ្មីៗក្នុងគោលបំណងបង្កើនសេដ្ឋកិច្ច និងជួយប្រជាពលរដ្ឋរបស់ប្រទេសទាំងនោះឱ្យមានជីវភាពប្រសើរឡើង។ លោកបណ្ឌិត Han Chang-Woo មានបទពិសោធន៍ក្នុងកំឡុងពេលដែលប្រទេសជប៉ុនចាប់ផ្ដើមមានភាពរីកចម្រើនពីទស្សវត្សឆ្នាំ១៩៥០ រហូតដល់បច្ចុប្បន្ន។ គាត់បានជួបប្រាស្រ័យទាក់ទងជាមួយមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ និងពាណិជ្ជករដើម្បីទទួលបាននូវយោបល់ និងការពិភាក្សាផ្សេងៗ។ លោកបណ្ឌិតបានចាប់អារម្មណ៍ជាពិសេសចំពោះប្រទេសកម្ពុជា ហើយគាត់មានអារម្មណ៍ថាប្រទេសកម្ពុជាមានសក្តានុពល បន្ទាប់ពីបានឆ្លងកាត់បទពិសោធន៍ដ៏លំបាកបំផុតក្នុងសម័យសង្គ្រាមស៊ីវិល។ លោក បណ្ឌិត យល់ឃើញថាការបង្កើតធនាគារពាណិជ្ជជាមួយនឹងការធ្វើបដិសណ្ឋារកិច្ចតាមបែបជប៉ុនពិតជាអាចជួយ និងចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ភាពរីកចម្រើនរបស់ប្រទេសកម្ពុជា។

ដោយហេតុនេះ លោកបណ្ឌិត Han Chang-Woo បានបង្កើត ម៉ារ៉ូហាន់ ធនាគារជប៉ុន ភីអិលស៊ី ក្នុងខែឧសភា ឆ្នាំ២០០៨ ដែលជាធនាគារពាណិជ្ជទីមួយដែលគ្រប់គ្រងដោយជនជាតិជប៉ុន ក្នុងគោលបំណងចូលរួមអភិវឌ្ឍន៍ និងលើកស្ទួយប្រទេសកម្ពុជាតាមរយៈការផ្ដល់នូវសេវាធនាគារសម្បូរបែប និងការវិនិយោគពីប្រទេសជប៉ុន។ ទស្សនៈវិស័យរបស់គាត់ គឺជួយគាំទ្រប្រជាជនកម្ពុជាដែលខិតខំចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជា ក្នុងស្មារតីប្រកួតប្រជែងដោយមិនផ្តេកផ្តួល ឬទទួលយកនូវស្ថានភាពបច្ចុប្បន្ននោះឡើយ។ ដើម្បីគាំទ្រឱ្យពេញលេញដល់ប្រជាជនកម្ពុជា ម៉ារ៉ូហាន់ ធនាគារជប៉ុន ជាធនាគារពាណិជ្ជទីមួយដែលផ្តល់កម្ចីមិនមានទ្រព្យបញ្ចាំដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

ឱកាសបានលេចឡើងក្នុងខែធ្នូ ឆ្នាំ២០១២ ដែលអាចអនុញ្ញាតិឱ្យ ម៉ារ៉ូហាន់ ធនាគារជប៉ុន ភីអិលស៊ី មានលទ្ធភាពទិញយកភាគហ៊ុនរបស់ ស្ថាបនា លីមីតធីត ដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេក្នុងប្រទេសកម្ពុជា។ ស្ថាបនា លីមីតធីត ត្រូវបានបង្កើតឡើងដំបូងក្នុងនាមជា អង្គការក្រៅរដ្ឋាភិបាល (NGO) ក្នុងឆ្នាំ១៩៩៥ ហើយក្នុងពេលដែល ម៉ារ៉ូហាន់ ធនាគារជប៉ុន ទិញយកភាគហ៊ុនរបស់ស្ថាបនា ដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដែលអាចផ្តល់សេវាកម្ចីដល់ប្រជាជនដែលមានចំណូលទាបនៅក្នុងទូទាំងប្រទេសជាមួយនឹងការចូលរួមអភិវឌ្ឍន៍ និងលើកស្ទួយសេដ្ឋកិច្ចប្រទេសកម្ពុជាតាមរយៈសាខាចំនួន ១៤០ និងការិយាល័យផ្តល់សេវារបស់ខ្លួនជាច្រើនផ្សេងទៀតនៅទូទាំងប្រទេស។

ម៉ារ៉ូហាន់ ធនាគារជប៉ុន បានកំពុងផ្តោតសំខាន់លើការផ្តល់ផលិតផល និងសេវាធនាគារពាណិជ្ជដែលមានគោលបំណងពង្រីកប្រតិបត្តិការរបស់ខ្លួនទូទាំងប្រទេស។ ជាមួយគ្នានេះដែរ ស្ថាបនា លីមីតធីត បានកំពុងផ្តោតសំខាន់លើសេវា និងផលិតផលមីក្រូហិរញ្ញវត្ថុទៅប្រជាជនដែលមានចំណូលទាបនៅទូទាំងប្រទេស ដោយមានគោលបំណងក្លាយជាធនាគារពាណិជ្ជពេញលេញ។ លោកបណ្ឌិត Han Chang-Woo ប្រធានក្រុមប្រឹក្សាភិបាលបាន យល់ឃើញពីភាពស្រដៀងគ្នានៃសក្តានុពល និងគោលដៅរួមរបស់ម៉ារ៉ូហាន់ ធនាគារជប៉ុន និងស្ថាបនា លីមីតធីត ដែលអាចបំពេញឱ្យគ្នាទៅវិញទៅមកបាន លោកក៏បានសម្រេចចិត្តធ្វើការរួមបញ្ចូលគ្នារវាងស្ថាប័នទាំងពីរដើម្បីកម្លាយខ្លួនជាធនាគារពាណិជ្ជថ្មីមួយ។

អាស្រ័យដោយការរួមបញ្ចូលគ្នារវាងគ្រឹះស្ថានហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ពុំធ្លាប់មានប្រវត្តិពីមុនមកនៅឡើយ និងបានឆ្លងកាត់ការពិគ្រោះយោបល់ជាច្រើនជាមួយធនាគារជាតិ នៃកម្ពុជា និងស្ថាប័នរបស់រដ្ឋាភិបាលដែលពាក់ព័ន្ធនឹងធនាគារ ស្ថាបនា ភីអិលស៊ី ត្រូវបានបង្កើតឡើងដោយជោគជ័យនៅក្នុងខែមេសា ឆ្នាំ២០១៦ ជាមួយនឹងដើមទុនចុះបញ្ជី ១២០ លានដុល្លារសហរដ្ឋអាមេរិក មានសាខាចំនួន ១៦០ មានម៉ាស៊ីន ATM ៧៣ និងបុគ្គលិកចំនួន ៣,៤៥៨ នាក់។ ធនាគារពាណិជ្ជដែលបានរួមបញ្ចូលគ្នាថ្មីបានបង្កើតឡើងដើម្បីផ្តល់នូវសេវាកម្មធនាគារប្រកបដោយភាពជឿជាក់ ក្នុងនាមជាធនាគាររបស់ប្រជាជននៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលបំពាក់ដោយសក្តានុពលដល់សហគ្រិន ព្រមទាំងបង្កើតឱ្យមាននូវឱកាសការងារជាច្រើនដើម្បីបង្កើតអាជីវកម្ម និងលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេតាមរយៈការទទួលយកបាននូវសេវាកម្មហិរញ្ញវត្ថុដែលមានស្ថិរភាព។

ទិសដៅរបស់លោកបណ្ឌិត Han Chang-Woo ប្រធានក្រុមប្រឹក្សាភិបាល មានភាពច្បាស់លាស់គឺ "យើងនឹងបន្តលើកតម្កើនកម្រិតនៃការពេញចិត្តរបស់អតិថិជន និងពង្រីកអាជីវកម្មរបស់ពួកយើងជាមួយនឹងគំនិតច្នៃប្រឌិត និងស្មារតីជាអ្នកដឹកនាំ។ យើងមានគោលបំណងក្លាយជាធនាគារពាណិជ្ជឈានមុនគេក្នុងប្រទេសកម្ពុជា"[12]។

### ៣.១.២ ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃរបស់ធនាគារ ស្ថាបនា

#### ក. ចក្ខុវិស័យ

ជាធនាគារដែលឈានមុខគេ និងជាទីទុកចិត្តបំផុតក្នុងការផ្តល់សេវាកម្មធនាគារពេញលេញទូទាំងព្រះរាជាណាចក្រកម្ពុជា។

#### ខ. បេសកកម្ម

កសាងអនាគតដ៏ល្អប្រសើរជាងមុនដោយផ្តោតលើអតិថិជនជាអទិភាព ផ្តល់សេវាកម្មឱ្យបានល្អលើសពីការរំពឹងទុករបស់អតិថិជន ជាមួយនឹងការផ្តល់នូវដំណោះស្រាយហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងពង្រឹងទំនាក់ទំនងសហគមន៍ប្រកបដោយនិរន្តរភាព។

#### គ. គុណតម្លៃ

- សេវាកម្មល្អឥតខ្ចោះ (Service Excellence)
  ជាធនាគារដែលទទួលបានការជឿទុកចិត្តតាមរយៈការប្តេជ្ញាចិត្តក្នុងការផ្តល់នូវសេវាកម្មដ៏ល្អបំផុតប្រកបដោយទំនួលខុសត្រូវ និងសុចរិតភាព។
- ធនជានជាចម្បង (People First)
  យើងយកចិត្តទុកដាក់ចំពោះគ្នា គោរពគ្នា និងជួយគ្នាទៅវិញទៅមកប្រកបដោយសាមគ្គីភាព។
- គំនិតថ្មី (New Ideas)
  ស្វាគមន៍គំនិតផ្តួចផ្តើមថ្មី និងការស្វែងរកការកែលម្អជាបន្តបន្ទាប់ ដើម្បីចាប់យកឱកាសអាជីវកម្មថ្មី។
- ការកសាងនិរន្តរភាព (Building Sustainability)
  យើងប្តេជ្ញាយ៉ាងមុតមាំក្នុងការគាំទ្រ និងទ្រទ្រង់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពសម្រាប់ធនាគារ និងសង្គមរបស់យើង។

[12] Sathapana Bank. (2025). *About Us*: https://www.sathapana.com.kh/kh/about-us

## ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ចរបស់ធនាគារ ស្ថាបនា

### ក. រចនាសម្ព័ន្ធគ្រប់គ្រង



### ខ. តួនាទីក្រុមប្រឹក្សាភិបាល

**បណ្ឌិត HAN CHANG-WOO**

**ប្រធានក្រុមប្រឹក្សាភិបាល**

លោកបណ្ឌិត HAN CHANG-WOO ជាស្ថាបនិក និងជាប្រធានក្រុមហ៊ុន MARUHAN Corporation ក្នុងប្រទេសជប៉ុនដែលកំពុងធ្វើការផ្គត់ផ្គង់ និងរៀបចំសម្ភារកំសាន្តជាច្រើនប្រភេទដូចជា៖ ទីលានវាយកូនហ្គោល ទីលានហាត់វាយកូនហ្គោល កន្លែងបោះប៊ូលីង មជ្ឈមណ្ឌលហ្គេម ភោជនីយដ្ឋាន និងPachinko Parlors (Pinball របស់ជប៉ុន)។ លោកបណ្ឌិត បានបង្កើតក្រុមហ៊ុន MARUHAN Corporation ក្នុងឆ្នាំ១៩៥៧ និងបានធ្វើឱ្យអាជីវកម្មមួយនេះមានការរីកចម្រើនយ៉ាងលឿនដែលបានទទួលចំណូលក្នុងការលក់សរុបជាង ២៥ ពាន់

លានដុល្លារក្នុងមួយឆ្នាំ។ ក្រុមហ៊ុន MARUHAN Corporation ត្រូវបានស្គាល់ថាជាក្រុមហ៊ុនឈានមុខគេក្នុងវិស័យឧស្សាហកម្មក្នុងប្រទេសជប៉ុន។ ភាពជោគជ័យនៃការរីកចម្រើនផ្នែកអាជីវកម្មរបស់ក្រុមហ៊ុន គឺកើតចេញពីការប្តេជ្ញាចិត្តក្នុងការប្រកួតប្រជែងខ្ពស់របស់លោកបណ្ឌិត HAN និងជំនឿចិត្តដ៏រឹងមាំក្នុងការបំពេញតាមតម្រូវចិត្តរបស់អតិថិជន។ បច្ចុប្បន្ន លោក បណ្ឌិត កំពុងចូលរួមយ៉ាងសកម្មជាមួយសមាគមមួយចំនួនក្នុងនាមជាទីប្រឹក្សាកិត្តិយសនៃមូលនិធិវប្បធម៌ Han Chang-Woo Tetsu ប្រធានសមាគម Kyoto UNESCO Association ប្រធានសមាគម United Nations Association of Japan Kyoto Headquarters ប្រធាន Tokyo Philharmonic ប្រធានក្រុមប្រឹក្សាភិបាល World Federation of Korean Chambers of Commerce and Industry និងទីប្រឹក្សាកិត្តិយសនៃ Central Association of Japan-Korea Friendship Societies ។ លោកបានទទួលសញ្ញាបត្រថ្នាក់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចនយោបាយ ពីសាកលវិទ្យាល័យ Hosei នៅឆ្នាំ១៩៥៣។

**លោក HAN KEN**

**អនុប្រធានក្រុមប្រឹក្សាភិបាល**

លោក HAN KEN បានបម្រើការជាមួយក្រុមហ៊ុន MARUHAN Corporation ក្នុងឆ្នាំ២០០០ បន្ទាប់ពីលោកបានធ្វើការនៅក្រុមហ៊ុនមូលធនប័ត្រ Nomura តាំងពីឆ្នាំ១៩៩៨។ នៅឆ្នាំ២០០៧ លោកត្រូវបានចាត់តាំងជាអភិបាលនៃក្រុមហ៊ុន MARUHAN Corporation ហើយនៅឆ្នាំ២០១៤ ជាអភិបាលប្រតិបត្តិ។ នៅឆ្នាំ២០២០ លោកត្រូវបានចាត់តាំងជាតំណាងអភិបាលប្រចាំតំបន់។ នៅឆ្នាំ២០២១ លោកត្រូវបានចាត់តាំងជាប្រធានក្រុមហ៊ុនហិរញ្ញវត្ថុនៃក្រុមហ៊ុន MARUHAN Corporation។ លោកក៏មានតួនាទីជាអភិបាលផ្នែកគ្រប់គ្រង និងជាប្រធាននាយកប្រតិបត្តិរបស់ក្រុមហ៊ុន MARUHAN Investment Asia Pte. Ltd ដែលមានស្នាក់ការកណ្តាលស្ថិតនៅក្នុងប្រទេសសិង្ហបុរី។ លោកគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធហិរញ្ញវត្ថុ ដូចជា ធនាគារ ស្ថាបនា ភីអិលស៊ី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា លីមីតធីត នៅប្រទេសមីយ៉ាន់ម៉ា និងម៉ារ៉ូហាន់ធនាគារ ជប៉ុននៅប្រទេសឡាវ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកច្បាប់ ពីសាកលវិទ្យាល័យ DOSHISHA នៅឆ្នាំ១៩៩៧។

**លោក IWASA TOMOYUKI**

**អភិបាល**

លោក IWASA TOMOYUKI មានបទពិសោធន៍ជាង ៣០ ឆ្នាំក្នុងវិស័យធនាគារចាប់តាំងពីលោកបានចាប់ផ្តើមអាជីពក្នុងឆ្នាំ១៩៨៩ នៅធនាគារ Mizuho Bank Ltd. ក្នុងប្រទេសជប៉ុន។ លោកបានកាន់មុខតំណែង និងធ្វើការជាច្រើននៅក្នុងវិស័យធនាគារសាជីវកម្មដោយរួមមាន៖ ការផ្សព្វផ្សាយពាណិជ្ជកម្ម ការធ្វើផែនការយុទ្ធសាស្ត្រ ការគ្រប់គ្រងហានិភ័យ និងឥណទានទាំងសម្រាប់ទីផ្សារក្នុងស្រុក និងក្រៅស្រុក។ បន្ទាប់ពីអាជីពចុងក្រោយរបស់លោកនៅធនាគារ Mizuho ក្នុងតួនាទីជាអគ្គនាយករងនៃនាយកដ្ឋានឥណទានអាមេរិកនៅទីក្រុងញូវយ៉ក លោកបានចូលរួមជាមួយ MARUHAN Corporation ក្នុងខែសីហា ឆ្នាំ២០១៩ ដែលជាម្ចាស់ភាគហ៊ុនរបស់ធនាគារ ស្ថាបនា ភីអិលស៊ី។ បច្ចុប្បន្ននេះ លោកមានតួនាទីជាមន្ត្រីសាជីវកម្មនៃក្រុមហ៊ុនហិរញ្ញវត្ថុ និងជាអ្នកគ្រប់គ្រងទូទៅនៃនាយកដ្ឋានគ្រប់គ្រងហានិភ័យ។ លោក Iwasa បានទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Vanderbilt (សហរដ្ឋអាមេរិក) ក្នុងឆ្នាំ២០០០ និងបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ពីសាកលវិទ្យាល័យ Tokyo (ប្រទេសជប៉ុន) ក្នុងឆ្នាំ១៩៨៩។

**ឯកឧត្តម SHINOHARA KATSUHIRO**

**អភិបាលឯករាជ្យ**

ឯកឧត្តម SHINOHARA KATSUHIRO ធ្លាប់មានប្រវត្តិរស់នៅប្រទេសកម្ពុជាជាង ៥០ ឆ្នាំកន្លងមកហើយ។ នៅឆ្នាំ១៩៦៧ គាត់បានមកដល់ប្រទេសកម្ពុជាលើកដំបូងក្នុងនាមជាមន្ត្រីការទូតរបស់ជប៉ុន និងបានចំណាយពេល ២ ឆ្នាំដំបូងរស់នៅក្នុងវត្តឧណ្ណាលោម ក្នុងរាជធានីភ្នំពេញដែលក្នុងនោះលោកបានចំណាយរយៈពេល ៧ ខែបួសជាព្រះសង្ឃដើម្បីសិក្សាភាសា និងវប្បធម៌ខ្មែរមុនពេលចូលកាន់មុខដំណែងជាមន្ត្រីលេខានៅស្ថានទូតជប៉ុនក្នុងប្រទេសកម្ពុជា។ បន្ទាប់ពីឯកឧត្តមបានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាក្នុងនាមជាអគ្គទីប្រឹក្សាស្ថានទូតជប៉ុន (ពីឆ្នាំ១៩៩១ ដល់ ឆ្នាំ១៩៩៤ និងពីឆ្នាំ២០០១ ដល់ ឆ្នាំ២០០៤) ឯកឧត្តមបានបង្កើតចំណងមិត្តភាព ជាមួយប្រទេសកម្ពុជាយ៉ាងរឹងមាំក្នុងតួនាទីជាឯកអគ្គរាជទូតជប៉ុនប្រចាំប្រទេសកម្ពុជាចាប់ពីឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០០៩។ ចាប់ពីខែធ្នូ ឆ្នាំ២០១២ ឯកឧត្តម គឺជាអភិបាលឯករាជ្យរបស់ ធនាគារ ស្ថាបនា ហើយលោកក៏ជាសមាជិកគណៈកម្មការកម្រិតក្រុមប្រឹក្សាភិបាល។ បច្ចុប្បន្នលោកជាប្រធានតំណាងនៃអង្គការ NGO មូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា (CIESF) នៃប្រទេសជប៉ុនដែលមានទីតាំងនៅរាជធានីភ្នំពេញ។

**ឯកឧត្តម NAKAGOME AKIHIRO**

**អភិបាលឯករាជ្យ**

លោក NAKAGOME AKIHIRO មានបទពិសោធន៍ ៣០ ឆ្នាំក្នុងវិស័យសវនកម្មគណនេយ្យផ្នែកទីប្រឹក្សាពន្ធដារបន្ទាប់មកជាទីប្រឹក្សាជំនួយការអភិវឌ្ឍន៍ (ODA) នៅក្រុមហ៊ុន EY ប្រទេសជប៉ុនតាមលក្ខណៈសម្បត្តិរបស់ CPA។ គម្រោង ODA ដែលលោកបានចូលរួមក្នុងការកែលម្អក្រុមអភិបាលកិច្ចនៃវិស័យធនាគារនៅប្រទេសម៉ុងហ្គោលី និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងពន្ធនៅប្រទេសកម្ពុជា។ ក្រោយមកលោកបានចូលបម្រើការជាប្រធាននាយកនៅក្រុមហ៊ុន EY Consulting នៅប្រទេសជប៉ុនក្នុងឆ្នាំ២០១៧ ហើយលោកបានបើកក្រុមហ៊ុនផ្តល់សេវាកម្មប្រឹក្សា SC Japan Co., Ltd ដែលរូបលោកជាប្រធាននាយកប្រតិបត្តិ។ ក្នុងខែសីហា ឆ្នាំ២០២១ លោកបានចូលជាអភិបាលឯករាជ្យនៅធនាគារ ស្ថាបនា។ លោកបានទទួលសញ្ញាបត្របរិញ្ញាបត្រផ្នែកវិស្វកម្មអគ្គិសនីនៃមហាវិទ្យាល័យវិស្វកម្មនៅសាកលវិទ្យាល័យ Yamanashi ក្នុងឆ្នាំ១៩៨០ ហើយលោកបានទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកគណនេយ្យករជំនាញ (CPA) នៅប្រទេសជប៉ុនក្នុងឆ្នាំ១៩៩៤។

**ឯកឧត្តម គិម វ៉ាដា**

**អភិបាលឯករាជ្យ**

ឯកឧត្តម គិម វ៉ាដា មានបទពិសោធន៍ការងាររយៈពេលជាង ៣៧ ឆ្នាំ នៅធនាគារជាតិ នៃកម្ពុជា ដោយចាប់ផ្តើមពីតំណែងជាប្រធានការិយាល័យនៅសាខាខេត្តកណ្តាលរបស់ធនាគារជាតិ នៃកម្ពុជា រហូតក្លាយជាអគ្គនាយក នៃអគ្គនាយកដ្ឋានត្រួតពិនិត្យនៃធនាគារជាតិ នៃកម្ពុជា។ នៅក្នុងអំឡុងពេលបំពេញការងារនៅធនាគារជាតិ នៃកម្ពុជា ឯកឧត្តមក៏បានទទួលបន្ទុក និងមានតួនាទីជាថ្នាក់ដឹកនាំជាន់ខ្ពស់ជាច្រើនជាមួយនឹងបទពិសោធន៍ទូលំទូលាយក្នុងវិស័យធនាគារ ដោយរួមបញ្ចូលទាំងផ្នែកគ្រប់គ្រងហានិភ័យ (ហានិភ័យទីផ្សារ ហានិភ័យឥណទាន ហានិភ័យសន្ទនីយភាព និងហានិភ័យប្រតិបត្តិការជាដើម) អភិបាលកិច្ច និងយុទ្ធសាស្ត្រអាជីវកម្ម។ ឯកឧត្តមបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការរៀបចំប្រព័ន្ធធនាគារនៅកម្ពុជាឡើងវិញយ៉ាង

ជោគជ័យក្នុងអំឡុងទសវត្សឆ្នាំ២០០០ ក្នុងការបង្កើតឱ្យមានប្រព័ន្ធធនាគារមួយដែលមានលក្ខណៈប្រកួតប្រជែង និងប្រកបដោយសុវត្ថិភាពក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងបានយ៉ាងល្អ ព្រមទាំងបានបង្កើតឱ្យមានការកេណ្ឌប្រមូលប្រាក់បញ្ញើយ៉ាងមានប្រសិទ្ធភាពសម្រាប់ផ្តល់ជាហិរញ្ញប្បទាន ដើម្បីជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា។ ឯកឧត្តម គឹម វ៉ាដា ទទួលបានបរិញ្ញាបត្រផ្នែកច្បាប់ក្នុងឆ្នាំ១៩៧៥ បរិញ្ញាបត្រផ្នែកធនាគារក្នុងឆ្នាំ១៩៨៥ និងអនុបណ្ឌិតផ្នែកគ្រប់គ្រងធុរកិច្ចជំនាញហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី នៅឆ្នាំ២០០៣។ ឯកឧត្តមធ្លាប់ធ្វើជាសាស្ត្រាចារ្យ និងជាវាគ្មិននៅសាកលវិទ្យាល័យល្បីៗមួយចំនួននៅក្នុងប្រទេសកម្ពុជា។ លើសពីនេះក្នុងអំឡុងពេល ១០ ឆ្នាំចុងក្រោយនេះលោកបានចូលរួមយ៉ាងសកម្មទាំងក្នុងនាមជាវាគ្មិនក្នុងសន្និសីទសិក្ខាសាលាជាតិ និងអន្តរជាតិជាច្រើនដែលទាក់ទងនឹងក្របខណ្ឌបទប្បញ្ញត្តិច្បាប់ ការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ ព្រមទាំងសេវាកម្មធនាគារចល័ត និងបរិយាប័ន្នហិរញ្ញវត្ថុ។ ចំពោះការងារអន្តរជាតិលោកទទួលបន្ទុកជាប្រធានក្រុមប្រឹក្សាភិបាលនៃសមាគមឥណទានកសិកម្ម និងជនបទប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (APRACA) ពីខែកក្កដា ឆ្នាំ២០១២ ដល់ខែមិថុនា ឆ្នាំ២០១៤ និងជាសមាជិកប្រតិបត្តិ នៃសហព័ន្ធបរិយាប័ន្នហិរញ្ញវត្ថុ (AFI) ពីខែមករា ឆ្នាំ២០១៥ ដល់ខែមិថុនា ឆ្នាំ២០១៧ ផងដែរ។

**គ. ភារកិច្ចគណៈគ្រប់គ្រងប្រតិបត្តិ**

**លោក ហ្វុង កៃ ជីន**

**ប្រធាននាយកប្រតិបត្តិ**

លោក ហ្វុង កៃ ជីន មានបទពិសោធន៍ជាង ៣០ ឆ្នាំក្នុងវិស័យធនាគារជាមួយនឹងគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិ និងក្នុងតំបន់។ មុនពេលចូលមកបម្រើការនៅ ធនាគារ ស្ថាបនា លោកគឺជាប្រធាននាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងអគ្គនាយករងនៃធនាគារ VPBank ប្រទេសវៀតណាម។ លោកក៏ជាអគ្គនាយករង និងនាយកផ្នែកធនាគារពាណិជ្ជកម្មនៃធនាគារ Alliance Bank Malaysia_Berhad និងជានាយកគ្រប់គ្រងទូទៅផ្នែកធនាគារសហគ្រាសធុនតូច និងមធ្យម នៃធនាគារ Standard Chartered Malaysia Berhad។ លោក ហ្វុង ទទួលបានសញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែករដ្ឋបាលពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Curtin នៅប្រទេសអូស្ត្រាលី និងបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចសំណង់ ពីវិទ្យាស្ថានបច្ចេកវិទ្យា Royal Melbourne ប្រទេសអូស្ត្រាលី។

**លោក គូរ៉ូគី កាន់ជី**

**អនុប្រធាននាយកប្រតិបត្តិ**

លោក គូរ៉ូគី កាន់ជី មានបទពិសោធន៍ជាង ៣៥ ឆ្នាំលើផ្នែកធនាគារពាណិជ្ជតាំងពីលោកចាប់ផ្តើមការងារនៅឆ្នាំ១៩៨៩ ជាមួយនឹងធនាគារ Sumitomo Limited (ក្រោយមកត្រូវប្តូរឈ្មោះទៅជាធនាគារ Sumitomo Mitsui ឬ SMBC) នៅប្រទេសជប៉ុន។ បន្ទាប់ពីលោកបានបម្រើការនៅសាខាក្នុងស្រុកនៃប្រទេសជប៉ុន លោកបានធ្វើការងារដែលភាគច្រើនគឺទាក់ទងទៅនឹងទីផ្សារដែលកំពុងរីកចម្រើននៃអាស៊ីអាគ្នេយ៍ និងផ្នែកធនាគារអន្តរជាតិនៅ SMBC។ លោកក៏បានបម្រើការងារដែលមានតួនាទីជាប្រធានផ្នែកគ្រប់គ្រងផែនការសាជីវកម្មនៅ PT Bank Sumitomo Mitsui ប្រទេសឥណ្ឌូនេស៊ី ចាប់ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ២០០៣ នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី។ បន្ទាប់មក លោកបានបម្រើការក្នុងតួនាទីជាអនុប្រធាន

គ្រប់គ្រងទូទៅនៃធនាគារ Eximbank ប្រទេសវៀតណាម ដែលជាសមាជិកធនាគារ SMBC ប្រចាំប្រទេសវៀតណាម ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៥។ នាខែមិថុនា ឆ្នាំ២០១៨ លោកបានចូលមកបម្រើការងារនៅ MARUHAN Corporation ដែលជាម្ចាស់ភាគហ៊ុនរបស់ ធនាគារ ស្ថាបនា។ ក្នុងខែធ្នូ ឆ្នាំ២០២១ លោកក៏បានចូលមកបម្រើការក្នុងតំណែងជាអនុប្រធានប្រតិបត្តិនៅធនាគារ ស្ថាបនា។ លោកគូរ៉ូគី ទទួលបានបរិញ្ញាបត្រផ្នែកសិល្បៈនៃការសិក្សាឥណ្ឌូចិន ពីសាកលវិទ្យាល័យ Tokyo នៅឆ្នាំ១៩៨៩។

**លោក ហ្គាញ៉ុង ហ្សង់ព្យែរ៍ ចូសែប អង់ជ្រេ**

**អនុប្រធាននាយកប្រតិបត្តិ**

លោក ហ្គាញ៉ុង ហ្សង់ព្យែរ៍ ចូសែប អង់ជ្រេ គឺជាអនុប្រធានប្រតិបត្តិនៅធនាគារ ស្ថាបនា ដែលមានបទពិសោធន៍ជាង ២៥ ឆ្នាំលើការដឹកនាំអង្គភាពនៅក្នុងវិស័យ Fintech និងប្រព័ន្ធទូទាត់ប្រាក់។ មុននឹងលោកចូលមកបម្រើការនៅធនាគារ ស្ថាបនា លោកធ្លាប់ជាអគ្គនាយកនៃ beFinancial នៅប្រទេសវៀតណាម និងជាអគ្គនាយកនៃ Eko-Pay។ កាលពីលោកនៅបម្រើការនៅមុខតំណែងមុនៗ លោកបានដឹកនាំឱ្យមានការអភិវឌ្ឍន៍ការធ្វើអនុកលកម្ម និងការប្រតិបត្តិនៃដំណោះស្រាយកម្មសិទ្ធិ នៅក្នុងធនាគារជាច្រើន និងផ្នែកប័ណ្ណដូចជា ប័ណ្ណវីសា និងម៉ាស្ទ័រកាត។ ច្រើនឆ្នាំកន្លងមកនេះ លោក ហ្គាញ៉ុង បាននាំមកនូវប្រព័ន្ធលក់ POS Loyalty Program ការសហការដៃគូផ្សព្វផ្សាយប័ណ្ណ ដំណោះស្រាយហិរញ្ញវត្ថុឌីជីថល និងផលិតផលធនាគារឌីជីថលនៅទូទាំងតំបន់អាមេរិកខាងជើង សហភាពអឺរ៉ុប និងអាស៊ីប៉ាស៊ីហ្វិក។ ជាមួយនឹងចំណេះដឹងដ៏ជ្រៅជ្រះនៃសកម្មភាពអភិវឌ្ឍន៍ពាណិជ្ជកម្ម ដំណោះស្រាយទូទាត់ប្រាក់ ដំណើរការហេដ្ឋារចនាសម្ព័ន្ធ និងការបញ្ចេញប័ណ្ណ លោកក៏មានតួនាទីដឹកនាំ និងគ្រប់គ្រងលើផ្នែកប្រតិបត្តិការធនាគារ ផ្នែកព័ត៌មានវិទ្យា និងផលិតផលឌីជីថល។ លើសពីនេះទៅទៀត លោកក៏មានតួនាទីដឹកនាំផ្នែកអភិវឌ្ឍន៍ដៃគូអាជីវកម្ម ខណៈលោកកំពុងបង្វឹក និងបង្កើតក្រុមការងារពូកែៗ និងមានទេពកោសល្យនៅធនាគារ ស្ថាបនា។

**កញ្ញា ជេននីហ្វឺ លី ឆាវលីន**

**នាយិកាប្រតិបត្តិប្រតិបត្តិការ**

កញ្ញា ជេននីហ្វឺ លី ឆាវលីន ដែលជានាយិកាប្រតិបត្តិប្រតិបត្តិការនៅធនាគារ ស្ថាបនា គឺជាបុគ្គលម្នាក់ដែលស្រឡាញ់ផ្នែកឌីជីថលតាំងពីចូលបម្រើការដំបូងលើគម្រោងឌីជីថលនៅឆ្នាំ១៩៩៣ អស់រយៈពេល ៣០ ឆ្នាំ កញ្ញាបានពង្រីកបទពិសោធន៍របស់ខ្លួនយ៉ាងទូលំទូលាយក្នុងវិស័យឌីជីថលដែលពាក់ព័ន្ធនឹងបច្ចេកវិទ្យាជាច្រើន។ កញ្ញា ជេននីហ្វឺ បានធ្វើការជាអ្នកផ្តល់សេវាកម្មផ្នែកឌីជីថលសហគ្រិនបច្ចេកទេស ហើយបានជួយដល់ការរៀបចំបង្កើតឡើងនូវការពង្រឹងបច្ចេកវិទ្យា និងបានដឹកនាំគម្រោងឌីជីថល និងកិច្ចជំនួបនៅក្នុងក្រុមហ៊ុនទូរគមនាគមន៍។ ថ្មីៗនេះ កញ្ញាបានដឹកនាំផ្នែកព័ត៌មានវិទ្យា និងឌីជីថល ដើម្បីរៀបចំធនាគារថ្មី និងកែប្រែពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទៅជាធនាគារពាណិជ្ជពេញលេញ។ កញ្ញា ជេននីហ្វឺ ទទួលបានបរិញ្ញាបត្រផ្នែកទំនាក់ទំនង ពីសាកលវិទ្យាល័យ Science Malaysia។

**លោក សៀង សេរី**

**នាយកប្រតិបត្តិ រដ្ឋបាល**

លោក សៀង សេរី មានបទពិសោធន៍ជាង ២៥ ឆ្នាំជាមួយស្ថាប័នហិរញ្ញវត្ថុជាច្រើន និងក្រុមហ៊ុន FMCG អន្តរជាតិ។ មុនពេលលោកត្រឡប់មកបម្រើការងារនៅ ធនាគារ ស្ថាបនា ភីអិលស៊ី ជានាយកប្រតិបត្តិ

រដ្ឋបាល នៅខែមករា ឆ្នាំ២០២៣ លោកត្រូវបានតែងតាំងជាប្រធាននាយកប្រតិបត្តិនៃ ស្ថាបនា លីមីតធីត ក្នុងប្រទេសភូមា។ បន្ថែមពីលើនេះទៅទៀត លោកធ្លាប់បម្រើការងារនៅធនាគារ ជប៉ុន MARUHAN ក្នុងឆ្នាំ២០០៨ ជានាយកសាខា និងបានអភិវឌ្ឍន៍អាជីពការងាររបស់លោកក្នុងតួនាទីផ្សេងៗជាច្រើនទៀត រួមមានដូចជា៖ នាយកសាខាស្នាក់ការកណ្តាល នាយកផ្នែកលក់ នាយកស្ថាប័នហិរញ្ញវត្ថុ និងនាយកប្រតិបត្តិរដ្ឋបាល។

លោក សេរី បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រង ពីសាកលវិទ្យាល័យ MAHARISHI Vedic ក្នុងឆ្នាំ១៩៩៧ និងអនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្មក្នុងឆ្នាំ២០០៨ ពីសាកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី។ ក្នុងដំណើរអាជីពការងាររបស់លោក សេរី លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាតិ និងអន្តរជាតិជាច្រើនដែលទាក់ទងនឹងធនាគារធុរកិច្ច។ លើសពីនេះទៅទៀត លោកត្រូវបានទទួលស្គាល់ជាសមាជិកក្រុមប្រឹក្សាភិបាលដែលមានវិជ្ជាជីវៈពីវិទ្យាស្ថាន Myanmar Institute of Directors (MIOD) នៅក្នុងឆ្នាំ២០២០។

**លោក ម៉េង វាសនា**

**នាយកប្រតិបត្តិហានិភ័យ**

លោក ម៉េង វាសនា មានបទពិសោធន៍ជាង ១៧ ឆ្នាំនៅក្នុងវិស័យធនាគារ និងក្រុមហ៊ុនសវនកម្មអន្តរជាតិមួយ។ លោកធ្លាប់ជាប្រធានផ្នែកសវនកម្មនៅក្រុមហ៊ុន Pricewaterhouse Coopers ក្នុងប្រទេសកម្ពុជា មុននឹងលោកបានចូលបម្រើការនៅ ម៉ារូហាន់ ធនាគារ ជប៉ុន នៅខែមេសា ឆ្នាំ២០១២ ក្នុងតំណែងជានាយកសវនកម្មផ្ទៃក្នុង និងក្រោយមកកាន់តំណែងផ្សេងទៀតដូចជា ប្រធាននាយកដ្ឋានគ្រប់គ្រងហានិភ័យសាជីវកម្ម និងប្រធាននាយកដ្ឋានឥណទាន មុនពេលមានការរួមបញ្ចូលគ្នារវាង ម៉ារូហាន់ ធនាគារ ជប៉ុន និង ស្ថាបនា លីមីតធីត ក្លាយជាធនាគារពាណិជ្ជក្នុងខែមេសា ឆ្នាំ២០១៦។ លោកបានបន្តបម្រើការជាប្រធាននាយកដ្ឋានឥណទានអាជីវកម្ម រហូតលោកត្រូវបានតែងតាំងជានាយកប្រតិបត្តិហានិភ័យនៅខែមេសា ឆ្នាំ២០២០។ លោក វាសនា ទទួលបរិញ្ញាបត្រផ្នែករដ្ឋបាលពាណិជ្ជកម្ម ពីសាកលវិទ្យាជាតិគ្រប់គ្រង ក្នុងឆ្នាំ២០០២។ លោកបានធ្វើការប្រលងជាប់ និងក្លាយជាសមាជិក ACCA ក្នុងឆ្នាំ២០០៩ និង FCCA ក្នុងឆ្នាំ២០១៤។ នៅក្នុងខែកញ្ញា ឆ្នាំ២០១៩ លោកទទួលបាន "Certified Expert in Risk Management" ដោយសញ្ញាបត្រចេញពី Frankfurt School of Finance and Management ប្រទេសអាល្លឺម៉ង់។

**លោក ស្វ័យ ប៉ុណ្ណរតន៍**

**នាយកប្រតិបត្តិហិរញ្ញវត្ថុ**

លោក ស្វ័យ ប៉ុណ្ណរតន៍ មានបទពិសោធន៍ជាង ១៨ ឆ្នាំជាមួយក្រុមហ៊ុន និងគ្រឹះស្ថានហិរញ្ញវត្ថុជាច្រើននៅក្នុងប្រទេសកម្ពុជា។ លោក ប៉ុណ្ណរតន៍ ចូលបម្រើការងារនៅ ធនាគារ ស្ថាបនា នៅខែតុលា ឆ្នាំ២០១៧។ មុននឹងចូលបម្រើការនៅ ធនាគារ ស្ថាបនា លោកគឺជាប្រធានទូទៅ ដែលគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងព័ត៌មានវិទ្យានៅក្រុមហ៊ុនតូយ៉ូតា ប្រទេសកម្ពុជា។ លោកក៏ធ្លាប់ធ្វើជានាយកប្រតិបត្តិហិរញ្ញវត្ថុ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា មុននឹងលោកត្រូវបានឡើងតំណែងទៅជាប្រធាននាយកប្រតិបត្តិនៅគ្រឹះស្ថានតែមួយ។ លោក ប៉ុណ្ណរតន៍ មានជំនាញយ៉ាងស្ទាត់ជំនាញទាក់ទងទៅនឹងគ្រឹះស្ថានហិរញ្ញវត្ថុអន្តរជាតិជាច្រើន និងមានបទពិសោធន៍ជាច្រើនឆ្នាំនៅក្នុងការគ្រប់គ្រងគម្រោងផ្សេងៗដូចជា ERP IT IFRS និងប្រព័ន្ធធនាគារស្នូល។

លោកត្រូវបានទទួលស្គាល់ជាអ្នកគ្រប់គ្រងគម្រោងដែលចេញដោយវិទ្យាស្ថានគ្រប់គ្រងគម្រោង ដែលមានទីតាំងនៅសហរដ្ឋអាមេរិក។ លើសពីនោះ លោក គឺជា Chartered Banker (CB) ដែលទទួលស្គាល់ដោយវិទ្យាស្ថាន Chartered Banker នៅចក្រភពអង់គ្លេស និងវិទ្យាស្ថាន Chartered Banker ប្រចាំអាស៊ីនៅប្រទេសម៉ាឡេស៊ី។ លោកក៏ជាសមាជិក FCCA នៃសមាគមគណនេយ្យករដែលទទួលបានអាជ្ញាប័ណ្ណផ្នែកគណនេយ្យ (ACCA) នៅចក្រភពអង់គ្លេស និងបុគ្គលដែលត្រូវបានទទួលស្គាល់ដោយនិយ័តករបរធនបាលកិច្ចនៅកម្ពុជា។ លោកក៏ទទួលបានសញ្ញាបត្រថ្នាក់អនុបណ្ឌិតផ្នែករដ្ឋបាលពាណិជ្ជកម្ម ពីសាលាពាណិជ្ជកម្ម Audencia ដែលស្ថិតនៅចំណោមសាលាពាណិជ្ជកម្មកំពូលនៅបារាំង និងទូទាំងសកលលោក។ បន្ថែមពីលើនេះទៅទៀត លោកក៏ទទួលបានវិញ្ញាបនបត្រឧត្តមភាពផ្នែកគ្រប់គ្រង ពីសាលាពាណិជ្ជកម្ម Harvard នៅសហរដ្ឋអាមេរិក និងវិញ្ញាបនបត្រផ្នែកវិភាគអាជីវកម្ម ពីសាលា Columbia Business School។ លើសពីនេះទៅទៀត លោកក៏ជាសមាជិកនៃ Harvard Business Review Advisory Council ដែលជាសហគមន៍ស្រាវជ្រាវសម្រាប់អ្នកជំនាញអាជីវកម្ម។

**លោក ហុង ឡុងឌី**

**នាយកប្រតិបត្តិសវនកម្មផ្ទៃក្នុង**

លោក ហុង ឡុងឌី មានបទពិសោធន៍ធ្វើការជាច្រើនឆ្នាំនៅក្នុងវិស័យធនាគារ និងនៅក្រុមហ៊ុនគណនេយ្យធំមួយនៅប្រទេសកម្ពុជា។ មុនពេលចូលបម្រើការនៅធនាគារ ស្ថាបនា លោកគឺជាសវនករនៅ PricewaterhouseCoopers ក្នុងប្រទេសកម្ពុជាផ្នែក Assurance and Advisory។ លោកបានបម្រើសេវាដល់អតិថិជនជាច្រើន ជាពិសេសផ្នែកឧស្សាហកម្មទូរគមនាគមន៍ និងធនាគារ។ នៅឆ្នាំ២០១៣ លោក ឡុងឌី ចូលបម្រើការនៅម៉ារ៉ូហាន់ ធនាគារ ជប៉ុន ជាប្រធានសវនកម្មផ្ទៃក្នុងរហូតដល់ការរួមបញ្ចូលគ្នានៅឆ្នាំ២០១៦ ជាធនាគារ ស្ថាបនា។ តាំងពីឆ្នាំ២០១៦ លោកបានដឹកនាំកិច្ចការងារផ្សេងៗរួមមាន ផ្នែកគ្រប់គ្រងហានិភ័យ និងការអនុលោមប្រតិបត្តិការ ផ្នែកហានិភ័យទីផ្សារ ព្រមទាំងផ្នែកសវនកម្មផ្ទៃក្នុង។ លោក ឡុងឌី ទទួលបានបរិញ្ញាបត្ររដ្ឋបាលពាណិជ្ជកម្ម ពីវិទ្យាស្ថានបច្ចេកវិទ្យានិងគ្រប់គ្រង ព្រមទាំងវិញ្ញាបនបត្រ CAT និងACCA សមាគមអ្នកជំនាញគណនេយ្យACCA និងវិញ្ញាបនបត្រអ្នកជំនាញផ្នែកគ្រប់គ្រងហានិភ័យ ពីសាលាហិរញ្ញវត្ថុ និងគ្រប់គ្រង Frankfurt នៅប្រទេសអាល្លឺម៉ង់។ លោកក៏ធ្លាប់ជាសមាជិកថ្នាក់ FCCA នៃស្ថាប័នACCA ព្រមទាំងបច្ចុប្បន្នជាសមាជិកនៃ IIAP និង KICPAA ផងដែរ។

**លោក ណាក់ ពេជ្រកោសា**

**នាយកប្រតិបត្តិបច្ចេកវិទ្យាព័ត៌មាន**

លោក ណាក់ ពេជ្រកោសា មានបទពិសោធន៍បច្ចេកវិទ្យាជាង ២០ ឆ្នាំជាមួយក្រុមហ៊ុនអន្តរជាតិ និងវិទ្យាស្ថានហិរញ្ញវត្ថុ។ មុននឹងចូលបម្រើការនៅធនាគារ ស្ថាបនា គាត់ជាប្រធានផ្នែកព័ត៌មានវិទ្យានៅធនាគារ J Trust Royal។ លោកបានធ្វើការនៅធនាគារ ANZ និងធនាគារ J Trust Royal អស់រយៈពេល ៨ ឆ្នាំ។ លោក កោសា ទទួលបានអនុបណ្ឌិតផ្នែករដ្ឋបាលពាណិជ្ជកម្ម ពីសាលកវិទ្យាល័យន័រតុន និងបរិញ្ញាបត្រផ្នែកព័ត៌មានសេដ្ឋកិច្ច ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ។ លោកក៏ទទួលបានវិញ្ញាបនបត្រអន្តរជាតិនៅ ITIL COBIT CPISI អ្នកដឹកនាំការអនុវត្ត ISMS ISO 2001:2013 និងតម្រូវការ QMS ISO 9001:2015។

**លោក កុយ ចំរើនវិជ្ជា**

**នាយកប្រតិបត្តិ ប្រតិបត្តិការឥណទាន**

លោក កុយ ចំរើនវិជ្ជា មានបទពិសោធន៍បម្រើការងារក្នុងវិស័យធនាគាររយៈពេលជាង ១៦ ឆ្នាំ ហើយមុនពេលចូលបម្រើការងារនៅធនាគារ ស្ថាបនា លោកក៏បានបម្រើការងារនៅធនាគារ វឌ្ឍនៈ អស់រយៈពេលជាង ៨ ឆ្នាំ។ លោកបានចូលបម្រើការងារជាមួយធនាគារ ស្ថាបនា ជាអនុប្រធាននាយកដ្ឋានឥណទានក្នុងខែកញ្ញា ឆ្នាំ២០១៥ ក្រោយមកលោកត្រូវបានតែងតាំងជា នាយកដ្ឋានប្រតិបត្តិការឥណទាននៅខែមេសា ឆ្នាំ២០១៨ ដោយបានគ្រប់គ្រងផ្នែកជាច្រើន ដូចជាផ្នែកការវិភាគ និងវាយតម្លៃឥណទានខ្នាតតូច និងមធ្យម និងឥណទានពាណិជ្ជកម្ម ផ្នែករដ្ឋបាលឥណទាន និងផ្នែកវាយតម្លៃទ្រព្យបញ្ចាំ។ អស់ជាច្រើនឆ្នាំកន្លងមកនេះ លោកបានដឹកនាំផ្នែកឥណទាន និងសម្រេចបាននូវលទ្ធផលដ៏គាប់ប្រសើរជាច្រើនផងដែរ។ លោកបានដឹកនាំក្រុមការងារគ្រប់គ្រងគម្រោងបានដោយជោគជ័យក្នុងការបង្កើត និងកំណត់ស្តង់ដារនៃផលិតផលឥណទាន និងមាត្រដ្ឋាននៅក្នុងប្រព័ន្ធធនាគារស្នូល និងអភិវឌ្ឍន៍នីតិវិធីប្រតិបត្តិការស្តង់ដារគោលនយោបាយ កំណែទម្រង់ប្រតិបត្តិការ និងធ្វើឱ្យមានស្វ័យប្រវត្តិកម្ម។ លោកក៏បានដឹកនាំក្រុមការងាររដ្ឋបាលឥណទាន ដើម្បីកែលម្អគុណភាពទិន្នន័យនៅក្នុងប្រព័ន្ធធនាគារស្នូល ដែលធ្វើឱ្យធនាគារ ស្ថាបនា បានទទួលពានរង្វាន់គុណភាពទិន្នន័យពីក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី (ស៊ីប៊ីស៊ី) ក្នុងខែតុលា ឆ្នាំ២០១៧។ បច្ចុប្បន្ន លោកត្រូវបានតែងតាំងជានាយកប្រតិបត្តិ ប្រតិបត្តិការឥណទាននៃធនាគារ ស្ថាបនា ក្នុងខែឧសភា ឆ្នាំ២០២២។ លោក វិជ្ជា បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្មជំនាញគ្រប់គ្រង នៅសាកលវិទ្យាល័យន័រតុន ក្នុងឆ្នាំ២០១០ និងទទួលបានបរិញ្ញាបត្រផ្នែកគ្រប់គ្រង ក្នុងឆ្នាំ២០០៧។

**អ្នកស្រី ឈឹម សំអុល**

**នាយិកាប្រតិបត្តិ ធនធានមនុស្ស និងនីតិកម្ម**

អ្នកស្រី ឈឹម សំអុល គឺជាសមាជិកដ៏សំខាន់មួយរូបនៃគណៈគ្រប់គ្រងជាន់ខ្ពស់ ធនាគារ ស្ថាបនា ដែលនាពេលបច្ចុប្បន្ននេះ អ្នកស្រីមានតួនាទីជានាយិកាប្រតិបត្តិ ធនធានមនុស្ស និងនីតិកម្ម ដោយគ្រប់គ្រងនាយកដ្ឋានចំនួន ០២ រួមមាន៖ នាយកដ្ឋានធនធានមនុស្ស និងនាយកដ្ឋាននីតិកម្ម/លេខាធិការដ្ឋាន។ សូមបញ្ជាក់ដែរថា អ្នកស្រី សំអុល ក៏ជាមេធាវីដែលជាសមាជិកនៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។ ជាមួយនឹងបទពិសោធន៍ក្នុងរយៈពេល ១០ ឆ្នាំ ក្នុងការផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ប្រកបដោយគុណភាព ក៏ដូចជាការទទួលបានទំនុកចិត្តខ្ពស់ពីសំណាក់អតិថិជនទាំងក្នុងស្រុក និងក្រៅស្រុក ដោយរួមមានទាំងការផ្តល់ប្រឹក្សាផ្នែកពាណិជ្ជកម្មរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ដែលលើសពីនេះ អ្នកស្រីក៏ជាមេធាវីមួយរូប ដែលទទួលស្គាល់ពីនិយ័តករមូលបត្រកម្ពុជា ក្នុងការប្រឹក្សាយោបល់ផ្នែកច្បាប់ក្នុងវិស័យមូលបត្រកម្ពុជាផងដែរ។

ចំពោះប្រវត្តិការសិក្សា អ្នកស្រី សំអុល គឺជាបេក្ខបណ្ឌិតដែលកំពុងសិក្សានៅរាជបណ្ឌិត្យសភាកម្ពុជា និងទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិភូមិបាល ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាល័យ Lumière Lyon 3។ អ្នកស្រី ក៏ជាអតីតនិស្សិតដែលទទួលបាន "អាហារូបករណ៍រាជរដ្ឋាភិបាលកម្ពុជា" ក្នុងកំឡុងឆ្នាំ២០០៤-២០០៨ សម្រាប់បរិញ្ញាបត្រផ្នែកច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសាកលវិទ្យាល័យ Lumière Lyon 2។ លើសពីនេះ អ្នកស្រីក៏ទទួលបានបរិញ្ញាបត្រផ្នែកបង្រៀនភាសាអង់គ្លេសជាភាសាបរទេស (TEFL) ពីវិទ្យាស្ថានភាសាបរទេស (IFL) នៃ

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

បន្ថែមពីប្រវត្តិសិក្សាខាងលើ អ្នកស្រី សំអុល ទើបតែទទួលបានគុណវុឌ្ឍិពី CEDR Mediator នៃចក្រភពអង់គ្លេសនៅដើមឆ្នាំ២០២២ ហើយអ្នកស្រីក៏ជាសមាជិករបស់ SIArb (Singapore Institute of Arbitration) តាំងពីឆ្នាំ២០១៧ ក៏ដូចជាអតីតនិស្សិតស្រាវជ្រាវនៅសាកលវិទ្យាល័យ National University of Singapore ក្នុងឆ្នាំ២០១០[13]។

## ៣.២ យុទ្ធសាស្ត្រនៃការគ្រប់គ្រងហានិភ័យរបស់ធនាគារ ស្ថាបនា

ហានិភ័យឥណទាន សំដៅដល់ហានិភ័យដែលសមភាគីមិនអាចអនុវត្តបានតាមកាតព្វកិច្ចដែលមានចែងក្នុងកិច្ចសន្យា។ ក្រៅពីកម្ចីដែលជាប្រភពចម្បងនៃហានិភ័យឥណទាន ប្រតិបត្តិការផ្សេងៗដែលមាននៅក្នុងបញ្ជីកាធនាគារ (Banking Book) និងបញ្ជីកាសម្រាប់ជួញដូរ (Trading Book) ទាំងក្នុង និងក្រៅតារាងតុល្យការ ក៏ជាប្រភពនៃហានិភ័យឥណទានដែរ។ គ្រឹះស្ថានអាចប្រឈមនឹងហានិភ័យឥណទាន ដែលអាចកើតមកពីឧបករណ៍ហិរញ្ញវត្ថុនានាក្រៅពីប្រាក់កម្ចីដូចជា ហិរញ្ញប្បទានពាណិជ្ជកម្ម ការសន្យាផ្តល់ឥណទាន ការធ្វើស្ទីការ (Acceptances) និងការធានាប្រតិបត្តិការអន្តរធនាគារ ប្រតិបត្តិការទូទាត់ ប្រតិបត្តិការប្តូរប្រាក់ សញ្ញាបណ្ណ មូលបត្រកម្មសិទ្ធិ និងឧបករណ៍និស្សន្ទជាដើម។

ការគ្រប់គ្រងហានិភ័យឥណទានបានដើរតួនាទីយ៉ាងសំខាន់ក្នុងសុខភាពហិរញ្ញវត្ថុ និងស្ថិរភាពនៃអាជីវកម្មនៅទូទាំងស្ថាប័ន។ វាពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណ ការវាយតម្លៃ និងការកាត់បន្ថយហានិភ័យដែលអាចកើតមានទាក់ទងទៅនឹងការពង្រីកឥណទានដល់អតិថិជន ឬសមភាគី។ ការគ្រប់គ្រងហានិភ័យឥណទានប្រកបដោយប្រសិទ្ធភាពអាចឱ្យស្ថាប័នធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹង ការពារទ្រព្យសម្បត្តិ រក្សាលំហូរសាច់ប្រាក់ឱ្យមានដំណើរការល្អ ការពារប្រឆាំងនឹងការខាតបង់ហិរញ្ញវត្ថុ និងប្រសិទ្ធភាពរបស់ស្ថាប័ន។

ការគ្រប់គ្រងហានិភ័យឥណទានប្រកបដោយប្រសិទ្ធភាព ស្ថាប័នអាចបង្កើនប្រសិទ្ធភាពការអនុវត្តការផ្តល់ឥណទានរបស់ពួកគេ រក្សាទំនាក់ទំនងល្អជាមួយអតិថិជន និងធានាសុខុមាលភាពហិរញ្ញវត្ថុរបស់ខ្លួនបាន។ ហានិភ័យឥណទានទាក់ទងនឹងការបាត់បង់ហិរញ្ញវត្ថុដែលអាចកើតមាននៅពេលដែលអ្នកខ្ចីមិនសងប្រាក់កម្ចី។ វាពាក់ព័ន្ធនឹងហានិភ័យនៃអ្នកឱ្យខ្ចីមិនទទួលបានចំនួនទឹកប្រាក់ដើម និងការប្រាក់ដែលជំពាក់ដែលនាំឱ្យមានការរំខានដល់លំហូរសាច់ប្រាក់ និងការចំណាយបន្ថែមសម្រាប់ការប្រមូលបំណុល។

ធនាគារ ស្ថាបនា ទទួលស្គាល់ថាការគ្រប់គ្រងហានិភ័យជាធាតុសំខាន់មួយសម្រាប់ការត្រួតពិនិត្យ និងការគាំទ្រទូទៅដើម្បីសម្រេចឱ្យបាននូវយុទ្ធសាស្ត្រ និងគោលដៅរបស់ធនាគារ។ តាមរយៈការការពារថ្នាក់ទីពីរ នាយកដ្ឋានគ្រប់គ្រងហានិភ័យបានផ្តល់នូវទស្សនៈវិស័យវិភាគហានិភ័យដើម្បីការពារផលប្រយោជន៍របស់ធនាគារពីសកម្មភាពអាជីកម្មដែលអាចប៉ះពាល់ក្នុងដំណើរការអាជីវកម្មប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស និងគំនិតផ្តួចផ្តើមអាជីវកម្ម។

ធនាគារ ស្ថាបនា បានអនុវត្តនូវក្របខ័ណ្ឌរីសអាប់តែថាយ (Risk Appetite) ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការត្រួតពិនិត្យសកម្មភាពហានិភ័យនានា ដែលសមស្របទៅនឹងរីសអាប់តែថាយ

[13] Sathapana Bank. (2023). Annual Report 2023 ទំព័រទី២០ ១៩២ទំព័រ

(Risk Appetite) និងវិសថលើវែន (Risk Tolerance) ដែលធនាគារ ស្ថាបនា មានឆន្ទៈទទួលយកក្រោមលក្ខខណ្ឌដែលអាចគ្រប់គ្រងដំណើរការបាន។

បន្ថែមពីលើនេះទៀត នាយកដ្ឋានគ្រប់គ្រងហានិភ័យរបស់ធនាគារ ស្ថាបនា បានធ្វើការតាមដានយ៉ាងល្អិតល្អន់ និងម៉ត់ចត់ទៅលើការគំរាមគំហែង និងឱកាសផ្សេងៗដែលចេញពីមជ្ឈដ្ឋានខាងក្រៅរួមមានសេដ្ឋកិច្ច វិស័យធនាគារ ទីផ្សារប្រកួតប្រជែង នយោបាយ សង្គម ការអភិវឌ្ឍន៍នៃបច្ចេកវិទ្យា គ្រោះធម្មជាតិ និងជូនដំណឹងទៅកាន់ក្រុមប្រឹក្សាភិបាល និងគ្រប់បណ្តានាយកដ្ឋានពាក់ព័ន្ធ ដើម្បីចាត់វិធានការឱ្យបានទាន់ពេលវេលា។

- ➢ បញ្ហាប្រឈមចំពោះការគ្រប់គ្រងហានិភ័យឥណទាន៖
- ការគ្រប់គ្រងទិន្នន័យគ្មានប្រសិទ្ធភាព៖ ភាពលំបាកក្នុងការចូលប្រើទិន្នន័យដែលពាក់ព័ន្ធមិនទាន់ពេលវេលាដែលនាំឱ្យពន្យារពេលក្នុងដំណើរការសម្រេចចិត្ត និងបញ្ហាប្រឈមក្នុងប្រតិបត្តិការ។
- កង្វះក្របខណ្ឌគំរូហានិភ័យដែលទូលំទូលាយ៖ បើគ្មានក្របខណ្ឌដែលមានភាពជាក់លាក់ និងរឹងមាំ ធនាគារអាចពិបាកក្នុងការបង្កើតរង្វាស់ហានិភ័យដ៏ស្មុគស្មាញ និងការយល់ដឹងទូលំទូលាយទៅលើហានិភ័យរបស់ស្ថាប័នទាំងមូល។
- ដំណើរការការងារស្មុគ និងមិនមានប្រសិទ្ធភាព៖ អ្នកវិភាគប្រឈមមុខនឹងឧបសគ្គក្នុងការកែតម្រូវប៉ារ៉ាម៉ែត្រគំរូប្រកបដោយប្រសិទ្ធភាព បណ្តាលឱ្យមានការធ្វើស្ទួនការខិតខំប្រឹងប្រែងដែលមិនចាំបាច់ និងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អនុបាតប្រសិទ្ធភាពរបស់ធនាគារ។
- ឧបករណ៍គ្រប់គ្រងហានិភ័យមិនគ្រប់គ្រាន់៖ ការខ្វះខាតនៃដំណោះស្រាយការគ្រប់គ្រងហានិភ័យដែលមានភាពរឹងមាំ និងច្បាស់លាស់ រារាំងធនាគារពីការកំណត់ការប្រមូលផ្តុំផលប័ត្រ ឬធ្វើការវាយតម្លៃផលប័ត្រទាន់ពេលវេលា ដោយកំណត់សមត្ថភាពរបស់ពួកគេក្នុងការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព។
- នីតិវិធីរាយការណ៍ស្មុគស្មាញ៖ ការពឹងផ្អែកទៅលើប្រព័ន្ធរាយការណ៍ដែលមានមូលដ្ឋានលើសៀវភៅដែលបានដាក់បន្ទុកលើសទម្ងន់លើអ្នកវិភាគ និងនាយកដ្ឋានព័ត៌មានវិទ្យា ដែលរារាំងប្រសិទ្ធភាព។
- ➢ កត្តាដែលបង្កឱ្យមានហានិភ័យឥណទាន៖
- កត្តាខាងក្នុង ៖ កើតឡើងដោយសារអ្នកឱ្យខ្ចី និងបុគ្គលិកពាក់ព័ន្ធមិនយកចិត្តទុកដាក់ទទួលខុសត្រូវក្នុងការងាររបស់ខ្លួន ដូចជាភ្នាក់ងារឥណទានវាយតម្លៃប្រាក់កម្ចីមិនត្រឹមត្រូវ សិក្សាមិនបានល្អិតល្អន់ពីប្រវត្តិ អត្តចរិត លំហូរសាច់ប្រាក់ និងលទ្ធភាពសងរបស់អ្នកខ្ចីរួមទាំងហានិភ័យពាក់ព័ន្ធផ្សេងៗ។ កត្តានេះអាចគ្រប់គ្រងបានដោយការពង្រឹងស្មារតីទទួលខុសត្រូវអនុវត្តទៅតាមគោលការណ៍ និងនីតិវិធីស្តីអំពីឥណទាន។
- កត្តាខាងក្រៅ៖ គឺជាកត្តាដែលជះឥទ្ធិពលដល់ការសងប្រាក់ដែលកើតឡើង ដោយមិនអាចធ្វើការគ្រប់គ្រងបាន។ កត្តានេះអាចបង្កឡើងដោយគ្រោះចៃដន្យ ដូចជាគ្រោះថ្នាក់អគ្គីភ័យ គ្រោះមហន្តរាយ ឬឧប្បទ្ទវហេតុផ្សេងៗ។ ថ្វីបើកត្តានេះមិនអាចគ្រប់គ្រងបាននោះ ក៏ប៉ុន្តែផ្អែកលើការឈ្លាសវៃ និងបទពិសោធន៍របស់ភ្នាក់ងារទទួលខុសត្រូវបញ្ហាអាចនឹងត្រូវកាត់បន្ថយបាន។

### ៣.២.១ ការស្វែងយល់សញ្ញាណហានិភ័យឥណទាន

ហានិភ័យឥណទានគឺជាកត្តាសំខាន់មួយដែលធនាគារ ស្ថាបនា ត្រូវតែគ្រប់គ្រង និងត្រួតពិនិត្យយ៉ាងម៉ត់ចត់ ដើម្បីបង្ការការបាត់បង់ចំណូលក្នុងការប្រគល់ឥណទានឱ្យអតិថិជន។ សញ្ញាណហានិភ័យឥណទានជាសកម្មភាពនៃការស្វែងរក និងវាយតម្លៃសកម្មភាព ឬស្ថានភាពណាដែលអាចបង្ហាញថាអតិថិជនមានភាពខ្សោយក្នុងការបង់វិញ។ ជំហានដំបូងក្នុងការចាត់ចែងគ្រប់គ្រងហានិភ័យឥណទាន គឺចាំបាច់ត្រូវស្វែងរកឱ្យឃើញ និងកំណត់ថាមានសញ្ញាណអ្វីខ្លះ មានទំហំប៉ុណ្ណាដែលអាចនឹងកើតឡើងក្នុងដំណើរប្រតិបត្តិការរបស់ស្ថាប័ន។ ជាធម្មតារាល់ផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលបានផ្តល់ឱ្យអតិថិជនរមែងមានហានិភ័យជាច្រើនអាចកើតមានឡើង។ ឧទាហរណ៍ដូចជា៖ ការទូទាត់យឺតៗ ការកើនឡើងនៃបំណុល ការធ្លាក់ចុះនៃចំណូល ឬបញ្ហាផ្ទាល់ខ្លួនអាស្រ័យលើសេដ្ឋកិច្ចសង្គម

ធនាគារ ស្ថាបនា បានប្រើប្រាស់ឧបករណ៍ និងវិធីសាស្រ្តបច្ចេកទេសដូចជា៖ ការវាយតម្លៃឥណទាន (Credit Scoring) ការត្រួតពិនិត្យឥណទាន (Credit Monitoring) និងការប៉ាន់ស្មានហានិភ័យដោយប្រើប្រាស់ប្រព័ន្ធ BI (Business Intelligence)។ ការស្វែងយល់សញ្ញាណហានិភ័យឥណទានត្រឹមត្រូវជួយឱ្យធនាគារស្ថាបនា ប្រកាន់ខ្ជាប់សុវត្ថិភាពហិរញ្ញវត្ថុ និងបន្តផ្តល់សេវាឥណទានបានយ៉ាងប្រសើរ។

### ៣.២.២ ការតាមដាន និងការចាត់ថ្នាក់ហានិភ័យឥណទាន

#### ក. ការតាមដានហានិភ័យឥណទាន

ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់របស់ធនាគារ ស្ថាបនា ត្រូវទទួលខុសត្រូវក្នុងការធានាថា ការវាយតម្លៃហានិភ័យឥណទាន ការត្រួតពិនិត្យ និងការកំណត់សំវិធានធន ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីធានាឱ្យមានសំវិធានធនសម្រាប់ហ្វាស៊ីលីធី (Facilities) ដែលមានអ៊ីមកែរមិន (Impairment) ក្នុងកម្រិតមួយសមស្រប និងគ្រប់គ្រាន់។ ក្រុមប្រឹក្សាភិបាលក៏ត្រូវធានាលើការអនុវត្តចំពោះការវាយតម្លៃហានិភ័យឥណទាន ការត្រួតពិនិត្យ និងដំណើរការឱ្យស្របតាម ចរិតលក្ខណៈ ភាពស្មុគស្មាញ និងទំហំនៃសកម្មភាពរបស់ស្ថាប័ន។

ក្រុមប្រឹក្សាភិបាលធនាគារ ស្ថាបនា ត្រូវអនុម័តក្របខ័ណ្ឌ និងគោលនយោបាយសម្រាប់ការវាយតម្លៃហានិភ័យឥណទាន ការត្រួតពិនិត្យ និងការកំណត់សំវិធាន។ គោលនយោបាយនេះ ក៏ត្រូវកំណត់យន្តការតាមដាន និងរាយការណ៍អំពីវិធានការប្រមូលមកវិញដែលស្ថាប័នត្រូវអនុវត្ត។

ក្រុមប្រឹក្សាភិបាលត្រូវធានាថា៖

1. នីតិវិធី និងដំណើរការអាចឱ្យធនាគារ ស្ថាបនា កំណត់បានជាមុននូវការធ្វើចំណាត់ថ្នាក់ ការវាយតម្លៃ និងការដោះស្រាយបញ្ហាគុណភាពឥណទាន
2. ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងជាន់ខ្ពស់ទទួលបានព័ត៌មានគ្រប់គ្រាន់អំពីគុណភាពឥណទាន និងសំវិធានធនដែលពាក់ព័ន្ធទៅនឹងឥណទានឱ្យបានទៀងទាត់ និងតាមពេលកំណត់
3. ការវិនិច្ឆ័យលើមុខងារត្រួតពិនិត្យឡើងវិញ និងគ្រប់គ្រងធ្វើឡើងស្របតាមគោលនយោបាយ និងនីតិវិធីរបស់ធនាគារ ស្ថាបនា
4. ការត្រួតពិនិត្យផ្ទៃក្នុងលើការវាយតម្លៃហានិភ័យឥណទាន និងការធ្វើសំវិធានធនធ្វើឡើងឱ្យត្រឹមត្រូវ និងទៀងទាត់ ដោយបុគ្គលដែលមានឯករាជ្យភាពពីប្រតិបត្តិការឥណទានរបស់ធនាគារ ស្ថាបនា។

ក្រុមប្រឹក្សាភិបាលធនាគារ ស្ថាបនា ត្រូវពិនិត្យឡើងវិញលើគោលនយោបាយ និងនីតិវិធីយ៉ាងតិចមួយឆ្នាំម្តង ដើម្បីធានាថាគោលនយោបាយ និងនីតិវិធីទាំងនេះមានសង្គតិភាពជាមួយនឹងសកម្មភាព ស្ថានភាពសេដ្ឋកិច្ច អតិថិជន និងហានិភ័យឥណទានរបស់ស្ថាប័ន។

**ខ. ការចាត់ថ្នាក់ហានិភ័យឥណទាន**

ប្រព័ន្ធគ្រប់គ្រងហានិភ័យឥណទាន ដែលអនុម័តដោយក្រុមប្រឹក្សាភិបាលធនាគារ ស្ថាបនា ត្រូវរួមបញ្ចូលប្រព័ន្ធចាត់ថ្នាក់ហានិភ័យឥណទានដែលបានកំណត់ច្បាស់លាស់ ដោយត្រូវកំណត់ការទទួលខុសត្រូវលម្អិតរបស់បុគ្គលពាក់ព័ន្ធនៅក្នុងធនាគារ ស្ថាបនា។

ធនាគារ ស្ថាបនា បានរៀបចំដំណើរការចាត់ថ្នាក់ហ្វាស៊ីបើធីឱ្យមានលក្ខណៈជាប្រព័ន្ធ និងមានសង្គតិភាពដោយផ្អែកលើមូលដ្ឋានហានិភ័យឥណទាន។ ក្នុងគោលបំណងនេះ ធនាគារ ស្ថាបនា មានប្រព័ន្ធចាត់ថ្នាក់ហានិភ័យឥណទាន ដែលសមស្របទៅនឹងកម្រិតហានិភ័យពាក់ព័ន្ធនឹង ចរិតលក្ខណៈ ភាពស្មុគស្មាញ និងទំហំនៃហ្វាស៊ីលីធីរបស់ធនាគារ ស្ថាបនា ។ ហ្វាស៊ីលីធីធំៗនឹងត្រូវធ្វើចំណាត់ថ្នាក់ដោយផ្អែកតាមវិធីសាស្ត្រវាយតម្លៃហានិភ័យ ឥណទានដែលមានលក្ខណៈពិស្តារ ចំណែកឯហ្វាស៊ីលីធីតូចៗដែលមានចរិតលក្ខណៈប្រហាក់ប្រហែលគ្នា និងស្ថិតក្រោមការគ្រប់គ្រងតែមួយ អាចត្រូវបានចាត់ថ្នាក់ដោយផ្អែកទៅតាមវិធីសាស្ត្រចាត់ថ្នាក់ឥណទាននេះ ឬអាចចាត់ថ្នាក់តាមប្រវត្តិហ្វាស៊ីលីធីខាតបង់។ ការចាត់ថ្នាក់ហានិភ័យឥណទានប្រកបដោយភាពជឿជាក់បានជួយក្នុងការវាយតម្លៃហ្វាស៊ីលីធីដោយប្រុងប្រយ័ត្ន និងកំណត់ការធ្វើសំវិធានធនគ្រប់គ្រាន់ចំពោះហ្វាស៊ីលីធីដែលមានអ៊ីមកែ (Impaired Facilities)។

ការចាត់ថ្នាក់ហានិភ័យឥណទាន ត្រូវបានធ្វើឡើងយ៉ាងលម្អិត ច្បាស់លាស់ និងគ្រប់គ្រាន់ទៅតាមកម្រិតនៃហានិភ័យឥណទាន។ ធនាគារ ស្ថាបនា បានបែងចែកហ្វាស៊ីលីធីតាមប្រភេទ ដោយផ្អែកលើមូលដ្ឋាននៃការវាយតម្លៃលើសមត្ថភាពទូទាត់សងរបស់សមាជិកតាមរយៈប្រភពចំណូលជាក់ស្តែង។

លក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃសមត្ថភាពទូទាត់សងរបស់សមាជិក ត្រូវមានចំណុចយ៉ាងតិចដូចខាងក្រោម៖

1. ប្រវត្តិទូទាត់សង
2. ស្ថានភាពហិរញ្ញវត្ថុរបស់សមាជិកនាពេលបច្ចុប្បន្ន និងការព្យាករណ៍
3. ចក្ខុវិស័យអាជីវកម្ម និងការព្យាករណ៍លំហូរសាច់ប្រាក់ដោយផ្អែកលើការសន្មត ដែលមានលក្ខណៈជាក់ស្តែង និងប្រុងប្រយ័ត្ន
4. លទ្ធភាព និងឆន្ទៈទូទាត់សង
5. ស្ថានភាពសេដ្ឋកិច្ច
6. គុណភាពនៃសំណុំឯកសារ។

**៣.២.៣ ការវិភាគ និងការវាស់វែងហានិភ័យឥណទាន**

ធនាគារ ស្ថាបនា ធ្វើការវាយតម្លៃលទ្ធភាពនៃការខកខានមិនបំពេញកាតព្វកិច្ចរបស់សមាជិក ដោយប្រើប្រាស់ឧបករណ៍កំណត់ផ្ទៃក្នុង។

គណៈកម្មាធិការឥណទានក្នុងស្រុក គឺត្រូវមានទំនួលខុសត្រូវក្នុងការកំណត់កម្រិតគោលនយោបាយហានិភ័យ។

កម្រិតហានិភ័យត្រូវបានពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំ និងក្នុងករណីដែល (i) មានការផ្លាស់ប្តូរលក្ខខណ្ឌឥណទានដែលរួមបញ្ចូលផងដែរនូវការពន្យារពេល (ii) ការទូទាត់សងមិនទៀងទាត់ ឬការគេចវេសដោយចេតនា និង (iii) ព័ត៌មានមិនល្អទាក់ទងនឹងអ្នកសុំខ្ចី ឬប្រតិបត្តិការ។

ធនាគារ ស្ថាបនា អនុវត្តវិធីសាស្ត្របីដំណាក់កាល ដោយផ្អែកលើការផ្លាស់ប្តូរគុណភាពឥណទានចាប់ពីមានការទទួលស្គាល់ដំបូង។ សំវិធានធនលើឱនភាពតម្លៃនឹងត្រូវធ្វើឡើងដោយផ្អែកលើវិធីសាស្ត្របីដំណាក់កាលដូចខាងក្រោមដែលឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរគុណភាពឥណទាននៃឧបករណ៍ហិរញ្ញវត្ថុ ចាប់តាំងពីមានការទទួលស្គាល់ដំបូង៖

(i) ដំណាក់កាលទី ១៖ ECL ១២ខែ - មិនមានឱនភាពតម្លៃឥណទាន

ចំពោះការប្រឈមនឹងហានិភ័យ ដែលមិនមានការកើនឡើងគួរឱ្យកត់សម្គាល់នៃហានិភ័យឥណទានតាំងពីការទទួលស្គាល់ដំបូង ហើយមិនមានឱនភាពតម្លៃឥណទាននោះទេ ហើយ ECL ដែលមានទំនាក់ទំនងនឹងប្រូបាប៊ីលីតេ (Probability) នៃព្រឹត្តិការណ៍លំនាំដើម ដែលកើតឡើងក្នុងរយៈពេល ១២ខែបន្ទាប់នឹងត្រូវបានទទួលស្គាល់។

(ii) ដំណាក់កាលទី ២៖ ECL ពេញមួយវដ្ត - មិនមានឱនភាពតម្លៃឥណទាន

ចំពោះការប្រឈមនឹងហានិភ័យ ដែលមានការកើនឡើងគួរឱ្យកត់សម្គាល់នៃហានិភ័យឥណទានតាំងពីការទទួលស្គាល់ដំបូង ប៉ុន្តែវាមិនមានឱនភាពតម្លៃឥណទាននោះទេ ECL ពេញមួយជីវិត នឹងត្រូវបានទទួលស្គាល់។

(iii) ដំណាក់កាលទី ៣៖ ECL ពេញមួយវដ្ត ឱនភាពតម្លៃឥណទាន

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃជាឱនភាពតម្លៃឥណទាននៅពេលមានព្រឹត្តិការណ៍មួយ ឬច្រើនដង ធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់លំហូរសាច់ប្រាក់នាពេលអនាគតដែលបានរំពឹងទុករបស់ទ្រព្យសកម្មនោះ។ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ដែលមានឱនភាពតម្លៃឥណទាននោះទេ ECL ពេញមួយជីវិតនឹងត្រូវបានទទួលស្គាល់។

| ដំណាក់កាល | ស្ថានភាពនៃហានិភ័យឥណទាន | សូចនាករលំនាំដើម |
|---|---|---|
| ១ | ១២-ខែ ECL - មិនមានឱនភាពតម្លៃឥណទាន | ០ ដល់ ៣០ DPD |
| ២ | ពេញ១វដ្តនៃ ECL - មិនមានឱនភាពតម្លៃឥណទាន | ៣១ ដល់ ៩០ DPD |
| ៣ | ពេញ១វដ្តនៃ ECL - ឱនភាពតម្លៃឥណទាន | លើសពី ៩០ DPD |
| | | បានរៀបចំ និងកំណត់ពេលវេលាឡើងវិញ |
| | | លំនាំដើមចាំបាច់ |
| | | លំនាំដើមដែលពាក់ព័ន្ធ |

**៣.២.៤ ការត្រួតពិនិត្យ និងការគ្រប់គ្រងហានិភ័យឥណទាន**

ធនាគារ ធ្វើប្រតិបត្តិការ និងផ្តល់ឥណទានជូនអតិថិជន និងបុរេប្រទានចំពោះរូបវន្តបុគ្គល ឬសហគ្រាស នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារ គ្រប់គ្រងវិសាលភាព និងត្រួតពិនិត្យនូវការប្រមូលផ្តុំ

ហានិភ័យឥណទាន នៅពេលណាដែលហានិភ័យទាំងនោះត្រូវបានកំណត់អត្តសញ្ញាណ។ ហានិភ័យធំៗដែលកំណត់ដោយធនាគារជាតិ នៃកម្ពុជា គឺជាហានិភ័យទាំងឡាយណាដែលផ្តល់ឱ្យអត្ថគាហកតែមួយដែលមានអនុបាតលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ។

យោងទៅតាមប្រកាសរបស់ធនាគារជាតិ នៃកម្ពុជាលេខ ធ៧-០៦-២២៦ ធនាគារ តម្រូវឱ្យរក្សាឱ្យបានគ្រប់ពេលវេលានូវអនុបាតអតិបរិមាចំនួន ២០% រវាងហានិភ័យធំៗសរុប ដែលកើតចេញពីប្រតិបត្តិការជាមួយនឹងអត្ថគាហកឯកត្តបុគ្គលម្នាក់ៗ និងមូលនិធិផ្ទាល់សុទ្ធរបស់ខ្លួន។ ចំនួនសរុបនៃហានិភ័យធំៗទាំងអស់មិនត្រូវលើសពី ៣០០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារឡើយ។

ហានិភ័យឥណទានទាក់ទងនឹងការបាត់បង់ហិរញ្ញវត្ថុដែលអាចកើតមានឡើងនៅពេលដែលអ្នកខ្ចីមិនសងប្រាក់កម្ចី។ វាពាក់ព័ន្ធទៅនឹងហានិភ័យនៃអ្នកឱ្យខ្ចីមិនទទួលបានចំនួនទឹកប្រាក់ដើម និងការប្រាក់ដែលជំពាក់ ដែលជាហេតុនាំឱ្យមានការរំខានទៅដល់លំហូរសាច់ប្រាក់ និងការចំណាយបន្ថែមសម្រាប់ការប្រមូលបំណុល។

អ្នកឱ្យខ្ចីអាចកាត់បន្ថយហានិភ័យឥណទាន ដោយការវាយតម្លៃទិដ្ឋភាពផ្សេងៗនៃភាពសក្តិសមនៃឥណទានរបស់អ្នកខ្ចី រួមទាំងកាតព្វកិច្ចបំណុលដែលមានស្រាប់ និងប្រាក់ចំណូលរបស់ពួកគេ។

ខណៈពេលដែលវាមិនអាចទៅរួចទេក្នុងការទស្សន៍ទាយ ដោយប្រាកដថាអ្នកខ្ចីណានឹងខកខាន ការវាយតម្លៃប្រកបដោយប្រសិទ្ធភាព និងការគ្រប់គ្រងហានិភ័យឥណទានអាចកាត់បន្ថយផលប៉ះពាល់នៃការខាតបង់បែបនេះ។

អ្នកឱ្យខ្ចី និងអ្នកវិនិយោគទទួលយកហានិភ័យឥណទានជាថ្នូរនឹងការទទួលបានការទូទាត់ការប្រាក់ពីអ្នកខ្ចី ឬអ្នកចេញកាតព្វកិច្ចបំណុល។ ការទូទាត់ការប្រាក់ទាំងនេះបម្រើជារង្វាន់សម្រាប់ការសន្មត់ហានិភ័យឥណទាន។

- **បញ្ហាប្រឈមចំពោះការគ្រប់គ្រងហានិភ័យឥណទានជោគជ័យ**

ការគ្រប់គ្រងទិន្នន័យគ្មានប្រសិទ្ធភាព៖ ភាពលំបាកក្នុងការចូលប្រើទិន្នន័យដែលពាក់ព័ន្ធក្នុងលក្ខណៈទាន់ពេលវេលាដែលនាំទៅដល់ការពន្យារពេលសំខាន់ៗ និងបញ្ហាប្រឈមក្នុងប្រតិបត្តិការ។

កង្វះក្របខណ្ឌគំរូហានិភ័យដ៏ទូលំទូលាយ៖ បើគ្មានក្របខណ្ឌបង្រួបបង្រួមទេ ធនាគារពិបាកបង្កើតរង្វាស់ហានិភ័យស្មុគស្មាញ និងទទួលបានទិដ្ឋភាពរួមនៃហានិភ័យទូទាំងសហគ្រាស។

ដំណើរការការងារដដែលៗ៖ អ្នកវិភាគប្រឈមមុខនឹងឧបសគ្គក្នុងការកែតម្រូវប៉ារ៉ាម៉ែត្រគំរូប្រកបដោយប្រសិទ្ធភាព ដែលបណ្តាលឱ្យមានការព្យាយាមចម្លងគ្នាដែលមិនចាំបាច់ និងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អនុបាតប្រសិទ្ធភាពរបស់ធនាគារ។

ឧបករណ៍ហានិភ័យមិនគ្រប់គ្រាន់៖ អវត្តមាននៃដំណោះស្រាយការគ្រប់គ្រងហានិភ័យដ៏រឹងមាំរារាំងធនាគារពីការកំណត់ការប្រមូលផ្តុំផលប័ត្រ ឬធ្វើការវាយតម្លៃផលប័ត្រទាន់ពេលវេលា ដោយកំណត់សមត្ថភាពរបស់ពួកគេក្នុងការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព។

នីតិវិធីរាយការណ៍ពិបាក៖ ការពឹងផ្អែកលើប្រព័ន្ធរាយការណ៍ដែលមានមូលដ្ឋានលើសៀវភៅដៃនោះបានដាក់បន្ទុកលើសទម្ងន់លើអ្នកវិភាគ និងនាយកដ្ឋានព័ត៌មានវិទ្យាដែលរារាំងប្រសិទ្ធភាព។

### ៣.២.៥ គោលនយោបាយសំវិធានធន

ចាប់ពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ ធនាគារ ស្ថាបនា តម្រូវឱ្យធ្វើតាមការធ្វើចំណាត់ថ្នាក់ និងសំវិធានធនលើឥណទានដោយអនុលោមទៅតាមប្រកាសលេខ ប៧-០១៧-៣៤៤ ប្រ.ក ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនអ៊ុមកែរមិន និងសារាចរណែនាំលេខ ប៧-០១៨-០០១ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការអនុវត្តទៅតាមប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ុមកែរមិន(កំណត់សម្គាល់លេខ ២.៧)។

➢ **ឥណទានមិនទាន់ហួសកាលកំណត់ និងមិនខាតបង់**

ឥណទានមិនទាន់ហួសកាលកំណត់ និងមិនខាតបង់ជាឥណទានមានគុណភាពល្អ ដែលមិនមានបទពិសោធន៍នៃការខាតបង់។ ឥណទានទាំងនេះត្រូវបានធានាដោយទ្រព្យបញ្ចាំ និងគណៈគ្រប់គ្រងយល់ឃើញថា លទ្ធភាពដែលធ្វើឱ្យឥណទានខាតបង់មានកម្រិតទាប។

➢ **ឥណទានហួសកាលកំណត់ តែមិនទាន់ខាតបង់**

ឥណទានហួសកាលកំណត់ និងមិនទាន់ខាតបង់ជាឥណទានផ្តល់ឱ្យអតិថិជន ដែលកិច្ចសន្យាទូទាត់សងការប្រាក់ ឬប្រាក់ដើមហួសកាលកំណត់លើសពី ១៤ថ្ងៃ តែតិចជាង ៣០ថ្ងៃ លុះត្រាតែមានព័ត៌មានដែលបញ្ជាក់ក្រៅពីនេះ។ ឥណទានហួសកាលកំណត់តែមិនទាន់ខាតបង់ជាឥណទាន ដែលកិច្ចសន្យាទូទាត់ការប្រាក់ ឬប្រាក់ដើមហួសកាលកំណត់លើសពី ៣០ថ្ងៃ តែតិចជាង ១០ថ្ងៃ លុះត្រាតែមានព័ត៌មានដែលបញ្ជាក់ក្រៅពីនេះ។ អនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃកម្ពុជា ឥណទាននេះត្រូវចាត់ថ្នាក់ជាឥណទានឃ្លាំមើលហើយត្រូវធ្វើសំវិធានធនតាមអត្រា ៣%។

➢ **ឱនភាពឥណទានផ្តល់ឱ្យអតិថិជន**

ឥណទានផ្តល់ឱ្យអតិថិជនដែលមានឱនភាព ជាឥណទានផ្តល់ឱ្យអតិថិជន ដែលធនាគារកំណត់ថាមានភស្តុតាងជាក់លាក់ថាមានឱនភាព និងកិច្ចសន្យាការទូទាត់សងការប្រាក់ ឬប្រាក់ដើមហួសកាលកំណត់ ឬមានប្រវត្តិហួសកាលកំណត់លើសពី ១០ថ្ងៃ លុះត្រាតែមានព័ត៌មានដែលបញ្ជាក់ក្រៅពីនេះ។

➢ **ឥណទានរៀបចំឡើងវិញ**

ឥណទានរៀបចំឡើងវិញ ជាឥណទានដែលកិច្ចសន្យាត្រូវបានពន្យារពេល ឬបុនហិរញ្ញប្បទានទៅតាមប្រការ និងលក្ខខណ្ឌដែលកំណត់កាលវិភាគសងត្រឡប់ថ្មី ដោយផ្អែកលើរយៈពេលស្ថានភាពហិរញ្ញវត្ថុទន់ខ្សោយនៃអ្នកសុំខ្ចី និងអ្នកសុំខ្ចីគ្មានលទ្ធភាពសងត្រឡប់កម្ចីតាមកាលវិភាគនៃកិច្ចសន្យាដើម ដែលបានព្រមព្រៀង។ ឥណទានរៀបចំឡើងវិញ ត្រូវវិភាគលើមូលដ្ឋាននិទស្សន៍អាជីវកម្ម និងសមត្ថភាពសងត្រឡប់របស់អ្នកសុំខ្ចីយោងទៅតាមព្យាករណ៍លំហូរសាច់ប្រាក់ថ្មី ដែលគាំទ្រដោយស្ថានភាពអាជីវកម្មថ្មី និងលក្ខខណ្ឌទីផ្សារជារួមដោយផ្អែកលើសម្មតិកម្មជាក់ស្តែង និងប្រុងប្រយ័ត្ន។

➢ **គោលនយោបាយជម្រះបញ្ជី**

អនុលោមតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃកម្ពុជា ធនាគារត្រូវជម្រះបញ្ជីឥណទានបុរេប្រទានផ្តល់ឱ្យអតិថិជនទាំងមូល ឬមួយផ្នែកចេញពីតារាងតុល្យការរបស់ខ្លួន នៅពេលដែលធនាគារបាត់សិទ្ធិតាមកិច្ចសន្យាគ្រប់គ្រងលើឥណទាន ឬនៅពេលដែលឃើញថាឥណទានមួយផ្នែក ឬទាំងមូលមិនអាចប្រមូលវិញបាន ឬគ្មានសង្ឃឹមថាឥណទាននេះអាចប្រមូលបានមកវិញទេ។

➢ **ទ្រព្យបញ្ចាំ**

ធនាគារ រក្សានូវទ្រព្យបញ្ចាំជាទ្រព្យសម្បត្តិ និងការធានាចំពោះឥណទានផ្តល់ឱ្យអតិថិជន។ ការប៉ាន់ស្មាននូវតម្លៃទីផ្សារនៃទ្រព្យបញ្ចាំ គឺផ្អែកតាមការវាយតម្លៃទ្រព្យបញ្ចាំប្រចាំឆ្នាំ។

នៅក្នុងការិយបរិច្ឆេទធនាគារ មិនមានទទួលនូវទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុទុកជាទ្រព្យបញ្ចាំធានាចំពោះឥណទានបុរេប្រទានផ្តល់ឱ្យអតិថិជន។

➢ **ការប្រមូលផ្តុំហានិភ័យរបស់ទ្រព្យសកម្មហិរញ្ញវត្ថុជាមួយការប្រឈមនឹងហានិភ័យឥណទាន**

ការប្រមូលផ្តុំកើតមានឡើង នៅពេលដែលចំនួនអ្នកសុំខ្ចីប្រកបអាជីវកម្មស្រដៀងគ្នា ឬនៅក្នុងតំបន់ភូមិសាស្រ្តដូចគ្នា ឬមានស្ថានភាពសេដ្ឋកិច្ចស្រដៀងគ្នា ដែលអាចនាំឱ្យមានផលប៉ះពាល់ស្រដៀងគ្នាទៅលើលទ្ធភាពក្នុងការបំពេញកាតព្វកិច្ចតាមកិច្ចសន្យា ដែលរងផលប៉ះពាល់ពីការផ្លាស់ប្តូរនៃសេដ្ឋកិច្ចនយោបាយ ឬលក្ខខណ្ឌផ្សេងទៀត។ ការប្រមូលផ្តុំបង្ហាញពីបម្រែបម្រួលលទ្ធផលមធ្យមរបស់ធនាគារ ដែលរងផលប៉ះពាល់ពីវិស័យ ឬទីតាំងភូមិសាស្រ្តជាក់លាក់ណាមួយ។

➢ **សមតុល្យនៅធនាគារនានា**

ធនាគារ បានដាក់ប្រាក់បញ្ញើរយៈពេលខ្លី ដែលលើសពីសាច់ប្រាក់ងាយស្រួលនៅធនាគារនានា ដែលបណ្តាលឱ្យមានការប្រឈមហានិភ័យបដិភាគី។ ធនាគារគ្រប់គ្រងការប្រឈមហានិភ័យបដិភាគី ដោយធ្វើការវិភាគត្រួតពិនិត្យបដិភាគីនីមួយៗ ដោយដាក់កម្រិតកំណត់ប្រាក់បញ្ញើក្នុងធនាគារមួយ និងដាក់ប្រាក់បញ្ញើនៅធនាគារផ្សេងៗគ្នា។

**៣.២.៦ លក្ខខណ្ឌនៃការបង់ប្រាក់ច្បាស់លាស់**

ការប្រាស្រ័យទាក់ទងយ៉ាងមានប្រសិទ្ធភាពនូវលក្ខខណ្ឌនៃការទូទាត់ទៅកាន់អតិថិជនក្នុងលក្ខណៈច្បាស់លាស់ ឆ្លាតវៃ និងទាន់ពេលវេលា គឺមានសារៈសំខាន់ណាស់ក្នុងការទប់ស្កាត់ការទូទាត់យឺតយ៉ាវ និងពង្រឹងទំនាក់ទំនងជាមួយអតិថិជន។ ខាងក្រោមនេះជាគន្លឹះបន្ថែមដើម្បីបង្កើនប្រសិទ្ធភាពការទំនាក់ទំនងជាមួយអតិថិជន និងការគ្រប់គ្រងហានិភ័យឥណទានៈ

- **កំណត់លក្ខខណ្ឌបង់ប្រាក់ឱ្យច្បាស់លាស់៖** កំណត់យ៉ាងច្បាស់នូវលក្ខខណ្ឌនៃការបង់ប្រាក់ រួមមានប្រេកង់បង់ប្រាក់ វិធីសាស្រ្តបង់ប្រាក់ដែលទទួលយកបាន និងការបញ្ចុះតម្លៃ ឬការលើកទឹកចិត្តសម្រាប់ការបង់ប្រាក់មុនកាលកំណត់។
- **បញ្ជាក់អំពីអត្រាការប្រាក់ និងពន្ធ៖** ផ្តល់ភាពច្បាស់លាស់អំពីអត្រាការប្រាក់ ឬការគិតថ្លៃហិរញ្ញវត្ថុដែលត្រូវអនុវត្តចំពោះសមតុល្យដែលនៅសល់ ក៏ដូចជាពន្ធ ឬថ្លៃសេវាដែលអាចអនុវត្តបាន។
- **បញ្ជាក់កាលបរិច្ឆេទផុតកំណត់ និងការផាកពិន័យលើការទូទាត់យឺតយ៉ាវ៖** បញ្ជាក់ឱ្យច្បាស់ពីថ្ងៃផុតកំណត់ដែលត្រូវបង់ប្រាក់ រួមទាំងផលវិបាក ឬការពិន័យសម្រាប់ការទូទាត់យឺត ឬខកខាន។ វាជាវិធីលើកទឹកចិត្តឱ្យមានការបង់ប្រាក់ទាន់ពេលវេលា និងកាត់បន្ថយការមិនបង់ប្រាក់។
- **រួមបញ្ចូលលក្ខខណ្ឌសម្រាប់ការបិទដែនកំណត់ឥណទាន៖** ពន្យល់អំពីស្ថានភាពដែលដែនកំណត់ឥណទានអាចត្រូវបានដកហូត ឬកាត់បន្ថយ ដូចជាការបង់ប្រាក់យឺតយ៉ាវ អស្ថិរភាពហិរញ្ញវត្ថុ ឬការមិនគោរពតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងឥណទាន។

- **បញ្ជាក់អំពីបទប្បញ្ញត្តិការគ្រប់គ្រងវិវាទ៖** ពន្យល់ឱ្យច្បាស់អំពីដំណើរការដោះស្រាយវិវាទទាក់ទងនឹងការចេញវិក្កយបត្រ ការបង់ប្រាក់ ឬបញ្ហាទាក់ទងនឹងឥណទានផ្សេងទៀត។ នេះអនុញ្ញាតឱ្យមានការដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាព និងជួយរក្សាទំនាក់ល្អជាមួយទំនងអតិថិជន។

តាមរយៈការអនុវត្តគន្លឹះទាំងនេះ និងបញ្ចូលវាទៅក្នុងទំនាក់ទំនងជាមួយអតិថិជន ធនាគារ ស្ថាបនា អាចជំរុញដំណើរការគ្រប់គ្រងឥណទានប្រកបដោយតម្លាភាព និងមានប្រយោជន៍រួមគ្នា ដែលជួយលើកកម្ពស់ការបង់ប្រាក់ទាន់ពេលវេលា និងកាត់បន្ថយហានិភ័យឥណទាន។

**៣.២.៧ ស្វ័យប្រវត្តិកម្មប្រកបដោយលទ្ធផលលឿនរហ័ស និងច្បាស់លាស់**

ធនាគារ ស្ថាបនា កំពុងអនុវត្តដំណោះស្រាយស្វ័យប្រវត្តិកម្មគណនីដែលត្រូវទទួលបានក្នុងអត្រាការកើនឡើង ដើម្បីស្របតាមការពង្រីកមូលដ្ឋានអតិថិជនរបស់ និងកាត់បន្ថយហានិភ័យឥណទាន។ ការអនុម័តស្វ័យប្រវត្តិកម្មអនុញ្ញាតឱ្យការគ្រប់គ្រងឥណទានតាមពេលវេលាជាក់ស្តែង ដែលនាំឱ្យហានិភ័យឥណទានមានការថយចុះ និងកាត់បន្ថយបំណុលអាក្រក់។

អត្ថប្រយោជន៍សំខាន់ៗនៃការអនុវត្តស្វ័យប្រវត្តិកម្មនៃគណនីទទួល រួមមានដូចខាងក្រោម៖

- **ការសម្រេចចិត្តឥណទានត្រឹមត្រូវ៖** ស្វ័យប្រវត្តិកម្មផ្តល់នូវឧបករណ៍ និងទិន្នន័យចាំបាច់សម្រាប់ធ្វើការសម្រេចចិត្តឥណទានដែលមានព័ត៌មាន និងភាពច្បាស់លាស់ ដែលអនុញ្ញាតឱ្យធនាគារ ស្ថាបនា អាចវាយតម្លៃសមត្ថភាពនៃឥណទានរបស់អតិថិជនបានយ៉ាងត្រឹមត្រូវ។
- **ការពិនិត្យតាមកាលកំណត់ដោយស្វ័យប្រវត្តិ៖** តាមរយៈដំណើរការត្រួតពិនិត្យតាមកាលកំណត់ដោយស្វ័យប្រវត្តិ ធនាគារ ស្ថាបនា អាចវាយតម្លៃប្រកបដោយប្រសិទ្ធភាព និងវាយតម្លៃឡើងវិញនូវសមត្ថភាពឥណទានរបស់អតិថិជនបានយ៉ាងមានប្រសិទ្ធភាព ដោយធានាថាដែនកំណត់ឥណទាន និងលក្ខខណ្ឌនៅតែសមរម្យ។
- **ការទទួលអតិថិជនលឿនជាងមុន៖** ស្វ័យប្រវត្តិកម្មជួយសម្រួលឱ្យដំណើរការចុះឈ្មោះអតិថិជនមានប្រសិទ្ធភាព ធ្វើដោយអនុញ្ញាតឱ្យធនាគារ ស្ថាបនា អាចចុះឈ្មោះអតិថិជនថ្មីបានយ៉ាងឆាប់រហ័ស និងរលូនតាមរយៈការប្រមូលទិន្នន័យ ការផ្ទៀងផ្ទាត់ និងការវាយតម្លៃឥណទានដោយស្វ័យប្រវត្តិ។
- **សុពលភាពឯកសារយោងធនាគារ និងពាណិជ្ជកម្ម៖** ដំណោះស្រាយស្វ័យប្រវត្តិកម្មគណនីដែលអាចទទួលបាន អាចធ្វើឱ្យមានសុពលភាពឯកសារយោងធនាគារ និងពាណិជ្ជកម្មដោយស្វ័យប្រវត្តិ ដោយធានានូវភាពត្រឹមត្រូវ និងភាពជឿជាក់នៃព័ត៌មានរបស់អតិថិជន និងកាត់បន្ថយហានិភ័យនៃការក្លែងបន្លំឯកសារយោង ឬមិនគួរឱ្យទុកចិត្ត។
- **ការជូនដំណឹងអំពីហានិភ័យឥណទានតាមពេលវេលាជាក់ស្តែង៖** ឧបករណ៍ស្វ័យប្រវត្តិកម្មផ្តល់នូវការជូនដំណឹងអំពីហានិភ័យឥណទានក្នុងពេលជាក់ស្តែង ដែលអនុញ្ញាតឱ្យធនាគារ ស្ថាបនា ធ្វើការតាមដានអំពីភាពសមត្ថភាពឥណទានរបស់អតិថិជនយ៉ាងសកម្ម និងចាត់វិធានការភ្លាមៗក្នុងករណីមានការផ្លាស់ប្តូរអវិជ្ជមាន ឬហានិភ័យដែលអាចកើតមាន។
- **ការត្រួតពិនិត្យឥណទានដោយប្រតិកម្មជាស្វ័យប្រវត្តិ៖** ប្រព័ន្ធស្វ័យប្រវត្តិកម្មអាចជួយបញ្ជាក់ឱ្យការត្រួតពិនិត្យឥណទានដោយផ្អែកលើលក្ខខណ្ឌ ឬព្រឹត្តិការណ៍ដែលបានកំណត់ជាមុន ដោយអនុញ្ញាត

ឱ្យធនាគារ ស្ថាបនា អាចវាយតម្លៃឡើងវិញនូវដែនកំណត់ឥណទាន និងលក្ខខណ្ឌនៅពេលចាំបាច់ ដើម្បីកាត់បន្ថយហានិភ័យថ្មីៗដែលកំពុងកើតឡើង។

តាមរយៈការប្រើប្រាស់ស្វ័យប្រវត្តិកម្មគណនីដែលទទួលបាន ធនាគារ ស្ថាបនា អាចពង្រឹងសមត្ថភាពការគ្រប់គ្រងហានិភ័យឥណទាន ធ្វើឱ្យដំណើរការការងារកាន់តែមានប្រសិទ្ធភាព និងកែលម្អប្រសិទ្ធភាពហិរញ្ញវត្ថុសរុប។

### ៣.២.៨ បច្ចេកវិទ្យាឌីជីថលឈានមុខរបស់ធនាគារ ស្ថាបនា

ដោយបានឈ្នះពានរង្វាន់ទីបីរបស់ខ្លួនក្នុងរយៈពេល ២ ឆ្នាំ Sathapana Mobile មិនត្រឹមតែជាកម្មវិធីធនាគារប៉ុណ្ណោះទេ ដោយការលើកកម្ពស់ការដាក់បញ្ចូលហិរញ្ញវត្ថុ ដែលអាចឱ្យប្រជាជនកម្ពុជាគ្រប់គ្រងហិរញ្ញវត្ថុរបស់ពួកគេបានយ៉ាងងាយស្រួល និងសុវត្ថិភាព។

ធនាគារ ស្ថាបនា ដែលជាធនាគារពាណិជ្ជឈានមុខគេមួយនៅកម្ពុជា មានមោទនភាពក្នុងការប្រកាសថា សេវាធនាគារចល័តរបស់ខ្លួន ស្ថាបនា ចល័ត បានទទួលពានរង្វាន់ “Most Innovative Mobile Banking Application in Cambodia 2024” ពី International Finance Awards។ ពានរង្វាន់កិត្តិយសនេះពង្រឹងភាពជាអ្នកដឹកនាំរបស់ Sathapana Mobile ក្នុងការច្នៃប្រឌិតធនាគារឌីជីថលនៅកម្ពុជា។

Sathapana Mobile បានរួមបញ្ចូលគ្នានូវលក្ខណៈពិសេសប្រកបដោយភាពច្នៃប្រឌិត និងបច្ចេកវិទ្យាដ៏រឹងមាំ ដែលផ្តល់សិទ្ធិអំណាចដល់អ្នកប្រើប្រាស់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ពួកគេយ៉ាងរលូន។ ជាមួយនឹងរចនាបទដែលងាយស្រួលប្រើ និងឆ្លាតវៃ Sathapana Mobile ផ្តល់នូវល្បឿនប្រតិបត្តិការលឿនរហ័ស។ រចនាបទនេះផ្តល់សេរីភាពក្នុងការរុករកប្រើប្រាស់បានយ៉ាងងាយស្រួល ដោយអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចបង្កើតគណនីសន្សំប្រាក់ឆ្លាតវៃ ឬផែនការសន្សំជាក្រុមបានយ៉ាងឆាប់រហ័ស ដែលធ្វើឱ្យការគ្រប់គ្រងហិរញ្ញវត្ថុកាន់តែមានភាពងាយស្រួលជាងពីមុន។ លើសពីនេះ កម្មវិធីនេះជួយសម្រួលដល់ការទូទាត់ដោយផ្ទាល់ជាមួយដៃគូសំខាន់ៗក្នុងប្រទេសកម្ពុជា។ គោលគំនិត “Human ATM” ដែលអនុញ្ញាតឱ្យអតិថិជនដកសាច់ប្រាក់តាមរយៈលេខកូដនៅទីតាំងរបស់ភ្នាក់ងារដៃគូ រួមបញ្ចូលគ្នានូវសេវាកម្មផ្ទាល់ខ្លួន ជាមួយនឹងភាពងាយស្រួលទំនើប ធ្វើឱ្យសេវាធនាគារកាន់តែងាយស្រួលប្រើប្រាស់នៅទូទាំងប្រទេសកម្ពុជា។

## ៣.៣ ការគ្រប់គ្រងហានិភ័យឥណទានឱ្យមានប្រសិទ្ធភាពរបស់ធនាគារ ស្ថាបនា

ការគ្រប់គ្រងហានិភ័យឥណទាន គឺជាផ្នែកសំខាន់មួយនៅក្នុងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពហិរញ្ញវត្ថុរបស់ធនាគារ។ ដោយមានប្រព័ន្ធគ្រប់គ្រងល្អ និងប្រសិទ្ធភាព នេះអាចជួយកាត់បន្ថយបំណុលខាត (NPLs) បង្កើនប្រាក់ចំណេញ និងពង្រឹងស្ថេរភាពរបស់ធនាគារ។

នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន មានធនាគារជាច្រើនបានកំពុងអនុវត្តវិធានការច្បាស់លាស់ក្នុងការត្រួតពិនិត្យហានិភ័យឥណទាន។ ឧទាហរណ៍៖ ធនាគារ ស្ថាបនា មានប្រព័ន្ធត្រួតពិនិត្យសាច់ប្រាក់ ការផ្តល់ឥណទានតាមលក្ខខណ្ឌយ៉ាងតឹងរ៉ឹង និងការបណ្តុះបណ្តាលបុគ្គលិកជាប្រចាំ។ ដោយសារកត្តាទាំងអស់នេះ អត្រាបំណុលមិនបានបង់ត្រូវកាត់បន្ថយ និងមានភាពជោគជ័យក្នុងការប្រកួតប្រជែងក្នុងទីផ្សារ។

ការសិក្សាចុងក្រោយបានបញ្ជាក់ថា ការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងហានិភ័យឥណទានបាននាំឱ្យមានការកើនឡើងនៃប្រាក់ចំណេញលើទ្រព្យសម្បត្តិ (Return on Assets) និងលើទុន (Return on Equity)។ ធនាគារដែលមានអត្រាបំណុលខាតទាប គឺមានសមត្ថភាពខ្ពស់ក្នុងការផ្តល់ឥណទានថ្មី ធ្វើឱ្យមាន

ការផ្តល់សេវាហិរញ្ញវត្ថុបានទូលំទូលាយ និងមានជំហររឹងមាំជាងក្នុងទីផ្សារ។

ការចាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន (Impaired Facilities) ជាផ្នែកមួយនៃក្របខ័ណ្ឌគ្រប់គ្រងហានិភ័យទូទៅដែលធនាគារ ស្ថាបនា ត្រូវអនុវត្ត។ ដើម្បីគ្រប់គ្រងហានិភ័យឥណទានប្រកបដោយប្រសិទ្ធភាពធនាគារ ស្ថាបនា ត្រូវមាន៖

1. ប្រព័ន្ធគ្រប់គ្រងហានិភ័យឥណទាន ដែលមានលក្ខណៈសមស្របទៅនឹងចរិតលក្ខណៈ ភាពស្មុគស្មាញ និងទំហំនៃសកម្មភាពអាជីវកម្ម
2. ការពិនិត្យឡើងវិញជាប្រចាំ ទៅលើប្រព័ន្ធគ្រប់គ្រងហានិភ័យឥណទាន ដោយផ្អែកលើការផ្លាស់ប្តូរស្ថានភាពសេដ្ឋកិច្ច សកម្មភាព អតិថិជន និងហានិភ័យនានា
3. ប្រព័ន្ធគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាពសម្រាប់ការកំណត់ជាមុន ការតាមដាន និងការវាស់វែងហានិភ័យឥណទានឱ្យបានត្រឹមត្រូវ រួមទាំងការកំណត់ឱ្យបានពេញលេញ និងការរាយការណ៍អំពីហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន (Impaired Facilities) និងការព្យាករណ៍ការខាតបង់នៃសំពៀតឥណទាន
4. សំវិធានធនគ្រប់គ្រាន់សម្រាប់ហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន (Impaired Facilities) ស្របតាមស្តង់ដារគណនេយ្យ ជាធរមាននៃប្រទេសកម្ពុជា
5. គោរពគោលនយោបាយ នីតិវិធី និងដំណើរការអនុវត្ត អនុលោមតាមលក្ខខណ្ឌតម្រូវទាំងអស់នៃប្រកាសនេះ។

ការគ្រប់គ្រងហានិភ័យឥណទាន (Credit Risk) ឱ្យមានប្រសិទ្ធភាព គឺមានតួនាទីសំខាន់ណាស់ក្នុងការធានាស្ថិរភាព និងភាពចំណេញរបស់ធនាគារ។ ក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា ការគ្រប់គ្រងហានិភ័យឥណទានបានក្លាយជាវិធានសំខាន់សម្រាប់ធនាគារ ស្ថាបនា ដើម្បីធានាការលូតលាស់ប្រកបដោយសុវត្ថិភាព និងនិរន្តរភាព។ ធនាគារ ស្ថាបនា គឺជាឧទាហរណ៍មួយនៃធនាគារដែលបានអនុវត្តយុទ្ធសាស្ត្រការគ្រប់គ្រងហានិភ័យឥណទានយ៉ាងប្រសើរ ដើម្បីធានាឱ្យមានប្រសិទ្ធភាពក្នុងការផ្តល់ឥណទាន និងការប្រកួតប្រជែងក្នុងទីផ្សារ។

ធនាគារ ស្ថាបនា បានយកវិធានការគ្រប់គ្រងហានិភ័យឥណទានមកអនុវត្តជាប្រចាំដូចជា៖

- ការបង្ហាញសមត្ថភាពផ្ទាល់ខ្លួនក្នុងការវាយតម្លៃស្ថានភាពហិរញ្ញវត្ថុអតិថិជន
- ប្រើប្រព័ន្ធគ្រប់គ្រងទិន្នន័យឥណទាន (Credit Scoring System) ដើម្បីបញ្ជាក់លក្ខណៈសមរម្យរបស់អ្នកដាក់ពាក្យសុំឥណទាន
- ធ្វើការផ្ទៀងផ្ទាត់លើគ្រប់ឯកសារពាក់ព័ន្ធជាច្បាស់លាស់ និងពិនិត្យការសងប្រាក់ប្រវត្តិពីបណ្តាញធនាគារដទៃទៀត។

ធនាគារ ស្ថាបនា ក៏បានចូលរួមជាមួយក្រុមហ៊ុន Finbots.ai ពីសិង្ហបុរី ដើម្បីបង្កើនសមត្ថភាពគ្រប់គ្រងហានិភ័យឥណទានរបស់ខ្លួន។ ធនាគារ ស្ថាបនា ចូលរួមជាមួយ Finbots.ai ដើម្បីបង្កើនការគ្រប់គ្រងហានិភ័យឥណទានឡើង។ ដំណោះស្រាយគំរូឥណទានរបស់ក្រុមហ៊ុន fintech ដែលមានឈ្មោះថា creditX នឹងជួយឱ្យធនាគារ ស្ថាបនា បង្កើតតារាងពិន្ទុហានិភ័យឥណទាន "គុណភាពខ្ពស់" ពន្លឿនដំណើរការអតិថិជន និងបង្កើនការគ្រប់គ្រងផលប័ត្ររបស់ខ្លួន។ ធនាគារ ស្ថាបនា នឹងអាចវាយតម្លៃបានប្រសើរជាងមុនលើសមត្ថភាព

សងប្រាក់របស់អ្នកដាក់ពាក្យសុំកម្ចីផ្ទាល់ខ្លួន កម្ចីផ្ទះ កម្ចីកសិកម្ម និងកម្ចីសម្រាប់សហគ្រាសតូចមធ្យម (SMEs) ដោយពន្លឿនកំណើនអាជីវកម្មដោយមិនបង្កើនហានិភ័យ។

លើសពីនេះ ធនាគារនឹងអាចបង្កើត Behavior Scorecards តាមតម្រូវការគ្រប់គ្រងផលប័ត្រក្នុងពេលវេលាជាក់ស្តែង និងចាត់វិធានការកាត់បន្ថយដែលបណ្តាលឱ្យមានហានិភ័យឥណទានទាប អត្រាអនុម័តខ្ពស់ និងប្រសិទ្ធភាពប្រតិបត្តិការកាន់តែច្រើន។

ធនាគារ ស្ថាបនា បានសហការជាមួយក្រុមហ៊ុន Finbots.ai ពីសិង្ហបុរី ដើម្បីប្រើប្រាស់កម្មវិធី CreditX ដែលប្រើបច្ចេកវិទ្យា AI ក្នុងការគ្រប់គ្រងហានិភ័យឥណទាន។ ឧបករណ៍នេះអនុញ្ញាតឱ្យធនាគារ ស្ថាបនា បង្កើតតារាងពិន្ទុឥណទានមានគុណភាពខ្ពស់ និងធ្វើឱ្យដំណើរការចុះបញ្ជីអតិថិជនត្រូវបានលឿនរហ័ស។ គោលដៅសំខាន់នៃការប្រើប្រាស់នេះ គឺធ្វើឱ្យធនាគារអាចវាយតម្លៃសមត្ថភាពសងប្រាក់ទៅលើអ្នកដាក់ពាក្យកម្ចីផ្ទាល់ខ្លួន ផ្ទះ កសិកម្ម និងអាជីវកម្មតូចមធ្យម (SME) បានយ៉ាងត្រឹមត្រូវ ខណៈអាជីវកម្មកើនឡើងដោយមិនបន្ថែមហានិភ័យ។ លទ្ធផលនៃការដាក់មូលដ្ឋានទិន្នន័យឌីជីថលនេះ មានឥទ្ធិពលធ្វើឱ្យអត្រាអនុម័តកម្ចីកើនឡើងនិងប្រសិទ្ធភាពប្រតិបត្តការកាន់តែខ្ពស់។

លើសពីនេះទៀត ធនាគារ ស្ថាបនា ក៏បានបង្កើតតារាងពិន្ទុឥរិយាបទ (behavior scorecards) ដើម្បីតាមដានសកម្មភាពឥណទាន និងស្ថានភាពហានិភ័យនៃគណនីកម្ចីក្នុងពេលវេលាជាក់ស្តែង។ ដំណើរការនេះអាចធ្វើឱ្យធនាគារ ស្ថាបនា អនុវត្តសកម្មភាពការពារ (mitigating actions) ដើម្បីកាត់បន្ថយហានិភ័យបានកាន់តែប្រសើរឡើង ខណៈពេលដែលធ្វើឱ្យដំណើរការអនុម័តកម្ចីមានល្បឿនខ្ពស់ និងចំណាយធនធានតិចជាងមុន។

ជាមួយនឹង creditX ធនាគារ ស្ថាបនា ត្រូវបានគេរំពឹងថានឹងធ្វើការវាយតម្លៃកាន់តែប្រសើរឡើងអំពីភាពសក្តិសមនៃឥណទានរបស់អ្នកដាក់ពាក្យស្នើសុំសម្រាប់កម្ចីផ្ទាល់ខ្លួន ផ្ទះ កសិកម្ម និងសហគ្រាសធុនតូចនិងមធ្យម (SME)។

ធនាគារ ស្ថាបនា ក៏ត្រូវបានរំពឹងថានឹងទទួលបានសមត្ថភាពក្នុងការបង្កើតតារាងពិន្ទុអាកប្បកិរិយាដែលមានភាពត្រឹមត្រូវខ្ពស់តាមតម្រូវការ និងអាចឱ្យការគ្រប់គ្រងផលប័ត្របានទាន់ពេលវេលា។ ទាំងនេះនឹងជួយធនាគារក្នុងការផ្តល់រង្វាន់ដល់អតិថិជនស្មោះត្រង់យ៉ាងសកម្ម និងចាត់វិធានការកាត់បន្ថយសម្រាប់អតិថិជនដែលមានហានិភ័យខ្ពស់។

ជាលទ្ធផល អាជីវកម្មលក់រាយ និងសហគ្រាសធុនតូច និងមធ្យម របស់ធនាគារត្រូវបានគេរំពឹងថានឹងមានហានិភ័យឥណទានទាប អត្រាអនុម័តខ្ពស់ និងបង្កើនប្រសិទ្ធភាពប្រតិបត្តិការ។

លោក Fung Kai Jin នាយកប្រតិបត្តិធនាគារ ស្ថាបនា បានមានប្រសាសន៍ថា៖ «ក្នុងនាមជាធនាគារពាណិជ្ជឈានមុខគេ យើងទទួលស្គាល់តម្លៃនៃការចាប់ដៃគូជាមួយក្រុមហ៊ុនច្នៃប្រឌិតដែលផ្តល់នូវបច្ចេកវិទ្យាជំនាន់ក្រោយ ដើម្បីផ្តល់លទ្ធភាពទទួលបានឥណទានកាន់តែប្រសើរដល់អតិថិជនរបស់យើង»។

**៣.៣.១ អត្ថប្រយោជន៍នៃការគ្រប់គ្រងហានិភ័យឥណទានចំពោះធនាគារ ស្ថាបនា**

Finbots.ai creditX គឺជាដំណោះស្រាយមួយ ដែលជួយពង្រឹងការគ្រប់គ្រងហានិភ័យឥណទាន បង្កើនប្រសិទ្ធភាពប្រតិបត្តិការ និងភាពរហ័សរហួនរបស់យើង។ នេះគឺស្របតាមគោលដៅរបស់យើងក្នុងការផ្តល់នូវដំណោះស្រាយធនាគារប្រកបដោយភាពច្នៃប្រឌិតដល់អតិថិជនរបស់យើងនៅក្នុងប្រទេសកម្ពុជា។

ការគ្រប់គ្រងហានិភ័យឥណទានដ៏មានប្រសិទ្ធភាពនេះ បានជួយដល់ធនាគារ ស្ថាបនា ឱ្យមានអត្រាបំណុលខាត (NPL) ទាប បន្តដំណើរការល្អក្នុងការផ្តល់សេវាឥណទាន និងទទួលបានការជឿជាក់ខ្ពស់ពីអតិថិជន។ ពិសេសក្នុងអំឡុងពេលកូវីដ-១៩ ធនាគារ ស្ថាបនា បានអនុវត្តគោលនយោបាយផ្តល់ការសម្រាលបំណុល និងពិនិត្យបន្ទាន់លើឥណទានដែលមានហានិភ័យខ្ពស់។

ជាផ្នែកនៃគោលដៅអភិវឌ្ឍន៍និរន្តរភាពធនាគារ ស្ថាបនា ក៏បានធ្វើការបណ្តុះបណ្តាលបុគ្គលិកជាប្រចាំ និងប្រើប្រាស់បច្ចេកវិទ្យា Digital Risk Management Tools ដើម្បីពង្រឹងប្រព័ន្ធត្រួតពិនិត្យឥណទាន និងគ្រប់គ្រងហានិភ័យឱ្យមានប្រសិទ្ធភាព។ ដូចនេះការ បោះជំហានផ្នែកបច្ចេកវិទ្យារបស់ធនាគារ ស្ថាបនា ជួយធានាបាននូវការតាមដានលឿន និងអាចវាយតម្លៃហានិភ័យបានទាន់ពេល។

ក្នុងនាមជាធនាគារដែលមានការអភិវឌ្ឍន៍លឿន និងមានវិស័យឥណទានធំមួយនៅក្នុងប្រទេសកម្ពុជា ធនាគារ ស្ថាបនា បានផ្តោតលើការគ្រប់គ្រងហានិភ័យឥណទានប្រកបដោយប្រព័ន្ធត្រឹមត្រូវ ដើម្បីធានាឱ្យមានភាពរឹងមាំនៃប្រតិបត្តិការហិរញ្ញវត្ថុ និងការលូតលាស់ប្រកបដោយចីរភាព។

ការគ្រប់គ្រងហានិភ័យឥណទានឱ្យមានប្រសិទ្ធភាពផ្តល់អត្ថប្រយោជន៍សំខាន់ៗដល់ធនាគារ ស្ថាបនា ដូចខាងក្រោម៖

➢ **បន្ថយអត្រាបំណុលខាតបង់ (Non-Performing Loans - NPLs)**

ធនាគារ ស្ថាបនា យកចិត្តទុកដាក់លើការជ្រើសរើសអតិថិជនដោយប្រើប្រព័ន្ធពិនិត្យសមត្ថភាពសងជាក់លាក់ និងអនុវត្តប្រព័ន្ធវាយតម្លៃឥណទាន (Credit scoring) និងស្វែងយល់ពីអត្តសញ្ញាណអតិថិជនយ៉ាងម៉ត់ចត់ និងច្បាស់លាស់។ ដោយការគ្រប់គ្រងនេះធនាគារ ស្ថាបនា អាចបន្តរក្សាអត្រា NPL ទាប និងទប់ស្កាត់ការខាតបង់ជាពាក់កណ្តាលនៃការរក្សាសុខភាពហិរញ្ញវត្ថុ។

➢ **កាត់បន្ថយការខាតបង់ពីឥណទានអតិថិជន**

ការគ្រប់គ្រងហានិភ័យឥណទានយ៉ាងមានប្រសិទ្ធភាពជាឧបករណ៍សំខាន់សម្រាប់ ដើម្បីបង្ការការខាតបង់ពីឥណទានអតិថិជន។ តាមរយៈការវាយតម្លៃអតិថិជនយ៉ាងម៉ត់ចត់ មុនពេលអនុម័តឥណទាន ធនាគារ ស្ថាបនា អាចកំណត់បានពីសមត្ថភាពសងត្រឡប់របស់អតិថិជន។ លើសពីនេះ ប្រព័ន្ធប្រមូលប្រាក់បច្ចុប្បន្នត្រូវបានបង្កើតឡើង ដើម្បីជំរុញការសងប្រាក់បានទាន់ពេលវេលា និងជួយកាត់បន្ថយបំណុលលើសកំណត់។ ប្រព័ន្ធតាមដាន និងការជឿជាក់លើសញ្ញាហានិភ័យជាបច្ចុប្បន្នភាពជួយធនាគារ ស្ថាបនា ទប់ស្កាត់ការខាតបង់ មុនពេលវាផ្ទុះឡើងជាបញ្ហាធ្ងន់ធ្ងរ។

➢ **បង្កើនភាពជឿជាក់ និងភាពប្រកួតប្រជែង**

ធនាគារ ស្ថាបនា ទទួលបានកម្រិតជឿជាក់ខ្ពស់ពីអតិថិជន អាជ្ញាធរ និងអ្នកវិនិយោគ ដោយសារតែគោលនយោបាយគ្រប់គ្រងហានិភ័យឥណទានប្រកបដោយប្រសិទ្ធភាព។ ការបង្ហាញភាពជាអ្នកដឹកនាំផ្នែកគ្រប់គ្រងឥណទាននេះបានអាចធ្វើឱ្យបង្កើនទំនុកចិត្ត និងការប្រកួតប្រជែងខ្ពស់។

➢ **បង្កើនចំណូល និងផលចំណេញ**

ការជ្រើសរើសអតិថិជនត្រឹមត្រូវ និងកាត់បន្ថយឥណទានអសកម្ម ធ្វើឱ្យធនាគារ ស្ថាបនា អាចបង្កើតចំណូលប្រចាំខែបានយ៉ាងមានប្រសិទ្ធភាព។ ការរក្សាបំណុលដែលមានគុណភាពល្អ បានជួយដល់ការទទួលបានផលចំណេញសុទ្ធ (Net Profit) និងការរក្សាប្រាក់ចំណេញរយៈពេលវែង។

- **ជួយគ្រប់គ្រងគុណភាពទ្រព្យសម្បត្តិ (Asset Quality)**

ដោយការវាយតម្លៃលើឥណទានប្រកបដោយវិជ្ជាជីវៈ និងប្រើប្រាស់ប្រព័ន្ធ Risk Rating System។ ធនាគារ ស្ថាបនា មានសមត្ថភាពខ្ពស់ក្នុងការរក្សាគុណភាពបំណុល និងធានាសមតុល្យទុនក្នុងរបាយការណ៍ហិរញ្ញវត្ថុជាប្រចាំ។

- **អនុវត្តគោលនយោបាយប្រទេស និងអន្តរជាតិ**

ធនាគារ ស្ថាបនា បានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការអនុវត្តតាមបទប្បញ្ញត្តិរបស់អាជ្ញាធរជាតិ (NBC) និងស្តង់ដារអន្តរជាតិដូចជា IFRS 9 និង Basel II/III ដោយបញ្ចូលវាទៅជាផ្នែកនៃប្រព័ន្ធគ្រប់គ្រងហានិភ័យ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំថ្ងៃ។ ការអនុវត្តទាំងនេះជួយធនាគារបង្កើនការត្រៀមខ្លួនទល់នឹងហានិភ័យផ្នែកហិរញ្ញវត្ថុ។ លើសពីនេះទៅទៀត វាក៏ជាប្រភពសំខាន់ក្នុងការបង្កើតឱកាសសហការណ៍ និងការចូលរួមប្រកួតប្រជែងក្នុងទីផ្សារសេដ្ឋកិច្ចអន្តរជាតិផងដែរ។

- **រីកចម្រើនប្រកបដោយចីរភាព (Sustainable Growth)**

ការប្រើប្រាស់នូវគោលនយោបាយគ្រប់គ្រងហានិភ័យយ៉ាងប្រុងប្រយ័ត្នបានជួយឱ្យធនាគារ ស្ថាបនា បង្កើនជំនឿទុកចិត្តពីអតិថិជន និងអ្នកវិនិយោគ ដោយផ្តល់ប្រាក់កម្ចីទៅដល់អតិថិជនដែលមានសមត្ថភាពសង និងមានប្រវត្តិឥណទានល្អ។ វិធានការណ៍ទាំងនេះមិនត្រឹមតែបង្ការការខាតបង់ទេ ប៉ុន្តែបង្កើនការជឿជាក់ពីសាធារណជន និងបង្កើតបរិយាកាសសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។ ទន្ទឹមនឹងនេះ កំណើននៃសកម្មភាពឥណទានបានបន្តទៅលើមូលដ្ឋានគ្រឹះរឹងមាំ ជួយធានានូវស្ថិរភាព និងមានគុណភាពសម្រាប់ក្នុងរយៈពេលវែង។

- **ប្រសិទ្ធភាពក្នុងការសម្រេចចិត្ត (Operational Efficiency)**

ការប្រើប្រាស់បច្ចេកវិទ្យាដូចជា Credit Scoring System និង Loan Automation Tools បានជួយកាត់បន្ថយកំហុស និងលើកលែងការងារដោយដៃ។ ការអនុវត្តបច្ចេកវិទ្យានេះនាំឱ្យការសម្រេចចិត្តបានទាន់ពេលវេលា និងបើកផ្លូវទៅកាន់ការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាព។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើនេះរួចមក ក្រុមយើងខ្ញុំយល់ឃើញថា ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារ ស្ថាបនា ភីអិលស៊ី ពិតជាមានសារៈសំខាន់ខ្លាំងណាស់ដល់ធនាគារ និងអ្នកប្រើប្រាស់។ ការគ្រប់គ្រងនេះមិនត្រឹមតែជួយកាត់បន្ថយហានិភ័យនោះទេ ប៉ុន្តែថែមទាំងជាជំហានមួយ ដើម្បីលើកកម្ពស់ការជឿទុកចិត្តពីសំណាក់អតិថិជនផងដែរ។ ប៉ុន្តែទោះជាយ៉ាងណាវិញក៏ដោយ ការអនុវត្តការគ្រប់គ្រងហានិភ័យឥណទាននេះនៅតែមានចំណុចខ្លាំង និងចំណុចខ្សោយទៅជាមួយគ្នាជានិច្ច ហើយខាងក្រោមនេះជាចំណុចខ្លាំង និងចំណុចខ្សោយ ដែលទាក់ទងនិងប្រធានបទ។

## ៤.១ ការវិភាគលើចំណុចខ្លាំង

- ការគ្រប់គ្រងហានិភ័យដោយបច្ចេកវិទ្យាទំនើប៖ ធនាគារ ស្ថាបនា បានប្រើប្រាស់នូវបច្ចេកវិទ្យាគ្រប់គ្រងហានិភ័យឥណទានដោយ ការវាយតម្លៃឥណទាន (Credit Scoring) និងការត្រួតពិនិត្យឥណទាន (Credit Monitoring) ដែលប្រើប្រាស់ប្រព័ន្ធ BI (Business Intelligence)។ ការប្រើប្រាស់បច្ចេកវិទ្យាទំនើបទាំងនេះ បានជួយឱ្យធនាគារ ស្ថាបនា បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងហានិភ័យឥណទាន និងបំពេញតម្រូវការរបស់អតិថិជនយ៉ាងមានប្រសិទ្ធភាព។
- ការផ្តល់នូវប្រភេទសេវាឥណទាន៖ ធនាគារ ស្ថាបនា បាននូវការបញ្ចេញឥណទានជាច្រើនប្រភេទ ដែលមានភាពងាយស្រួល ច្បាស់លាស់ និងប្រកបដោយសុវត្ថិភាពសម្រាប់អតិថិជនធ្វើការសម្រេចបានត្រឹមត្រូវ និងប្រសើរជាងមុន។ ហើយជួយឱ្យថ្នាក់ដឹកនាំផ្នែកគ្រប់គ្រងឥណទានអាចវាយតម្លៃលើគុណភាពឥណទានរបស់អតិថិជនបានរហ័សទាន់ពេលវេលា និងមានប្រសិទ្ធភាពជាងមុន ដែលជួយឱ្យការសម្រេចចិត្តមានភាពត្រឹមត្រូវ និងសម្រេចបាននូវគោលដៅរបស់ធនាគារ។
- គោលការណ៍ត្រួតពិនិត្យយ៉ាងម៉ត់ចត់៖ ធនាគារ ស្ថាបនា តាមដានត្រួតពិនិត្យយ៉ាងម៉ត់ចត់ទាំងមុន និងក្រោយពេលផ្តល់ឥណទាន ដោយចាត់ឱ្យភ្នាក់ងារធ្វើការរៀបចំឯកសារ និងចុះពិនិត្យផ្ទាល់ទៅកាន់ផ្ទះអតិថិជន ដើម្បីវាយតម្លៃលើមុខរបរ ទ្រព្យបញ្ចាំ ទំហំឥណទាន និងការសម្រេចចិត្តស្នើសុំឥណទាន។ ការសម្រេចចិត្តនេះអនុវត្តតាមគោលការណ៍ និងនីតិវិធីដែលធនាគារកំណត់ដាក់លាក់។
- ឧបករណ៍វាយតម្លៃហានិភ័យ៖ ក្នុងឆ្នាំ ២០២៣ ធនាគារ ស្ថាបនា បានសហការជាមួយ Finbots.ai ដើម្បីអនុវត្តប្រព័ន្ធ CreditX ដែលជាសំណុំឧបករណ៍វាយតម្លៃហានិភ័យឥណទានដោយ AI ដែលមានគុណភាពខ្ពស់ ជំរុញដំណើរការស្នើសុំឥណទានឱ្យរហ័ស និងគាំទ្រឱ្យធនាគារគណនាសមត្ថភាពឥណទានរបស់អតិថិជនបានច្បាស់លាស់ និងបន្ថយនូវហានិភ័យនៃបំណុលខូះសាច់ប្រាក់ (NPL)។

ទន្ទឹមនឹងនេះភ្នាក់ងារ និងបុគ្គលិកទាំងអស់មានទំនាក់ទំនងល្អ ជាមួយអតិថិជន អាជ្ញាធរមូលដ្ឋាន និងស្ថាប័នផ្សេងៗ ដែលជាកត្តាយ៉ាងសំខាន់មួយធ្វើឱ្យដំណើរការការងារប្រព្រឹត្តទៅបានយ៉ាងរលូន និងមានប្រសិទ្ធភាព។ ជាមួយគ្នានេះដែរ ការបែងចែកតួនាទីតាមឋានានុក្រមរបស់បុគ្គលិកគ្រប់ផ្នែក ក៏ត្រូវបានអនុវត្តយ៉ាងមានភាពច្បាស់លាស់ ហើយមានការជំរុញ និងលើកទឹកចិត្តយ៉ាងសកម្មពីថ្នាក់ដឹកនាំ ដែលបានបង្កើតបរិយាកាសការងារដែលមានភាពសហការល្អ និងភាពល្អប្រសើរ។ លើសពីនេះទៅទៀត ការពិនិត្យជាប្រចាំថ្ងៃ

ទៅលើស្ថានភាពឥណទានក្រោយការបញ្ចេញឥណទាន ក៏ជួយលើកកម្ពស់ប្រសិទ្ធភាពនៃការបញ្ចេញ និង ប្រមូលឥណទានមានកម្រិតកាន់តែខ្ពស់ ព្រមទាំងអាចទប់ស្កាត់បញ្ហាឥណទានកើតមានឡើង និងស្វែងរកដំណោះស្រាយបានទាន់ពេលវេលា។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទោះបីជាធនាគារ ស្ថាបនា មានចំណុចខ្លាំងជាច្រើនក្នុងការគ្រប់គ្រងហានិភ័យឥណទាន ដូចដែលបានរៀបរាប់ខាងលើក្តីក៏ដោយ ប៉ុន្តែធនាគារ ស្ថាបនា នៅតែមានចំណុចខ្វះខាតមួយចំនួន ដែលអាចក្លាយជាឧបសគ្គ ឬបណ្តាលឱ្យមានភាពមិនប្រសើរគ្រប់គ្រាន់ក្នុងការគ្រប់គ្រងហានិភ័យឥណទានផងដែរ។

**ចំណុចខ្វះខាតទាំងនោះមានដូចជា៖**

- ការកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យ៖ ការគ្រប់គ្រងទិន្នន័យរបស់ធនាគារ ស្ថាបនា នៅមានកម្រិតនៅឡើយ ដែលអាចនាំឱ្យមានភាពលំបាកក្នុងប្រើប្រាស់ទិន្នន័យដែលពាក់ព័ន្ធមិនបានទាន់ពេលវេលា ធ្វើឱ្យពន្យារពេលក្នុងដំណើរការសម្រេចចិត្តរបស់អតិថិជន និងបញ្ហាប្រឈមក្នុងប្រត្តិបត្តិការ។
- ឧបករណ៍គ្រប់គ្រងហានិភ័យមិនគ្រប់គ្រាន់៖ ការខ្វះខាតនៃដំណោះស្រាយគ្រប់គ្រងហានិភ័យ ដែលមានភាពរឹងមាំ បានរារាំងធនាគារ ស្ថាបនា ពីការកំណត់ ការប្រមូលផ្តុំផលបត្រ និងធ្វើការវាយតម្លៃផលបត្រឱ្យបានទាន់ពេលវេលា ដោយកំណត់សមត្ថភាពរបស់ពួកគេក្នុងការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព។

ដូចដែលបានពណ៌នាខាងលើ ទាំងអស់នេះសុទ្ធតែជាចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួន ដែលក្រុមរបស់យើងខ្ញុំបានយល់ដឹងបន្ទាប់ពីបានសិក្សា និងស្រាវជ្រាវអំពីធនាគារ ស្ថាបនា។ បើមានចំណុចណាមួយខុសឆ្គង មិនសមស្របដែលកើតមានដោយអចេតនា ក្រុមរបស់យើងខ្ញុំក៏សូមខន្តីអភ័យទោសពីសំណាក់លោកគ្រូ អ្នកគ្រូ ក៏ដូចជាសាស្ត្រាចារ្យ និងជាពិសេសធនាគារ ស្ថាបនា ព្រោះនេះគ្រាន់តែជាការស្រាវជ្រាវ និងការយល់ឃើញពីក្រុមរបស់យើងខ្ញុំតែប៉ុណ្ណោះ ក្រុមរបស់យើងខ្ញុំក៏រីករាយនឹងទទួលយក និងកែលម្អនូវរាល់កំហុសដែលបានផ្តល់ជូនដល់ក្រុមរបស់យើងខ្ញុំ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

បន្ទាប់ពីក្រុមយើងខ្ញុំបានសិក្សាស្រាវជ្រាវ និងប្រមូលឯកសារមួយរយៈកន្លងមកលើប្រធានបទ ស្តីពី ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារ ស្ថាបនា ភីអិលស៊ី ក្រុមយើងខ្ញុំអាចវិភាគ និង សន្និដ្ឋានបានថា ការគ្រប់គ្រងហានិភ័យក្នុងការផ្តល់ឥណទានរបស់ធនាគារ ស្ថាបនា ពិតជាមានដំណើរការ ល្អប្រសើរពិតប្រាកដមែន ដោយធនាគារមាននូវប្រព័ន្ធគ្រប់គ្រងឥណទានដ៏មានប្រសិទ្ធភាព និងមានភាព ទំនើបទាន់សម័យ។ ការផ្តល់សេវាឥណទានបានអនុវត្តដោយការបញ្ចេញព័ត៌មានយ៉ាងមានភាពច្បាស់លាស់ ម៉ត់ចត់ និងប្រកបដោយសុវត្ថិភាព ដើម្បីជួយឱ្យការសម្រេចចិត្តផ្តល់ឥណទានប្រព្រឹត្តទៅបានត្រឹមត្រូវ។ ការ ត្រួតពិនិត្យសកម្មភាពរបស់អតិថិជនមុននឹងផ្តល់ឥណទាន និងក្រោយពីបានផ្តល់ឥណទានក៏ត្រូវបានអនុវត្ត យ៉ាងម៉ត់ចត់ ដើម្បីកាត់បន្ថយហានិភ័យឥណទាន និងធានានូវភាពប្រសើរនៃគុណភាពឥណទាន។ ម្យ៉ាងវិញ ទៀតធនាគារ ស្ថាបនា បានប្រើប្រាស់កម្មវិធីទំនើបដូចជា “Sathapana Mobile” និងប្រព័ន្ធវាយតម្លៃហានិភ័យ AI CreditX ដែលជួយបង្កើនប្រសិទ្ធភាពនៃប្រតិបត្តិការហិរញ្ញវត្ថុ និងការគ្រប់គ្រងហានិភ័យឥណទាន ដើម្បី ធ្វើឱ្យឥណទានមានភាពល្អប្រសើរជាងមុន។

ជាចុងបញ្ចប់ក្រុមយើងខ្ញុំ សូមធ្វើការអភ័យទោស និងអធ្យាស្រ័យអំពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តអ្នកអាន និងអ្នកស្រាវជ្រាវទាំងអស់ចំពោះកំហុសខុសឆ្គងក្នុងប្រការណាមួយដែលបានកើតឡើង ដោយអចេតនា ព្រោះវាគ្រាន់តែការលើកយកមកបង្ហាញអំពីកិច្ចការស្រាវជ្រាវ ដែលទាក់ទងអំពីប្រធានបទ «ការគ្រប់គ្រងហានិភ័យក្នុងផ្តល់ឥណទានរបស់ធនាគារ ស្ថាបនា ភីអិលស៊ី» បន្ថែមលើមេរៀនដែលបានសិក្សា កន្លងមកតែប៉ុណ្ណោះ។ ថ្វីត្បិតកិច្ចការស្រាវជ្រាវនេះមិនបង្ហាញពីទិន្នន័យគ្រប់ជ្រុងជ្រោយទាំងអស់ក៏ពិតមែន ប៉ុន្តែឯកសារនេះអាចមានប្រយោជន៍សម្រាប់និស្សិតជំនាន់ក្រោយ ជាគំរូក្នុងការស្វែងយល់ និងស្រាវជ្រាវដែល ទាក់ទងជុំវិញប្រធានបទ ការគ្រប់គ្រងហានិភ័យក្នុងផ្តល់ឥណទានរបស់ធនាគារ ស្ថាបនា ផងដែរ។ ក្រុមយើង ខ្ញុំសូមទទួលការចូលរួមចំណែកក្នុងការកែលម្អ ដើម្បីស្ថាបនាដោយការយោគយល់ និងអនុគ្រោះដោយក្តី រីករាយ។

## ៥.២ ការផ្តល់អនុសាសន៍

ឆ្លងតាមការសន្និដ្ឋានលើការស្រាវជ្រាវទាក់ទងនឹងប្រធានបទខាងលើនេះរួចមក ក្រុមយើងខ្ញុំសង្កេត ឃើញថា ធនាគារ ស្ថាបនា មានចំណុចខ្លាំងជាច្រើនក្នុងការគ្រប់គ្រងប្រតិបត្តិការឥណទានរបស់ខ្លួន តែយ៉ាង ណាវិញ ក៏នៅមានចំណុចខ្វះខាតមួយចំនួនតូចផងដែរ ដែលគួរតែធ្វើការកែលម្អឱ្យបានកាន់តែប្រសើរឡើង ក្នុងការគ្រប់គ្រងហានិភ័យឥណទាន មានដូចខាងក្រោម៖

- បង្កើនការប្រើប្រាស់គោលនយោបាយគ្រប់គ្រងទិន្នន័យ (Data Management Policy)៖ ធនាគារ ស្ថាបនា គួរតែបង្កើនគោលនយោបាយ និងបទប្បញ្ញត្តិឱ្យបានកាន់តែច្បាស់លាស់សម្រាប់ការប្រមូល ការផ្ទុក ការប្រើប្រាស់ និងការចែកចាយទិន្នន័យ ដើម្បីជួយការពារទិន្នន័យឱ្យមានសុវត្ថិភាព និងអាច ទុកចិត្តបាន។

- អភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងហានិភ័យ (Risk Management System)៖ ដើម្បីអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងឱ្យកាន់តែល្អប្រសើរ ធនាគារ ស្ថាបនា ត្រូវបង្កើតនូវឧបករណ៍ ឬប្រព័ន្ធគ្រប់គ្រងឆ្លើយតបនឹងហានិភ័យដែលមានលក្ខណៈគ្របដណ្ដប់គ្រប់ផ្នែក និងអាចព្យាករបានមុននូវហានិភ័យដែលអាចនឹងកើតមានឡើង។ ប្រព័ន្ធនេះគួរត្រូវបានផ្ទៀងផ្ទាត់ជាប្រចាំ និងបន្ថែមលក្ខណៈ បច្ចេកទេសថ្មីៗបន្ថែមទៀត។

# ឯកសារយោង


១.វិទ្យាស្ថានវ៉ាន់ដា. (2023). *ការគ្រប់គ្រងឥណទាន*. បោះពុម្ពលើកទី២ ទំព័រទី២៤-២៦. ៥៨ទំព័រ. ភ្នំពេញ។

២.វិទ្យាស្ថានវ៉ាន់ដា. (2016). *ការគ្រប់គ្រងហានិភ័យ*. បោះពុម្ពលើកទី២ ទំព័រទី១. ៧៧ទំព័រ. ភ្នំពេញ។

៣.វិទ្យាស្ថានវ៉ាន់ដា. (2019). *រូបិយវត្ថុ និងធនាគារ ភាគ១*. បោះពុម្ពលើកទី៥. ទំព័រទី៥៧. ៥៨ទំព័រ។

៤.Sathapana Bank. (2023). Annual Report 2023 ទំព័រទី២០ ១៤២ទំព័រ.

៥. ACADEMIA. Ory Kalip. (2023, April 29). *និយមន័យធនាគារ*. Retrieved from https://www.academia.edu/31513027/ (Accessed March, 03 2025).

៦.Facebook page. HRU. (2017, January 31). *និយមន័យធនាគារ*. Retrieved from https://www.facebook.com/share/p/1ACXBDpRTy/ (Accessed March, 03 2025).

៧. WordPress. Khem Sarith. (2016, October 04). *Banking Definitions*. Retrieved from https://khemsarith.wordpress.com (Accessed March, 03 2025).

៨.WIKIPEDIA. (2005, September 13). *History of banking*. Retrieved from https://en.m.wikipedia.org/wiki/History_of_banking (Accessed March, 05 2025).

៩.CRID. (2011, August 01-12). *Credit Management*. Retrieved from http://ocsrp.blogspot.com/2016/05/blog-post_78.html?m=1 (Accessed March, 05 2025).

១០.Nemet-Nejat, K. R. (1998). *Daily life in ancient Mesopotamia*. Westport, CT: Greenwood Publishing Group.

១១. Facebook. Khem Sarith. (2015, August 09). *Definition of Risk*. Retrieved from https://www.facebook.com/share/p/14uioNhirJ/ (Accessed March, 08 2025).

១២. EP. (2019, December 19-20). *Risk Theory*. Retrieved from https://www.europeanproceedings.com/article/10.15405/epsbs.2020.04.75 (Accessed March, 08 2025).

១៣. FINTECH. (2023, May 30). *Finbots.ai*. Retrieved from https://www.fintechfutures.com/ai-in-fintech/cambodia-s-sathapana-bank-taps-finbots-ai-for-enhanced-credit-risk-management (Accessed March, 08 2025).

# ឧបសម្ព័ន្ធ




Premier
Personal Banking
Business Portal
About Us
Help Center
Postcard
EN
AUD/USD 0.773 0.513
ធនាគារ ស្ថាបនា
SATHAPANA BANK
Personal
Business
Digital Banking
Women In Business
Promotion
News
TERM DEPOSIT ACCOUNT
EARN A HIGH INTEREST RATE
OPEN NOW VIA SATHAPANA MOBILE
DEPOSIT NOW
OPEN ACCOUNT
APPLY LOAN
SATHAPANA CARDS
DIGITAL BANKING
SPECIAL OFFER


BANKING&FINANCE RETAIL BANKING AWARDS 2022
AWARDS
2022
BEST MOBILE BANKING APP
CAMBODIA
SATHAPANA BANK
MOST INNOVATIVE MOBILE BANKING APP
CAMBODIA 2024
Sathapana Bank Plc
INTERNATIONAL FINANCE AWARDS
3:20
My KHQR
Sery Mongkol



ក្រុមប្រឹក្សាភិបាល
គណៈកម្មការសវនកម្ម
គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ
ប្រធាននាយកប្រតិបត្តិស្តីទី
គណៈកម្មការគ្រប់គ្រងហានិភ័យ
ការិយាល័យតំណាង ប្រចាំទីក្រុងយ៉ាំងហ្គូន ប្រទេសភូមា
អនុប្រធាននាយកប្រតិបត្តិ
អនុប្រធាននាយកប្រតិបត្តិ
អនុប្រធាននាយកប្រតិបត្តិ
នាយកប្រតិបត្តិ សវនកម្មផ្ទៃក្នុង
នាយកប្រតិបត្តិ សេវាហិរញ្ញវត្ថុបុគ្គល
នាយកប្រតិបត្តិបច្ចេកវិទ្យា និងព័ត៌មាន
នាយិកាប្រតិបត្តិ ប្រតិបត្តិការ
នាយិកាធនធានមនុស្ស នីតិកម្ម
នាយកប្រតិបត្តិ ហិរញ្ញវត្ថុ
នាយកប្រតិបត្តិ រដ្ឋបាល
នាយកប្រតិបត្តិ ប្រតិបត្តិការឥណទាន
នាយក គ្រប់គ្រងហានិភ័យ
ផ្នែកសវនកម្ម ប្រតិបត្តិការ
ផ្នែកសវនកម្មព័ត៌មានវិទ្យា
នាយករងប្រតិបត្តិ សេវាធនាគារបុគ្គល
នាយកដ្ឋាន គ្រប់គ្រងសាខា
ប្រធានតំបន់/សាខា
ផ្នែកលក់ និង ទំនាក់ទំនងអតិថិជន
នាយកដ្ឋាន សេវាស្តារបន្ទាប់ពីមានរឿង
នាយកដ្ឋានអភិវឌ្ឍន៍ ផលិតផលហិរញ្ញវត្ថុបុគ្គល
ផ្នែកអាជីវកម្ម ពាណិជ្ជកម្ម
នាយកដ្ឋានទំនាក់ទំនង អាជីវកម្មធនាគារ
នាយកដ្ឋាន ធនាគារឌីជីថល
នាយកដ្ឋាន ផលិតផលឌីជីថល
នាយកដ្ឋានអភិវឌ្ឍ អាជីវកម្មប័ណ្ណធនាគារ
នាយកដ្ឋានប្រតិបត្តិការ ប័ណ្ណធនាគារ
នាយកដ្ឋានប្រតិបត្តិការ អេធីអឹម និងម៉ាស៊ីនឆូតកាត
នាយកដ្ឋានលក់ ប្រតិបត្តិការធនាគារ
នាយកដ្ឋាន កម្មវិធីបច្ចេកវិទ្យាព័ត៌មាន
នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធ បច្ចេកវិទ្យាព័ត៌មាន
នាយកដ្ឋាន ប្រព័ន្ធធនាគារឌីជីថល
នាយកដ្ឋានអភិវឌ្ឍ បច្ចេកវិទ្យា
ការិយាល័យ គ្រប់គ្រងគម្រោង
នាយកដ្ឋាន ប្រតិបត្តិការ ទំនាក់ទំនងអតិថិជន
នាយកដ្ឋានប្រតិបត្តិការ ផ្ញើប្រាក់ និងពាណិជ្ជកម្ម
នាយកដ្ឋាន ឧត្តមភាព សេវាកម្មអតិថិជន
នាយកដ្ឋាន ទីផ្សារ ទំនាក់ទំនង និងស្លាកយីហោ
នាយកដ្ឋាន ធនធានមនុស្ស
ការិយាល័យ លេខាធិការដ្ឋាន
នាយកដ្ឋាននីតិកម្ម
នាយកដ្ឋាន ហិរញ្ញវត្ថុ
នាយកដ្ឋាន រតនាគិតយ
ផ្នែកគ្រប់គ្រង ប្រសិទ្ធភាព និង ផលិតភាពការងារ
ផ្នែកទំនាក់ទំនង អតិថិជនជប៉ុន
នាយកដ្ឋាន រដ្ឋបាល
ផ្នែកលទ្ធកម្ម
នាយកដ្ឋាន សន្តិសុខព័ត៌មានវិទ្យា
នាយកដ្ឋាន វាយតម្លៃ និងអនុម័តឥណទាន
នាយកដ្ឋាន រដ្ឋបាលឥណទាន
នាយកដ្ឋានគ្រប់គ្រង និងប្រមូលឥណទាន
ផ្នែកហានិភ័យ សហគ្រាស
ផ្នែកហានិភ័យ ឥណទាន
នាយកដ្ឋាន ប្រតិបត្តិតាម

- ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន
- បរិញ្ញាបត្ររង គណនេយ្យ
- បរិញ្ញាបត្រ គណនេយ្យ
- បរិញ្ញាបត្រ ភាសាអង់គ្លេស
  (សញ្ញាបត្រ ២ កម្រិត)
- បរិញ្ញាបត្ររងហិរញ្ញវត្ថុ និងធនាគារ
- បរិញ្ញាបត្រហិរញ្ញវត្ថុ និងធនាគារ
- អនុបណ្ឌិត គណនេយ្យ
- អនុបណ្ឌិត សវនកម្ម
- អនុបណ្ឌិត ពន្ធដារ






**ភ្នំពេញ**
អគារលេខ ២១៦-២១៨ មហាវិថីម៉ៅសេទុង
សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ
Tel: 023 213 563, Fax: 023 213 562
Vanda Institute of Accounting

**បាត់ដំបង**
ផ្ទះលេខ 271 ផ្លូវលេខ614 ភូមិរំចេក2
សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង
Tel: 053 732 563, Fax: 096 855 36 96
Vanda Institute of Battambang

**សៀមរាប**
អគារវឿន ផ្លូវសាលាពាណិជ្ជ ភូមិវត្តបូព៌
សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប
Tel: 017 370 268, Fax: 069 533 339
Vanda Institute Siem Reap Branch

www.vanda.edu.kh



ការគ្រប់គ្រងឥណទាន CREDIT MANAGEMENT


បាត់ដំបង ភ្នំពេញ សៀមរាប

# វិទ្យាស្ថាន វ៉ាន់ដា
# VANDA INSTITUTE



# ការគ្រប់គ្រងឥណទាន
# CREDIT MANAGEMENT


រក្សាសិទ្ធិគ្រប់យ៉ាងដោយវិទ្យាស្ថាន វ៉ាន់ដា


បោះពុម្ពលើកទី១(២០១៨)

សម្រាប់ប្រើផ្ទៃក្នុង